ឧស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ស្វែងរក
ការពិត

- សម្តែងរឿងពីរបបខ្មែរក្រហមដើម្បីធ្វើឱ្យចងចាំ
- អំពើចោរកម្មលើវត្ថុបុរាណប្រទេសកម្ពុជា

ចែកជូនដោយឥតគិតថ្លៃជល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៣ ខែឧសភា ឆ្នាំ២០១៤

ស្វែងរកការពិត

លេខ១៧៣ ខែឧសភា ឆ្នាំ២០១៨

ឧស្សាហដ្ឋានៃមជ្ឈមណ្ឌលឯកសារកម្ពុជា
មាតិកា

◆សម្តែងរឿងពីរបបខ្មែរក្រហមដើម្បីធ្វើឲ្យចងចាំ ១

ផ្នែកឯកសារ

◆ បំផុសការចិត្តៀន ស្ម័យចិត្តៀននៅក្នុងជួរ ២

◆ ហ៊ីង សុខុម : ទិស្សនិកថ្នាក់ម៉ាស្ទ័រ ៨

ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ អ៊ុន ភឿន មេក្រុមកងពិសេស ផ្នែកដើងទឹក ១៨

◆ ការចងចាំ «ទ្រីពុកម្តាយខ្ញុំស្លាប់ដោយសារ...» ២២

◆ ខ្ញុំម្នាក់ប៉ុណ្ណោះដែលមានជីវិតរស់ ២៦

◆ ឈួន ណារ៉ែន : ដេកយាមស្រូវត្រូវវាយ ២៩

ផ្នែកច្បាប់

◆ សំណុំរឿង០០៣ និង ០០៤ : និយមន័យ ៣៩

វេទិកាពិភាក្សាសាធារណៈ

◆ អំពើចោរកម្មលើវត្ថុបុរាណប្រទេសកម្ពុជា ៤៧

ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ទុកក៏មិនចំណេញ ៥២

◆ ជីវិតម្តាយខ្ញុំនៅក្នុងរបបខ្មែរក្រហម ៥៤

◆ ឃើញពន្ធ៍ថ្ងៃមានន័យថារស់ ៥៦

◆ មិនដែលភ្ជាប់ពីទុក្ខលំបាក ៥៨

◆ អ្វីដែលរបបខ្មែរក្រហមបន្សល់ទុកសម្រាប់ខ្ញុំ ៦០





ការសម្តែងនៅក្នុងទិវានៃការចងចាំថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨

រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យចោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរខក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ស្នេហ៍លេខនេះ : សាយ ទិត្យពិសី, ម៉ាកាស់ ស៊ីម័រ, រ៉ែន ឌុលដីហ្ការ, យូម លីនណា, ជ្ជ ម៉ាប់, រ៉ង ស៊ីវ៉ាថ, អៀង ណារី **អ្នកនិពន្ធនិងស្រាវជ្រាវ :** ៣រ សារៈមុនិន្ទ, ស៊ុន សុធីតា **អ្នកបកប្រែ :** ភ្ជង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ :** ឆាំង យុ និង ញ្ញាណ សុជាតិ **ជំនួយការនិពន្ធនាយក :** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ :** សោម ប៊ុនថន **ត្រួតត្រួតការចែកផ្សាយ :** ឆេង រ៉ើង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

សម្តែងរឿងពីរបបខ្មែរក្រហមដើម្បីធ្វើឱ្យចងចាំ

ណេម ភារិទ្ធ មិនដែលឆ្លងកាត់របបខ្មែរក្រហមទេ ប៉ុន្តែគាត់តែងមកសម្តែងរឿងរ៉ាវពីរបបដែលមានអាយុកាលបីឆ្នាំ ប្រាំបីខែ និងម្ភៃខែនេះជារៀងរាល់ឆ្នាំ ។ ក្នុងវ័យ២៧ឆ្នាំ និងជានិស្សិតនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្ប: ភារិទ្ធ សម្តែងរឿងរ៉ាវជីវិតពីរបបខ្មែរក្រហមយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ គឺនៅថ្ងៃទី៧ ខែមករា ជាថ្ងៃរបបខ្មែរក្រហមដួលរលំ និងនៅថ្ងៃទី២០ ខែឧសភា ជាពេលដែលខ្មែរក្រហមបង្កើតសហករណ៍លើកដំបូងកាលពីថ្ងៃទី២០ ខែឧសភាឆ្នាំ១៩៧៣ ។

ថ្ងៃទី២០ ខែឧសភា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជា «ទិវានៃការចងចាំ» ដែលបានប្រារព្ធតាំងពីឆ្នាំ១៩៨៤ មក ដោយពេលនោះ ត្រូវបានដាក់ឈ្មោះថា «ថ្ងៃចងកំហឹង» ។ រៀងរាល់ថ្ងៃទី២០ ខែឧសភា សាច់រឿងទាក់ទងនឹងរឿងរ៉ាវជីវិតពីរបបខ្មែរក្រហមត្រូវបានយកមកសម្តែងនៅវាលពិឃាដដើងឯក ដោយមានការចូលរួមពីសំណាក់មន្ត្រីរដ្ឋាភិបាល ព្រះសង្ឆ ដូនជី ប្រជាពលរដ្ឋ សិស្ស-និស្សិតរាប់ពាន់នាក់ ។ ការសម្តែងនេះ រៀបរាប់ត្រួសៗពីសាច់រឿងក្នុងរបបខ្មែរក្រហម រួមមានការជម្លៀសដោយបង្ខំ ការពង្រាត់សមាជិកគ្រួសារ ការបង្ហត់អាហារ ការវាយដំ ប្រហារ ការធ្វើទារុណកម្ម ការសម្លាប់ និងការរលំរលាយនៃរបបខ្មែរក្រហម ។

ណេម ភារិទ្ធ នៅសារមន្ទីរប្រល័យពូជសាសន៍ដើងឯក

រៀងរាល់ឆ្នាំ ភារិទ្ធ សម្តែងជាតួជនរងគ្រោះ ដែលត្រូវកម្មាភិបាលខ្មែរក្រហមសម្លាប់ ប៉ុន្តែឆ្នាំនេះ គាត់បានដើរតួជាមេកងវិញ ដោយមានអំណាច និងសម្លាប់រណាដែលចោទប្រកាន់ថា ល្មើសនឹងបទបញ្ជារបស់អង្គការ ។ ក្នុងនាមជាតួសម្តែង មេកងភារិទ្ធ បានទុកពុកមាត់វែងៗ ធ្វើមុខកាច និងមានកំហឹង និងសម្តែងកាយវិការធ្វើឲ្យប្រជាជនខ្លាច ។

ភារិទ្ធ រៀនសូត្រពីរបបខ្មែរក្រហមតាមរយៈឪពុកម្តាយ ដែលតែងតែរៀបរាប់ប្រាប់គាត់ជារឿយៗកាលពីគាត់នៅក្មេង ។ កាលពីជំនាន់នោះ ឪពុកម្តាយរបស់គាត់រស់នៅស្រុកមុខកំពូល ខេត្តកណ្តាល ដោយធ្វើការងាររាប់ដូចប្រជាជនដទៃទៀតដែរ ។ គាត់បានបាត់បង់អ្នកប្រុសម្នាក់ក្នុងរបបនោះ ។ ក្រៅពីរៀនសូត្រពីឪពុកម្តាយនិយាយប្រាប់ ភារិទ្ធ បានរៀនសូត្រពីរបបខ្មែរក្រហមតាមរយៈការសិក្សានៅក្នុងថ្នាក់ ។ ជាក់ស្តែង មុននឹងមកសម្តែងជាតួមេកងនៅថ្ងៃទី២០ ខែឧសភានេះ ភារិទ្ធ បានមើលខ្សែវីដេអូជាច្រើនទាក់ទងនឹងរបបខ្មែរក្រហមនៅក្នុងថ្នាក់ជាមួយនិស្សិតផ្សេងទៀត និងបានចូលរួមការហ្វឹកហាត់ជាច្រើនលើកច្រើនសា ។

ភារិទ្ធ និយាយថា គាត់ចង់សម្តែងរឿងរ៉ាវទាក់ទងនឹងជីវិតក្នុងរបបខ្មែរក្រហមនេះដើម្បីឲ្យសាធារណជនដឹងពីអ្វីដែលបានកើតឡើងក្នុងរបបនោះ ទោះបីជាអ្វីដែលគាត់សម្តែងមិនស្មើជាដូចនឹងអ្វីដែលបានកើតឡើងពិតប្រាកដក៏ដោយ ។

ញ្ញាណ សុថ្ងៃ

បំផុសការធិតៀន ស្វ័យធិតៀន នៅក្នុងថ្ងរយុវជន យុវនារីបដិវត្តន៍យើងឱ្យខ្លាំងក្លា និងប្រាលប្រៅថាប់ថានិច្ច

ដកស្រង់ចេញពីទស្សនាវដ្ដីទង់បដិវត្តន៍ ឯកសារលេខ D២១៣៩០

អ្នកដែលធ្លាប់ឆ្លងកាត់ និងរួចរស់ជីវិតពីរបបខ្មែរក្រហម ពិតជាធ្លាប់ព្ធនូវពាក្យថា «ទិតៀន និង ស្វ័យទិតៀន» មិនខាន ។ ក្នុងរបបខ្មែរក្រហម ការប្រជុំធ្វើការ ទិតៀន និងស្វ័យទិតៀន គឺធ្វើឡើងជាញឹកញាប់ បន្ទាប់ពីធ្វើការងាររួច ឬហូបបបររួច ។ ពាក្យថា ទិតៀន នាពេលនោះ គឺមានន័យថា ពិនិត្យ តាមដានសមាជិកក្រុម ទាំងគុណវិបត្តិ និងគុណសម្បត្តិ សីលធម៌ ជាដើម ដើម្បីមានមតិអប់រំ កែតម្រូវចំពោះបុគ្គលណាដែលធ្វើខុស ខ្ជិលធ្វើការងារ ឲ្យមានការភ្ញាក់រពុកជៀសវាងបុគ្គលនោះធ្វើឲ្យរាំងស្ទះដល់ចលនាបដិវត្តន៍ ។ ជាក់ស្តែងនៅក្នុងរឿង «ស្រមោលបង» ដែលជារឿងពិតមួយរបស់អ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហម បានលើកឡើងពីចំណុចនិយាយអំពីការប្រជុំទិតៀនកាត់ និងស្វាមី អំពីសីលធម៌ ដោយពេលនោះ ប្រធានអង្គប្រជុំលើកថា «អ្នកខ្លះមិនចោលរបៀបរបបចក្រពត្តិអាសអាភាសសូម្បីតែទៅងូតទឹកក៏បណ្ដើរគ្នាឲ្យត្រសងសប្បាយរីករាយណាស់ក្នុងពេលដែលយុទ្ធជនយើងនៅកំពុងប្រយុទ្ធស៊ីសាច់ហុតឈាមគ្នាជាមួយពួកអាមេរិកនៅឡើយ» ។ និយាយដល់ត្រង់នេះ ក្រប់គ្នាងាកមើលស្រមកប្ដីប្រពន្ធអ្នកទាំងពីរ ។ តាំងពីថ្ងៃនោះមក អ្នកទាំងពីរក៏លែងហ៊ានបណ្ដើរគ្នាទៅងូតទឹកទៀត ។

ឯពាក្យ ស្វ័យទិតៀន គឺចង់សំដៅលើយើងខ្លួនឯង ធ្វើការវាយតម្លៃខ្លួនឯងពីគុណភាពការងារ ពីភាពខ្វះខាតរបស់ខ្លួនចំពោះមុខសមូហភាព ឬក៏អង្គការ ។ មនុស្សមួយចំនួន ត្រូវខ្មែរក្រហមយក

យុវជន និង យុវនារី ឡើងប្តេជ្ញាក្នុងពេលប្រជុំស្វ័យទិតៀន

ទៅសម្ងាប់ បន្ទាប់ពីប្រជុំ ទិតៀន និងស្ទ័យទិតៀន នេះ ព្រោះអ្នកដ្ឋាន ពេលប្រជុំ អ្នកខ្លះព្រោះតែចង់ផ្គាប់ចិត្តអង្គការ ក៏ដូចជាយកគុណសម្បត្តិ តែងតែធ្វើការទិតៀនចំពោះសមាជិកក្រុម ក៏ដូចជាអ្នកដទៃទៀតថា មិនល្អ ខ្ជិលច្រអូសនឹងការងារ ធ្វើឲ្យខូចទ្រព្យសម្បត្តិអង្គការ លួចរត់ទៅជួបបងប្អូន ធ្វើពុតជាឈឺ ឬលួចហូបជាឯកជនជាដើម ។ ហេតុនេះ ការប្រជុំទិតៀន និងស្ទ័យទិតៀន នៅពេលនោះ ពិតជាមានគ្រោះថ្នាក់ណាស់ ព្រោះបន្ទាប់ពីការប្រជុំហើយ អ្នកដែលត្រូវគេរាយការណ៍ទាំងនោះ ត្រូវអង្គការយកទៅរៀនសូត្រអស់ ពាក្យថា «រៀនសូត្រ» គឺ ស្មើនឹងពាក្យ «ស្លាប់» ហើយក៏មិនដែលឃើញត្រឡប់មកវិញដែរ ។

ចំពោះខ្មែរក្រហម តើពាក្យ «ទិតៀន និងស្ទ័យទិតៀន» នេះ មានសារសំខាន់យ៉ាងណាក្នុងចលនាបដិវត្តន៍? ខាងក្រោមនេះ ជាអត្ថបទដកស្រង់ចេញពីទស្សនាវដ្ដីទង់ប្រដិវត្តន៍លេខ១០ ខែឧសភា ឆ្នាំ១៩៧០ ដែលនិយាយអំពីខ្ចីមសារ និងសារសំខាន់នៃការ «ទិតៀន និងស្ទ័យទិតៀន» ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

១.សារសំខាន់នៃការទិតៀន ស្ទ័យទិតៀន នៅក្នុងចលនាបដិវត្តន៍យើងកន្ធងមក

ការបដិវត្តន៍ គឺជាការតស៊ូកម្ចាត់ចាស់ ដែលប្រតិកិរិយាដ៏ះដាន់ ឈ្លានពាន ពុករលួយ ពាលា អាវ៉ាសែ និងខ្ជិនថយ ហើយកសាងថ្មីដែលបដិវត្តន៍ល្អបរិសុទ្ធ ស្អាតស្អំ និងចម្រើនជឿនលឿន ។ និយាយម្យ៉ាងទៀត ផ្ទើបដិវត្តន៍ គឺធ្វើការតស៊ូវណ្ណៈតឹងតែង ស្លាប់រស់ ដើម្បីវាយកម្ទេចខ្មាំងសត្រូវវណ្ណៈ នៅក្នុងសង្គមជាតិ ជាចក្រពត្តិ សក្តិភូមិ នាយទុន និងខ្មាំងសត្រូវវណ្ណៈ នៅក្នុងខ្លួនយើងម្នាក់ៗជាទស្សនៈ គោលជំហរ សតិអារម្មណ៍ និងទម្លាប់ចាស់ ដែលមិនបដិវត្តន៍ មិនអធន មិនសមូហភាព មិនចម្រើនជឿនលឿន ។ ដើម្បីមានកម្លាំងវាយកម្ទេចខ្មាំងសត្រូវវណ្ណៈ នៅក្នុងសង្គមជាតិ ជាចក្រពត្តិ សក្តិភូមិ នាយទុន បានខ្លាំងក្លា ហើយដណ្ដើមបានជ័យជម្នះជាបន្តបន្ទាប់ ជនបដិវត្តន៍យើង ក៏ដូចជា យុវជន យុវនារីបដិវត្តន៍យើងត្រូវ្ចរ ចាំបាច់ត្រូវវាយកម្ទេច វាយកម្ចាត់ខ្មាំងសត្រូវវណ្ណៈ ដែលស្ថិតនៅក្នុងខ្លួនយើងម្នាក់ៗ ឲ្យបានខ្លាំងក្លាជាប់ជានិច្ច ហើយយកឈ្នះលើវា ឲ្យបានជាបន្តបន្ទាប់ ។ ដើម្បីវាយកម្ទេច និងវាយកម្ចាត់ខ្មាំងសត្រូវ វណ្ណៈ នៅក្នុងខ្លួនយើង ដណ្ដើមបានជ័យជម្នះ ជាបន្តបន្ទាប់ ជាប់ជានិច្ច យើងត្រូវមានវិធី និងអាវុធសក្តិសិទ្ធិដើម្បីកម្ទេចវា កម្ចាត់វា ។

ដើម្បីវាយកម្ទេចខ្មាំង ជាចក្រពត្តិ សក្តិភូមិ នាយទុនយុវជនយុវនារីកម្ពុជាយើង ត្រូវក្រោកឡើងធ្វើការតស៊ូបដិវត្តន៍ ផ្ទើសង្គ្រាមប្រជាជន ដោយប្រើហិង្សានយោបាយ និងហិង្សាអាវុធ បាញ់ប្រហារ វាយកម្ទេចវា ។ ប៉ុន្ដែ យើងពុំអាចយកអាវុធ ជាកាំភ្លើង គ្រាប់បែក កាំបិត ផ្ដាក់ដំបង ព្រនង់ មកប្រហារ ឬកម្ទេចខ្មាំងសត្រូវនៅក្នុងខ្លួនយើងម្នាក់ៗ បានឡើយ ពីព្រោះអ្ជីខ្មាំងសត្រូវនៅក្នុងខ្លួនយើងម្នាក់ៗ វាជាវត្ថុធាតុអរូបី មើលមិនឃើញ ចាប់មិនបាន ។ ដូច្នេះ ដើម្បីវាយកម្ចាត់វាដោយប្រសិទ្ធភាព បក្សកុម្មុយនីស្ដកម្ពុជាយើងបានយក **ការទិតៀន ស្ទ័យទិតៀន** ផ្ទើជាអាវុធសំខាន់បំផុត ដើម្បីផ្ទើការប្រយុទ្ធបដិវត្តន៍ នៅលើសមរភូមិអរូបីនេះ ។

ទិតៀន គឺជាការត្រួតពិនិត្យ តាមដាន ទាំងគុណសម្បត្តិ ទាំងគុណវិបត្តិរបស់សមមិត្តយើង ក្នុងការរស់នៅ និងធ្វើការងារបំពេញភារកិច្ចបដិវត្តន៍ប្រចាំថ្ងៃ ដើម្បីមានមតិជួយកសាងតម្រែតម្រង់ និងជាស់គ្ជឿនក្រើនរំពុក ឲ្យសមមិត្តយើងប្រកាន់យក ឬដើរតាមផ្លូវល្អ ត្រឹមត្រូវជានិច្ច ហើយជៀសវាង ឬគេចឲ្យផុតពីការដើរខុសផ្លូវ ឬការធ្លាក់ទៅក្នុងផ្លូវមិនល្អ ដែលនឹងអាចបណ្ដាលឲ្យមានគ្រោះមហន្ដរាយ គិចក្ដី ច្រើនក្ដីដល់ចលនាបដិវត្តន៍ដល់បក្ស ក៏ដូចជាដល់បុគ្គលខ្លួនឯងម្នាក់ៗដែរ ។

ឯ.ស្ទ័យទិតៀន គឺជាការត្រួតពិនិត្យ តាមដានខ្លួនឯង ការស្គាល់ និងមើលឃើញខ្លួនឯងឲ្យបានច្បាស់លាស់ សត្យានុមតិ ទាំងគុណសម្បត្តិ ទាំងគុណវិបត្តិ ហើយលើកយកមកលាតត្រដាងជូនសមូហភាព និងអង្គការជួយពិនិត្យវិនិច្ឆ័យ ជួយកសាងតម្រែតម្រង់ និងជួយតាមដានតម្រែតម្រង់ជាបន្ដបន្ទាប់ តទៅថ្ងៃមុខទៀត ។

តាមពិសោធន៍កន្ធងមក ក្នុងការអនុវត្ដជាក់ស្ដែងនូវទិតៀនស្ទ័យទិតៀនរបស់បក្សក្នុងចលនាបដិវត្តន៍យើង ឃើញថាទិតៀនស្ទ័យទិតៀនរបស់បក្សក្នុងចលនាបដិវត្តន៍យើងនេះ ជាអាវុធមួយសំខាន់បំផុត និងមានប្រសិទ្ធភាពបំផុត ក្នុងការកម្ចាត់នូវគុណវិបត្តិ ជ្ជុំញ្ជាបំផុស និងពង្រឹងពង្រីកចលនាបដិវត្តន៍យើងឲ្យរឹងប៉ឹងខ្លាំងក្លាឡើងជាលំដាប់ ។ ចាប់តាំងពីមានចលនាបដិវត្តន៍មកបក្សកុម្មុយនីស្ដកម្ពុជាយើងបានអនុវត្ដទិតៀន ស្ទ័យទិតៀន នៅក្នុងជួរបដិវត្តន៍យើងទាំងមូល យ៉ាងហ្មត់ចត់ទៀងទាត់ជាប់រៀងរហូតមក ហើយ

ជានកំណត់ជាលាក់ការណ៍យកការទិតៀនេះ ធ្វើជាអាវុធដើម្បីកសាងពង្រឹងពង្រីកជួរបក្ស ជួរបដិវត្តន៍ និងជួរយុវជន យុវនារីបដិវត្តន៍យើង ។ ដូច្នេះហើយ ជានជាជួរយុវជន យុវនារីបដិវត្តន៍យើងចេះតែត្រូវជានពង្រឹង និងពង្រីកឡើង ទាំងបរិមាណ ទាំងគុណភាពជាបន្តបន្ទាប់ ។ ដោយសារការអនុវត្តទិតៀន ស្ទ័យទិតៀនជានហ្មត់ចត់ ទៀងទាត់ជាប់ជានិច្ច ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ។

តើកសាងសង្គមនិយមមានន័យយ៉ាងណា?

កសាងសង្គមនិយម ជាការកសាងទាំងសម្ភារ ទាំងខាងនយោជាយចាត់តាំង តែសំខាន់បំផុតនោះ គឺការកសាងខាងសតិអារម្មណ៍ ។ កសាងសង្គមនិយម គឺកសាងសតិអារម្មណ៍សមូហភាពនៃវណ្ណៈអធនរបស់បក្ស កសាងទស្សនៈគោលជំហរ និងលោកទស្សនៈបដិវត្តន៍នៃវណ្ណៈអធន កសាងនិស្ស័យសង្គមនិយម ដែលសមូហភាព គោរពអង្គការវិន័យខ្ពស់ កសាងនូវទម្លាប់ និងរបៀបរបបរស់នៅធ្វើការងារ គិតគូរ និយាយស្តី ជាសង្គមនិយម គឺទៅតាមទស្សនៈគោលជំហរអធនរបស់បក្ស ។

ដូច្នេះ រយៈកាលធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្នេះ ជារយៈកាលនៃការតស៊ូវណ្ណៈតឹងតែង ស្មុគស្មាញជាទីបំផុត ។ ការតស៊ូវណ្ណៈនៅក្នុងរយៈកាលបដិវត្តន៍សង្គមនិយមនេះ ក្នុងករណីខ្លះ មានលក្ខណៈតឹងតែង ស្លាប់រស់ ជាងការតស៊ូវណ្ណៈ កាលពីក្នុងសម័យសង្ត្រាមបដិវត្តន៍ទៅទៀត ។ បើយើងពិនិត្យមើលជារូបភាពខាងក្រៅ ឃើញហាក់ដូចជាគ្មានការតស៊ូវណ្ណៈ ឬឃើញហាក់ដូចជាធ្វើបដិវត្តន៍សង្គមនិយម ស្រួលជាង ធូរជាង ជំនាន់តស៊ូធ្វើសង្ត្រាមប្រជាជន ក្នុងសម័យបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ ពីព្រោះវាគ្មានខ្មាំង គ្មានកប៉ាល់ហោះ គ្មានកាំភ្លើងធំ កាំភ្លើងផ្លោង គ្មានគ្រាប់បែក គ្មានរថក្រោះ គ្មានកប៉ាល់ចម្បាំងខ្មាំងឡើងមករាតត្បាត ជាញ់សម្លាប់ បំផ្ទិចបំផ្លាញ តាមដើងគោក ដើងទឹក ដើងអាកាស គ្មានការកាប់សម្លាប់បង្ហូរឈាមគ្នារាល់ថ្ងៃរាល់ម៉ោង ដូចកាលសម័យសង្ត្រាមទៀតឡើយ ។ ប៉ុន្តែ បើពិនិត្យឲ្យដល់ជម្រៅ ឲ្យដល់ខ្ទឹមសារនៃបដិវត្តន៍សង្គមនិយមទៅវិញ ឃើញថា ការតស៊ូវណ្ណៈក្នុងសម័យសន្តិភាព ក្នុងសម័យកសាងសង្គមនិយម កសាងប្រទេសបច្ចុប្បន្នេះ វាមានការតឹងតែង ស្មុគស្មាញ ស្លាប់រស់ជាទីបំផុត ។ ការស្លាប់រស់នេះ មិនមែនស្លាប់រស់ជាបុគ្គលមួយនាក់ ពីរនាក់ ១០-២០នាក់ ឬ១០០-១.០០០នាក់ ដូចកាលសម័យសង្ត្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកនោះទេ ។ តែការស្លាប់រស់បច្ចុប្បន្នេះ គឺការស្លាប់រស់ ដល់របបទាំងមូល ដល់បដិវត្តន៍ទាំងមូល ដល់ប្រទេសជាតិទាំងមូល ។

កាលពីក្នុងសម័យសង្ត្រាម យើងត្រូវប្រយុទ្ធទល់ជាមួយខ្មាំងសត្រូវ ជាចក្រពត្តិ សក្តិភូមិ នាយទុន ឬយន្តហោះកប៉ាល់ចម្បាំងរថក្រោះ ដែលយើងមើលឃើញស្តាប់ព្ទ ហើយទទួលរងនូវការឈឺចាប់ខ្លោចផ្សា ជាក់ស្តែងលើរូបរាងកាយក្តី ខាងផ្លូវចិត្តក្តី ខាងមនោសញ្ចេតនាក្តី ដោយផ្ទាល់តែម្តង ដូច្នេះ យើងមានកំហឹងជាប់ មានការប្រុងប្រយ័ត្នជាប់ មានការត្រៀមប្រយុទ្ធកម្ទេចវាជាប់ ដើម្បីការពារខ្លួន ការពារបដិវត្តន៍ ការពារតំបន់រំដោះ ការពារស្រុក ភូមិ និងទ្រព្យសម្បត្តិរបស់ប្រជាជនយើង ពុំដែលមានពេលភ្លេចភ្លាំង ឬស្ពឹកស្រពន់ខាងទស្សនៈ គោលជំហរឡើយ ។ ប៉ុន្តែឥឡូវ យើងមានសន្តិភាព យើងមានជីវភាពរស់នៅធ្វើការងារពិតមែន តែមិនទាន់សម្បូរសប្បាយក៏ដោយ តែក៏មានលក្ខណៈងាយស្រួលជាងកាលសម័យសង្ត្រាមដែរ ។ តទៅអនាគតទៀត ដែលយើងកសាងប្រទេសកាន់តែរីកចម្រើនលើគ្រប់ផ្នែក នោះជីវភាពខាងសម្ភាររបស់យើងក៏នឹងកាន់តែចម្រើនធូរធារឡើងជាលំដាប់ទៀត ។ ក្នុងសភាពសត្យានុមតិយ៉ាងនេះ ទោះចង់ ឬមិនចង់ ដឹងខ្លួនក្តី ឬមិនដឹងខ្លួនក្តី ទស្សនៈគោលជំហរបដិវត្តន៍របស់យើង ងាយរវាតពីទស្សនៈគោលជំហរមាក៏ក៏ត្រឹមត្រូវរបស់បក្សណាស់ មិនថា យុទ្ធជន យុទ្ធនារី ឬកម្មាភិបាលថ្នាក់ណាៗឡើយ ។ ទស្សនៈគោលជំហរ សក្តិភូមិ នាយទុន និងវណ្ណៈជិះជាន់ផ្សេងៗទៀត ក៏ងាយស៊ិកសៀតជ្រៀតចូលមកក្នុងជួរបដិវត្តន៍យើង មកក្នុងជួរបក្សយើង ក៏ដូចមកក្នុងសង្គមជាតិយើងទាំងមូលដែរ ។ ឯទស្សនៈគោលជំហរ សតិអារម្មណ៍ មិនបដិវត្តន៍ផ្សេងៗ ពិសេស សតិអារម្មណ៍កម្មសិទ្ធិឯកជន កម្មសិទ្ធិបុគ្គលសួនតួ ដែលយើងពុំទាន់ជានវាយកម្ចាត់វាចេញឲ្យអស់ជ្រះស្រឡះពីក្នុងខ្លួន ហើយដែលវាក្រាបពួនសម្ងំនៅក្នុងខ្លួនយើងម្នាក់ៗ យូរមកហើយនោះ ក៏វាអាចកម្រើក អាចផុសដើបឡើងវិញ ហើយអាចពង្រឹងពង្រីកខ្លួនវាវិញជានឆាប់រហ័សដែរ ។ ដូចមិត្តយើងជ្រាបន័យនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជា

ពីខាងដើម ស្រាប់មកហើយ បើទស្សនៈ គោលជំហរ សតិអារម្មណ៍ សក្តិភូមិ នាយទុន និងវណ្ណៈជិះជាន់ផ្សេងៗទៀត ជាពិសេស សតិអារម្មណ៍កម្មសិទ្ធិឯកជន កម្មសិទ្ធិបុគ្គលសួនតួ វាវើរើបង្ហើងវិញ ហើយវាពង្រឹងពង្រីកខ្លួនវាបានវិញ ទាំងនៅក្នុងជួរយុវជនយុវនារីបដិវត្តន៍យើងក្តី ទាំងនៅក្នុងជួរបដិវត្តន៍ទាំងមូលក្តី នៅក្នុងជួរបក្សទាំងមូលក្តី ឬនៅក្នុងសង្គមជាតិយើងទាំងមូលក្តី នោះបានសេចក្តីថា របបចក្រពត្តិ សក្តិភូមិ នាយទុន វាវាយរបបសង្គមនិយមឈ្នះហើយ ។ ឯបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជា នោះបើជាទិតទំបង្គ្រប ង្ហើនផលបាន១០ គោន១ហិកតា កសាងរោងចក្របានរាប់ម៉ឺនខ្នងយ៉ាងណាក៏ដោយ ក៏ពុំមែនមានន័យ ឬខ្វីមសារ ជាសង្គមនិយមអ៊ីទៀតឡើយ ។ ការនេះ បានសេចក្តីថា បដិវត្តន៍សង្គមនិយមយើង ត្រូវរលំរលាយហើយ ត្រូវបរាជ័យហើយ ។ ប្រទេសជាតិយើង នឹងធ្លាក់ខ្លួនទៅជាខ្ទុំកញ្ជ្រះគេ បាត់បង់ក្តីឈ្នោះ អាប់ឧ៩ិនកិត្តិយស ដូចមុន ឬលើសមុនទៀតផង ។ នេះហើយជាគ្រោះមហន្តរាយធំបំផុត ដែលយុវជន យុវនារីកម្ពុជាយើង ដែលជាអ្នកបន្តវេនបដិវត្តន៍ បន្តវេនផ្ទើបដិវត្តន៍សង្គមនិយម និងកុម្មុយនីស្តនិយមតទៅអនាគតទៀត ត្រូវមើលឃើញឲ្យច្បាស់ មើលឃើញឲ្យវែងឆ្ងាយ ហើយចាប់អារម្មណ៍ឲ្យខ្ពស់ ដើម្បីមានវិធានការប្រុងប្រយ័ត្នទប់ទល់ និងវាយកម្ចាយវាឲ្យបានដាច់ខាតជាប់ជានិច្ច និងរៀងរហូតតទៅជំនាន់ក្រោយៗទៀត ។

ឃើញគ្រោះអាសន្នយ៉ាងនេះ ដើម្បីធានាឲ្យបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាយើងដណ្តើមបានជ័យជម្នះ លោតផ្លោះ ជាបន្តបន្ទាប់រៀងរហូតទៅ យុវជន យុវនារីបដិវត្តន៍យើង ចាំបាច់បន្តធ្វើការតស៊ូវណ្ណៈឲ្យខ្លាំងក្លា ហើយកាន់តែក្តៅ កាន់តែជ្រាលជ្រៅថែមទៀត នៅក្នុងជួរបដិវត្តន៍ទាំងមូល ក៏ដូចក្នុងយុវជន យុវនារីបដិវត្តន៍ទាំងមូល ក៏ដូចជាក្នុងអង្គភាព មន្ទីរក្រសួង ការដ្ឋាន សហករណ៍នីមួយៗ ហើយនិងក្នុងខ្លួនយើងម្នាក់ៗដែរ ។ ដើម្បីបន្តធ្វើការតស៊ូវណ្ណៈ ដូចពោលខាងលើនេះឲ្យបានកាន់តែខ្លាំងក្លា វាចាមចារនូវការទិតៀន សុំយទិតៀន នៅក្នុងជួរយើង នៅក្នុងអង្គភាពយើងនីមួយៗឲ្យបានក្តៅនឹងជ្រាលជ្រៅថែមទៀត ។

ដូច្នេះ ក្នុងរយៈកាលបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្ននេះ ការទិតៀន សុំយទិតៀន ជា

យុវជន និង យុវនារីខ្មែរក្រហម ប្រមូលផ្លែត្រឡាចដាក់រនេះ

អារុំធម្ងយសំខាន់បំផុត និងចាំបាច់បំផុត ដែលយុវជន យុវនារីគ្រប់រូប ក៏ដូចជនបដិវត្តន៍គ្រប់រូប ត្រូវប្រកាន់ខ្ជាប់ ដើម្បីដណ្តើមយកជ័យជម្នះឲ្យបានដាច់ខាត ។

២.ត្រូវបំផុសការទិតៀន សុ័យទិតៀនឲ្យខ្លាំងក្លា និងជ្រាលជ្រៅជាប់ជានិច្ចនៅក្នុងជួរ យុវជន យុវនារីបដិវត្តន៍យើង

ក្នុងរយៈកន្លងមក នៅក្នុងជួរបដិវត្តន៍យើងទាំងមូល ក៏ដូចជានៅក្នុងជួរយុវជន យុវនារីយើងទាំងមូលដែរ មានធ្វើការទិតៀន សុ័យទិតៀន បានទៀតទាត់ ហ្មត់ចត់ ក្នុងគ្រប់កាលៈទេសៈ ក្នុងគ្រប់អង្គភាព តាមរយៈប្រជុំជីវភាពការងារក្តី ប្រជុំស៊ីជម្រៅក្តី និងតាមរយៈការធ្វើជីវទស្សនបដិវត្តន៍ក្តី ។ អាស្រ័យហេតុនេះហើយ បានជាជួរយុវជន យុវនារីបដិវត្តន៍យើង ត្រូវបានពង្រឹង និងពង្រីកឡើងជាលំដាប់ក្នុងគ្រប់កាលៈទេសៈលំបាក ស្រួល ។ ដូច្នេះហើយ បានជាយុវជន យុវនារីបដិវត្តន៍យើងមានគោលជំហរស្រួចស្រាវបំផុត ក្មានរួញរា ក្មានស្ទាក់ស្ទើរ មិនចុះញ៉ាមខ្មាំងសត្រូវឡើយ មានវីរភាពអង់អាចក្លាហានខ្ពស់បំផុត ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ពុះពារឆ្លងកាត់ខបសគ្គតូចធំ និងការលំបាកវេទនាច្រើនរាប់មិនអស់ ដើម្បីប្រយុទ្ធវាយកម្ទេចខ្មាំង ក៏ដូចដើម្បីប្រយុទ្ធសម្រេចភារកិច្ចបដិវត្តន៍តូច ធំ គ្រប់បែបយ៉ាង ដែលបក្សប្រគល់ឲ្យដណ្តើមបានជោគជ័យធំដុំ ជាបន្តបន្ទាប់ រហូតដល់សម្រេចជ័យជម្នះទាំងស្រុង និងស្ថាពរនៅថ្ងៃ ១៧មេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ យុវជន យុវនារីបដិវត្តន៍យើង ក៏នៅបានបន្តអនុវត្តការទិតៀន សុ័យទិតៀន ដើម្បីកសាងខ្លួន និងកសាងអង្គភាពខ្លួនឲ្យកាន់តែមានគោលជំហរបដិវត្តន៍រឹងប៉ឹងលើគ្រប់ផ្នែកថែមទៀត ដើម្បីសម្រេចភារកិច្ចការពារប្រទេស និងកសាងប្រទេសជាបន្តទៀត ។ ក្នុងរយៈ ១ឆ្នាំកន្លងទៅនេះ យុវជន យុវនារីបដិវត្តន៍យើង ក៏បានរួមចំណែកយ៉ាងសកម្មសម្រេចភារកិច្ចធំពីរនេះ បានល្អប្រសើរ និងដោយជោគជ័យ ។

តែទន្ទឹមនឹងគុណសម្បត្តិ ដែលមានខាងលើនេះ យើងក៏សង្កេតឃើញនៅមានការខ្ទះខាតដោយ អន្ទើៗ ដោយកន្លែងៗ ដែរចំពោះបញ្ហាទិតៀន សុ័យទិតៀននេះ ។

◆ នៅកន្លែងខ្លះ ឬតាមអង្គភាពខ្លះ មិនសូវមានការប្រជុំទិតៀន សុ័យទិតៀន ឬការអប់រំរៀន សូត្រឆ្លងជីវទស្សនបដិវត្តន៍ ឲ្យបានញឹកញាប់ទៀងទាត់ ហ្មត់ចត់ទេ ។

◆ នៅកន្លែងខ្លះទៀត ឬតាមអង្គភាពខ្លះ មានប្រជុំទិតៀន សុ័យទិតៀន ញឹកញាប់ដែរ តែការទិតៀន សុ័យទិតៀននេះ ច្រើនធ្វើសើៗ លំៗ ឲ្យមានតែរូបភាពប៉ុណ្ណោះ ។ តែមិនក្តៅ មិនស៊ីជម្រៅ ដើម្បីកសាងគោលជំហរនយោបាយសតិអារម្មណ៍ចាត់តាំងបដិវត្តន៍របស់មិត្តយើងទេ ។ ពោល គឺការទិតៀន សុ័យទិតៀនទាំងនេះ មានសភាពត្រជាក់រហឹម មានសភាពជាការរួមរស់វណ្ណៈ ជាការស៊ុមគ្រលុំរវាងគោលជំហរអធនរបស់បក្ស និងគោលជំហរវណ្ណៈជិះជាន់ផ្សេងៗ ដែលមិនបដិវត្តន៍ មិនអធន ។ ការទិតៀន សុ័យទិតៀនបែបនេះ មិនសមស្របនឹងរយៈកាលបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ដែលកំពុងតែផុលផុសខ្លាំងក្លា ក្តៅគគុក ដូចយើងបានឃើញពីខាងលើនោះឡើយ ។

◆ នៅកន្លែងខ្លះ ឬអង្គភាពខ្លះទៀត ការទិតៀន សុ័យទិតៀន មានសភាពខ្លាំងក្លា ក្តៅណាស់ តែក្តៅតែសំបកក្រៅ ។ ពោល គឺខ្លាំងក្តៅ ជាពាក្យសម្តី ជាអាកប្បកិរិយា ទឹកមុខ ទឹកមាត់ ជារបៀបវាយប្រហារគ្នា សម្ងុត គំរាមគ្នា វាយបំបាក់គ្នា តែខាងខ្លឹមសារ គឺមិនជ្រៅ វាយមិនដល់ឬសកែវនៃគោលជំហរនយោបាយសតិអារម្មណ៍ ចាត់តាំងដែលវាពួនសម្ងំ កប់ជ្រៅទៅក្នុងខ្លួនមិត្តយើងម្នាក់ៗ ឡើយ ។ ការទិតៀន សុ័យទិតៀនបែបនេះ ពុំអាចសម្រេចសំណូមពរ កម្ចាត់គុណវិបត្តិ លើកស្ទួយនូវគុណសម្បត្តិរបស់មិត្តយើងម្នាក់ៗ បានឡើយ ។ ផ្ទុយទៅវិញ វាមានតែនាំឲ្យបែកបាក់ ប្រេះឆាដល់សាមគ្គីភាព ៦ កភាពផ្ទៃក្នុងជួរបដិវត្តន៍យើងតែប៉ុណ្ណោះ ។

◆ នៅកន្លែងខ្លះទៀត មានការទិតៀន សុ័យទិតៀនតែចំពោះថ្នាក់ក្រោម តែនៅក្នុងថ្នាក់លើក្មានអនុវត្តការទិតៀន សុ័យទិតៀននេះទាល់តែសោះ ឬក៏មានធ្វើដែរតែលំៗ មិនក្តៅ មិនជ្រៅ ដូចធ្វើចំពោះថ្នាក់ក្រោមទេ ។ល ។

ទាំងអស់នេះ ជាបាតុភាពខុសឆ្គងដែលនៅមានសេសសល់នៅតាមកន្លែងខ្លះ អង្គភាពខ្លះ ចំពោះបញ្ហាទិតៀន សុ័យទិតៀននេះ ។

ក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមបច្ចុប្បន្ននេះ ដែលការតស៊ូវណ្ណៈមានសភាពតឹងតែង ស្មុគស្មាញ និងស្វាប់រស់ជាទីបំផុត ដូចយើងបានឃើញពីខាងដើមស្រាប់ បើក្មានការទិតៀន សុ័យទិតៀនទេ ឬបើធ្វើការទិតៀន សុ័យ

ទិតៀន មិនបានក្តៅជាប់ជានិច្ច មិនបានស៊ីជម្រៅឲ្យដល់ទស្សនៈ គោលជំហរជាមូលដ្ឋានរបស់មិត្តយើងម្នាក់ៗទេ នោះគ្រោះអាសន្ន របបនាយទុន ដើបក្បាលឡើងវិញនៅកម្ពុជា នឹងចោទមានឡើងជាពិតប្រាកដ ។ សើរើនិយម ក៏នឹងអាចចោទឡើងចំពោះបដិវត្តន៍កម្ពុជាយើងដែរ ។ ដូច្នេះ ជាគ្រោះមហន្តរាយធំណាស់ចំពោះចលនាបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជារបស់យើង ក៏ដូចចំពោះប្រទេសជាតិយើងទាំងមូល ហើយនិងចំពោះបុគ្គលយុវជន យុវនារីយើងម្នាក់ៗដែរ ។ ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើងចាំបាច់ ត្រូវបំផុសចលនាទិតៀន ស៊ូយទិតៀន នៅក្នុងអង្គភាពយើងនីមួយៗ នៅក្នុងជួរយុវជន យុវនារីយើងទាំងមូល ក៏ដូចជានៅក្នុងជួរបដិវត្តន៍យើងទាំងមូលដែរ ឲ្យបានខ្លាំងក្លាបំផុត ក្តៅបំផុត ជ្រាលជ្រៅបំផុត ។ ខ្លាំងក្លានេះ ក្តៅនេះ ជ្រៅនេះ គឺសំដៅខាងទស្សនៈ គោលជំហរ ខាងខ្លឹមសារ តែមិនមែនក្តៅខ្លាំង មុតខាងពាក្យសំដី អាកប្បកិរិយា ឬទឹកមុខ ទឹកមាត់ឡើយ ។ ឯវិធីគឺត្រូវទន់ភ្ញន់ រាបសា ហើយឈរដាច់ខាតលើគោលការណ៍ និងលាក់ការណ៍ទិតៀន ស៊ូយទិតៀនរបស់បក្ស ។

ដើម្បីបំផុសចលនាទិតៀន ស៊ូយទិតៀន ឲ្យបានខ្លាំងក្លា និងជ្រាលជ្រៅនៅក្នុងជួរយុវជន យុវនារីបដិវត្តន៍យើង ក៏ដូចក្នុងជួរបដិវត្តន៍យើងទាំងមូលដែរ យុវជនយុវនារីបដិវត្តន៍យើងចាំបាច់ត្រូវ :

១) អនុវត្តការទិតៀន ស៊ូយទិតៀន តាមការប្រជុំជីវភាពការងារក្តី តាមការប្រជុំស៊ីជម្រៅក្នុងអង្គភាពនីមួយៗក្តី តាមការប្រជុំជីវភាពក្រុមយុវកកក្តី តាមការធ្វើជីវទស្សនបដិវត្តន៍ក្តី ឲ្យបានញឹកញាប់ ទៀងទាត់ និងហ្មត់ចត់ជានិច្ច ។

២) រៀនសូត្រឲ្យជ្រួតជ្រាបនូវគោលការណ៍ លាក់ការណ៍ និងវិធីធ្វើការទិតៀន ស៊ូយទិតៀនរបស់បក្ស ។

៣) រៀនសូត្រ និងក្តាប់ឲ្យជាប់នូវខ្លឹមសារដែលត្រូវពាក់ព័ន្ធធ្វើការទិតៀន ស៊ូយទិតៀន របស់បក្ស ដើម្បីពាក់ព័ន្ធស៊ូយទិតៀនរបស់ខ្លួនឯង ក៏ដូចត្រួតពិនិត្យជួយទិតៀនកសាងសមមិត្តដទៃឲ្យបានចំណុចគោលជំហរ នយោបាយសតិអារម្មណ៍ និងចាត់តាំងជាមូលដ្ឋានដែលបក្សលើកឡើង ។

៤) បើនៅកន្លែងណា ឬអង្គការណា គ្មានប្រជុំទិតៀន ស៊ូយទិតៀនឲ្យបានទៀងទាត់ ហ្មត់ចត់ តាមកាលកំណត់ទេ យុវជនយុវនារីបដិវត្តន៍យើង ត្រូវតស៊ូទាមទារឲ្យមានការអនុវត្តការទិតៀន ស៊ូយទិតៀនឲ្យបានទៀងទាត់តាមការកំណត់របស់បក្ស ។

៥) ឈរលើគោលការណ៍ លាក់ការណ៍ទិតៀន ស៊ូយទិតៀនរបស់បក្ស យុវជន យុវនារីបដិវត្តន៍ យើងត្រូវអង់អាចក្លាហាន ហ៊ានធ្វើស៊ូយទិតៀន ត្រួតពិនិត្យខ្លួនឯងឲ្យបានស៊ីជម្រៅ និងស្មោះត្រង់ ហើយក៏អង់អាចក្លាហាន ហ៊ានទិតៀនមិត្តដទៃ ទោះថ្នាក់លើក្តី ថ្នាក់ស្មើក្តី ថ្នាក់ក្រោមក្តី ដោយស្មោះស្ម័គ្រ និងដោយគោលជំហរទទួលខុសត្រូវកសាងពង្រឹងជួរបក្ស ជួរបដិវត្តន៍ ជួរយុវជនយុវនារីបដិវត្តន៍ និងអង្គភាពយើងនីមួយៗ ឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាជានិច្ច ដើម្បីធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាសម្រេចជោគជ័យដាច់ខាត ។

ទាល់តែបំផុស ចលនាទិតៀន ស៊ូយទិតៀន បានខ្លាំងក្លា ជ្រាលជ្រៅ និងធំទូលាយ នៅតាមគ្រប់អង្គភាព គ្រប់មន្ទីរ ក្រសួង គ្រប់មូលដ្ឋាន និងគ្រប់ថ្នាក់ ក្នុងជួរបដិវត្តន៍យើង បក្សយើងទាំងមូលយ៉ាងនេះ ទើបធានាដល់ចលនាបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម នៅកម្ពុជាបច្ចុប្បន្ន ក៏ដូចតទៅអនាគតទៀត ។ ដូច្នេះ ការអនុវត្តទិតៀន ស៊ូយទិតៀនឲ្យបានខ្លាំងក្លាជ្រាលជ្រៅ ទៀងទាត់ និងហ្មត់ចត់ជានិច្ច ជាការកិច្ចសំខាន់បំផុតរបស់យុវជន យុវនារីបដិវត្តន៍យើងគ្រប់រូប ក៏ដូចជារបស់ជនបដិវត្តន៍គ្រប់រូប ដើម្បីសម្រេចបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាឲ្យបានជោគជ័យទាំងស្រុង និងជាស្ថាពរ ។

ទាវ សារៈមុនិន្ទ

អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាម: *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* . ព័ត៌មានបន្ថែម សូមទាក់ទង ញ្ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

ហ៊ីង សុខុម : និស្សិតថ្នាក់ម៉ាស្ទ័រ ផ្នែកសេដ្ឋកិច្ច នៅសាកល វិទ្យាល័យមីកណែល និង ញូវយ៉ក ទាប់ឃុំឃាំងនៅមន្ទីរស-២១

ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៥៨៩៩៨

ហ៊ីង សុខុម ជានិស្សិតរៀនថ្នាក់ម៉ាស្ទ័រផ្នែកសេដ្ឋកិច្ច នៅអាមេរិក ។ សុខុម បានចាកចេញពីប្រទេសកម្ពុជា នៅខែមិថុនា ឆ្នាំ១៩៥៨ ហើយបានត្រឡប់មកប្រទេសកម្ពុជាវិញនៅខែមិថុនា ឆ្នាំ១៩៧៦ ក្រោយពេលរបបខ្មែរក្រហមទទួលជ័យជម្នះ ។ សុខុម ត្រូវអង្គការចាប់ខ្លួននៅខែកញ្ញា ឆ្នាំ១៩៧៦ និងត្រូវបានវាយសួរចម្លើយជាច្រើនលើកដោយឈ្មោះ ប៊ិន នៅមន្ទីរសន្តិសុខស-២១ ។

ខាងក្រោមនេះ ជាការដកស្រង់ចេញពីចម្លើយសារភាពរបស់ សុខុម ដ្ឋាល់ :

១) ឪពុកម្តាយ និងបួន

ក) អំពីឪពុកម្តាយ : ឪពុកខ្ញុំឈ្មោះ ហ៊ីង ខាន់ កើតនៅឃុំអរិយក្សត្រ ។ កាត់ធ្វើមេឃុំនៅបាណាម (ពាមរក៍) ក្នុងខេត្តព្រៃវែង ក្នុងឆ្នាំ១៩៤៥ ។ កាត់ស្លាប់នៅក្នុងឆ្នាំ១៩៤៩ ។ ម្តាយខ្ញុំឈ្មោះ រស់ សាត កើតនៅព្រែកថោង ស្លាប់នៅឆ្នាំ១៩៧៣ ។

ខ) អំពីបងបួនបង្កើត : ខ្ញុំមានបងបួន៥នាក់ បងស្រីម្នាក់ និងប្រុសបួននាក់ :

◆ បងស្រីខ្ញុំឈ្មោះ ខាន់ ស៊ីមជីន មានប្តីឈ្មោះ ឃ្លូ ជាតធ្វើគ្រូបង្រៀន ។ ក្រោយមក ធ្វើការនៅក្រសួងសិក្សាធិការជាតិ

ក្រែសម្រាប់អ្នកទោសនៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង

នាក្រុងភ្នំពេញ ។ គាត់នៅរស់ជាមួយគ្រួសារ ។

◆ ប្អូនប្រុសខ្ញុំបន្ទាប់ឈ្មោះ ហ៊ីង សុឃឿន ធ្វើការនៅសាកលវិទ្យាល័យបច្ចេកទេស មិត្តភាព ខ្មែរ-សូវៀត នាក្រុងភ្នំពេញ ។ គាត់នៅរស់ជាមួយគ្រួសារ ។

◆ ប្អូនប្រុសខ្ញុំម្នាក់ទៀតឈ្មោះ ហ៊ីង សំអឿន ធ្វើការនៅធនាគារជាតិ នាក្រុងភ្នំពេញ ។ គាត់នៅរស់ជាមួយគ្រួសារ ។

◆ ប្អូនប្រុសពៅឈ្មោះ ហ៊ីង សម្ផត្តិ ស្លាប់ហើយ ។

ក) អំពីមា មីងទាងម្តាយ

◆ មាខ្ញុំម្នាក់ឈ្មោះ រស់ ឆន ធ្វើការនៅប៉ុស្តិ៍ខ្សែលួស នៅភ្នំពេញ ។ គាត់រស់នៅជាមួយគ្រួសារ ។

◆ មាខ្ញុំម្នាក់ទៀតឈ្មោះ រស់ ម៉ន ធ្វើការនៅក្នុងមន្ទីរមួយក្នុងក្រសួងសិក្សាជាតិ នៅភ្នំពេញ ។ គាត់រស់នៅជាមួយគ្រួសារ ។

◆ មាម្នាក់ទៀតឈ្មោះ រស់ ដុន ធ្វើពេទ្យទាហាន ពាក់ដោយ ។

ខ) អំពីមា មីងទាងឪពុក

◆ អ៊ីខ្ញុំឈ្មោះ ហ៊ីង ទាត់ ធ្វើចៅហ្វាយស្រុក ។ ក្រោយមកធ្វើតំណាងរាស្ត្រ (ស្លាប់) ។

◆ ពូខ្ញុំម្នាក់ទៀតឈ្មោះ ហ៊ីង ដាន់ ពីដើមធ្វើមេឃុំ នៅអរិយក្សត្រ (នៅរស់) ។

គ) អំពីបងប្អូនជីដូនមួយទាងម្តាយ

◆ ប្អូនស្រីជីដូនមួយឈ្មោះ រស់ សំបូរ ធ្វើគ្រូបង្រៀននៅភ្នំពេញ ។ គាត់នៅរស់ជាមួយគ្រួសារ ។

ឃ) អំពីបងប្អូនជីដូនមួយទាងឪពុក

◆ បងជីដូនមួយខ្ញុំម្នាក់ឈ្មោះ ហ៊ីង សុខុន ធ្វើចៅហ្វាយខេត្តនៅកំពង់ស្ពឺ ហើយក្រោយមក ធ្វើចៅហ្វាយក្រុងព្រះសីហនុវិញ ។ គាត់រស់នៅជាមួយគ្រួសារ ។

◆ បងជីដូនមួយខ្ញុំម្នាក់ទៀតឈ្មោះ ហ៊ីង ទាំ២ន ធ្វើទាហានដើងគោក ឆ្នាំ១៩៥៨ ។ គាត់ពាក់ស័ក្តិមួយ មិនដឹងនៅរស់ ឬស្លាប់ទេ ។

២) អំពីផ្លាស់ខ្លួន

ក) ការសិក្សានៅក្នុងប្រទេស

◆ ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤២ ខ្ញុំនៅជាមួយជីដូនជីតាខ្ញុំ ឯព្រៃកថោង និងបានចូលរៀននៅសាលាបឋមសិក្សាព្រៃកលួង ស្រុកឧម្ពាច់កណ្តាល ខេត្តកណ្តាល ។

◆ ពីឆ្នាំ១៩៤៨-៤៩ ខ្ញុំនៅជាមួយបងថ្លៃខ្ញុំឈ្មោះ ឃ្ជ ជាត ធ្វើចាងហ្វាងសាលាបឋមសិក្សាកំពង់កន្ទ្ធត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឆ្នាំនោះ ខ្ញុំប្រលងយកសញ្ញាបត្របឋមសិក្សាជាប់ ។

◆ ឆ្នាំ១៩៤៩-៥០ ខ្ញុំចូលរៀននៅថ្នាក់ទី៦ទំនើប នៅវិទ្យាល័យស៊ីសុវត្ថិ ។ ឆ្នាំនោះការរៀនរបស់ខ្ញុំក្រោមការណែនាំរបស់គ្រូបារាំងម្នាក់ឈ្មោះ ចាតូលី និងគ្រូខ្មែរម្នាក់ឈ្មោះ ហុន ហៀង ឌឿង ។ គ្រូទាំងពីរនាក់នេះ មានទិន្នាការនយោបាយ ។ នៅពេលនោះដែរ ខ្ញុំក៏បានស្គាល់សិស្សម្នាក់ឈ្មោះ ផៃ ឌីស៊ីថា និងបានដើរលេងជាមួយគ្នាជាញឹកញាប់ ។ ឈ្មោះនេះ ជាកូនរបស់ផៃ ធុល ដែលមានទិន្នាការនយោបាយដែរ ។ ក្រៅពីនោះ ខ្ញុំស្គាល់សិស្សម្នាក់ទៀតឈ្មោះ ប៉ាល់ សំឡ ដែលមានឪពុកធ្វើជាចៅហ្វាយស្រុក ។

◆ ពីឆ្នាំ១៩៥៣-៥៤ ខ្ញុំប្រលងឌីប្លូមជាប់ ។ ពេលនោះខ្ញុំមានគ្រូបារាំងម្នាក់ឈ្មោះ ព្រ ចុស ដែលបង្រៀនខ្ញុំឲ្យចូលចិត្តបារាំង ស្រុកបារាំង និងអរិយធម៌បារាំង ។ ខ្ញុំមានគ្រូបារាំងប្រុសម្នាក់ទៀតឈ្មោះ កាសស្ពែក បង្រៀនភាសាអង់គ្លេស និងគ្រូឈ្មោះ រ៉ូ ស៊ាន់ ប៊ែរ បង្រៀនប្រវត្តិសាស្ត្រ ។ គ្រូទាំងបីបង្រៀនខ្ញុំឲ្យស្រឡាញ់របៀបរស់នៅក្នុងសង្គមមូលធន ដែលមានទិន្នាការនយោបាយអាណានិគម ហើយចង់ឲ្យខ្ញុំទៅរៀននៅស្រុកបារាំងដើម្បីបម្រើវា ។

នៅឆ្នាំនោះ ខ្ញុំចូលចិត្តដើរលេងជាមួយមិត្តជាកូនអ្នកមានមានឈ្មោះ សាន រ៉ាយម៉ូ ជាកូន សាន យុន ធ្វើជានាម៉ឺនធំនៅក្នុងវ៉ាំង ។ មិត្តម្នាក់ទៀតដែលខ្ញុំខសម្ងាត់ដើរលេងជាមួយដែរឈ្មោះ សោម សារ៉ា ជាប្អូនរបស់ ដួង សំអាន ឆ្លាប់ធ្វើជារដ្ឋមន្ត្រី ។ ក្រៅពីនោះ ខ្ញុំដើរលេងជាមួយ ទេព ដាន់ដារ និង ទេព ដល្ងី ជាកូនរបស់ទេព ផន ជានាម៉ឺនធំមួយនៅពេលនោះ ។

◆ ពីឆ្នាំ១៩៥៥-៥៦ ខ្ញុំប្រឡងជាប់ចាសូទី១ (មធ្យមសិក្សាបត្រកាតទី១ ឬបាក់អង) ។ ឆ្នាំនោះ ខ្ញុំរៀនជាមួយអ្នកគ្រូ ព្រ ចុស ដដែល ដែលបង្រៀនអក្សរសាស្ត្របារាំង និងអរិយធម៌

ជារាំង។ គាត់ជានហ្គីកហ្ជីនខ្ញុំឲ្យស្រឡាញ់ភាសាជារាំង។ ត្រូវ៉ូ ស៊ាន់ បែរ បង្ក្រៀនភូមិសាស្ត្រ និងប្រវត្តិសាស្ត្រប្រទេសអឺរ៉ុប និងស្រុកអាមេរិក។ នៅពេលខ្ញុំសុំអាហារូបករណ៍ទៅរៀននៅស្រុកអាមេរិក គាត់ជានសរសេរសំបុត្រតាំទ្រខ្ញុំថា ជាសិស្សល្អ ហើយមានប្រាជ្ញា ដើម្បីទៅកាន់ការិយាល័យអាហារូបករណ៍នៅទូតអាមេរិក។ គាត់យកចិត្តទុកដាក់ខ្ញុំណាស់ ជួបខ្ញុំនៅកន្លែងណា ក៏គាត់ឈប់សួរសុខទុក្ខខ្ញុំដែរ។ ឆ្នាំនោះខ្ញុំនៅផ្ទះ ឌិក ហ្ជីង ដែលជាអ្នកទទួលខុសត្រូវខាងទិញដូរ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ។

◆ ឆ្នាំ១៩៥៦-៥៧ ខ្ញុំរៀននៅថ្នាក់ទីបញ្ចប់ខាងផ្នែកវិទ្យាសាស្ត្រពិសោធន៍។ ខ្ញុំមានមិត្តពីរនាក់ ឈ្មោះ អ៊ុនជា និង អ៊ុន សូដាន់ ដែលមានឪពុកធ្វើចៅហ្វាយខេត្តក្រចេះ។ ចំណែកគ្រូបង្ក្រៀនសំខាន់ជាងគេ ឈ្មោះ ឡា ម៉ើសូ ជាជនជាតិយួនកាតូលិក តែមានអាកប្បកិរិយាដូចជារាំង។ គាត់បង្ក្រៀនមុខវិជ្ជាមនោគមវិជ្ជា ប្រតិកិរិយា។ គាត់បង្ក្រៀនខ្ញុំឲ្យចូលចិត្តគំនិតនិយម ហើយសេរីក្នុងការគិត។

◆ នៅចុងឆ្នាំ១៩៥៧ និងដើមឆ្នាំ១៩៥៨ ខ្ញុំសុំចេញទៅបង្ក្រៀននៅអនុវិទ្យាល័យកម្ពុជបុត្រ។ ខ្ញុំបង្ក្រៀនបានប្រហែលជាពីរខែក៏ត្រូវឈប់ ព្រោះខ្ញុំត្រូវរៀនភាសាអង់គ្លេសដើម្បីរៀបចំទៅរៀននៅអាមេរិក។

១) ដំណើរចាកចេញទៅអាមេរិក

ចាប់ពីដើមឆ្នាំ១៩៥៨ រហូតដល់ខ្ញុំចាកចេញពីប្រទេសកម្ពុជាទៅស្រុកអាមេរិក ខ្ញុំបានទទួលការហ្គីកហ្ជីនច្រើនពីជនជាតិអាមេរិកាំងធ្វើការនៅទូត។ ខ្ញុំរៀនភាសាអង់គ្លេស ក្រោមការណែនាំរបស់អ្នកគ្រូស្រីម្នាក់ឈ្មោះ យ៉ូតូ ដើម្បីឲ្យខ្ញុំស្គាល់ពីការរស់នៅស្រុកអាមេរិក។ គាត់បានបញ្ជាំងខ្សែភាពយន្តស្តីពីការរស់នៅស្រុកអាមេរិក តាំងពីការរស់នៅរបស់និស្សិត និងសិស្ស វិទ្យាល័យ ការរៀនសូត្រ ការកម្សាន្ត ហើយទូតអាមេរិកក៏បានរៀបចំឲ្យគ្រួសារអាមេរិកាំងហៅខ្ញុំទៅហូបបាយយ៉ាងហោចណាស់មួយអាទិត្យពីរដងដែរ។

ដល់ដិតដាច់ខែមិថុនា ឆ្នាំ១៩៥៨ ខ្ញុំនិងសិស្សឯទៀតបានដិះយន្តហោះពីពោធិ៍ចិនតុងឆ្ពោះទៅបាងកក។ មុននឹងចាកចេញ ជនជាតិអាមេរិកាំងបានចែកលុយដុល្លារឲ្យខ្ញុំ និងសិស្សឯទៀតដោយម្នាក់ៗទទួលបានប្រាក់ប្រហែល១០០ដុល្លារ ដើម្បីចាយក្នុងការធ្វើដំណើរនេះ។

ពេលខ្ញុំទៅដល់រ៉ាស៊ីនតោន នៅក្នុងខែកក្កដា ឆ្នាំ១៩៥៨ អាមេរិកាំងបានអប់រំខ្ញុំដូចនៅភ្នំពេញដែរ។ គ្រួសារអាមេរិកាំងតែងហៅខ្ញុំដិះឡានដើរកម្សាន្តជាមួយ ហើយនៅពេលល្ងាចថ្ងៃសុក្រ ឬថ្ងៃសៅរ៍ គ្រួសារអាមេរិកាំងបានហៅខ្ញុំទៅហូបបាយជាមួយ ជួនកាលមានរាំដង។ គ្រួសារនោះបានប្រាប់ថា ឲ្យខ្ញុំសប្បាយចិត្តកុំឲ្យខ្ញុំនឹកផ្ទះ។ ពេលនោះខ្ញុំមិនសូវនឹកនាម្តាយ ឬបងប្អូនខ្ញុំទេ។

២) ការសិក្សានៅសាកលវិទ្យាល័យ ប៊ីកណែល

◆ ពីខែសីហា ដល់ខែកញ្ញា ឆ្នាំ១៩៥៨ ខ្ញុំត្រូវទៅរៀននៅសាកលវិទ្យាល័យ ប៊ីកណែល (Bucknell University) រដ្ឋភិនស៊ីលវីជីញ៉ា (Pencil Virginia)។ ខ្ញុំមិនបានជ្រើសរើសសកលវិទ្យាល័យដែលខ្ញុំត្រូវទៅរៀនទេ គឺអាមេរិកាំងរើសឲ្យ។ នៅពេលរៀន ខ្ញុំទទួលបានប្រាក់ខបត្តម្ភប្រចាំខែ១៦០ដុល្លារ ដើម្បីបង់ថ្លៃបន្ទប់ និងបាយ និងចាយវាយក្រៅ។ ថែមលើនោះ អាមេរិកឲ្យប្រាក់ទិញសៀវភៅទៀត។ ពេលខ្ញុំរៀននៅសាលានោះ សមាគមសាសនាគ្រិស្តជាង បានយកចិត្តទុកដាក់អប់រំដល់និស្សិតបរទេសណាស់។ សមាគមនោះស្ថិតនៅគ្រឹះស្ថានមួយល្អស្អាត ទូលាយ ហើយមានកន្លែងអង្គុយជជែកគ្នាលេង និងកន្លែងប្រជុំ។ សមាគមនោះ បានហៅខ្ញុំឲ្យទៅចូលរួមដឹកតែក្នុងមួយអាទិត្យម្តង ដើម្បីឲ្យខ្ញុំស្គាល់គេឯង។ នៅពេលសម្រាកពីរៀនម្តងៗ គ្រួសារអាមេរិកាំងបានហៅខ្ញុំទៅផ្ទះរបស់គេ ហើយដល់ថ្ងៃអាទិត្យ គ្រួសារនោះបាននាំខ្ញុំទៅព្រះវិហារ ហើយតែងនាំខ្ញុំទៅជួបគេឯងទៀតផង។ ខ្ញុំជួបទាំងសង្ឆរាជព្រះវិហារ។ នៅថ្ងៃរសៀលគ្រួសារនេះត្រឡប់មកផ្ទះ ហូបបាយរសៀល រួចហើយបបួលខ្ញុំដិះឡានទៅមើលទេសភាពជនបទ ហើយពេលល្ងាចធ្វើពិធីពិចនិចនៅជាប់ព្រៃក ឬព្រៃ។

◆ ឆ្នាំ១៩៦២ ខ្ញុំទទួលសញ្ញាបត្រ បាក់ហ្ស៊ីលរ៍ (Bachelor) ខាងនយោបាយ និងសេដ្ឋកិច្ច។ នៅពេលនោះ ចាងហ្វាងសមាគមសាសនាគ្រិស្តជាង ឈ្មោះ ជុស្ស៊ូ ប្រ្ចាន បានមកជួបខ្ញុំដោយរីករាយបំផុត ហើយប្រាប់ខ្ញុំថាគួរតែត្រឡប់មកកម្ពុជាវិញហើយព្រោះវិជ្ជាខ្ញុំប៉ុណ្ណោះលួមធ្វើការបានហើយ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំចង់រៀនតទៅទៀត ហើយបានសុំបន្តអាហារូបករណ៍ទៀត។

◆ ឆ្នាំ១៩៦៣ ខ្ញុំបន្តរៀនសូត្រទៀត ហើយដល់ខែសីហា ខ្ញុំបានរៀនចប់ហើយទទួលសញ្ញាបត្រម៉ាស្ទ័រ ខាងសេដ្ឋកិច្ច ។

ឃ) ការសិក្សាបន្តនៅសាកលវិទ្យាល័យញូវយ៉ក

ខ្ញុំរៀបចំត្រឡប់មកកម្ពុជាវិញ ហើយដល់ខែតុលា ខ្ញុំបានមកដល់ប៉ារីស ព្រោះសភាពការណ៍នៅក្រុងភ្នំពេញពេលនោះមិនស្រួល ។ ខ្ញុំឮថា លន់ នល់ រៀបចំធ្វើរដ្ឋប្រហារ ។ ខ្ញុំបានជួបនិស្សិតខ្មែរច្រើន ដែលឥឡូវនេះនៅក្នុងជួរបដិវត្តន៍ ។

◆ ឆ្នាំ១៩៦៤ ខ្ញុំបានសម្រេចចិត្តត្រឡប់មកអាមេរិកវិញ ព្រោះការរស់នៅប៉ារីសពិបាកពេករកធ្វើការមិនបាន ។ ខ្ញុំមកដល់ញូវយ៉ក្នុងខែមករា ឆ្នាំ១៩៦៤ ហើយខ្ញុំបានចូលរៀនបន្តនៅសាកលវិទ្យាល័យញូវយ៉ក ផ្នែកសេដ្ឋកិច្ច ព្រោះខ្ញុំសុំអាហារូបករណ៍ពីគ្រឹះស្ថានអាស៊ីបាន ។

◆ ឆ្នាំ១៩៦៥ ខ្ញុំការប្រពន្ធ ជាជនជាតិហ្ស៊ីលីពីនឈ្មោះ ក្រីស្ទីន ប៉ាតូរ ។ នៅពេលខ្ញុំរៀននៅសាកលវិទ្យាល័យញូវយ៉ក មានសាស្ត្រាចារ្យមួយចំនួនបង្ក្រៀនខ្ញុំឲ្យចូលចិត្តនយោបាយសេដ្ឋកិច្ចតាមទ្រឹស្តីមូលធននិយមឲ្យខ្ញុំជឿជាក់លើកម្ចាំងសម្ភារ ។

ង) ចូលរណសិរ្ស

ឆ្នាំ១៩៧០ នៅក្រោយ លន់ នល់ ធ្វើរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មក ខ្ញុំបានសម្រេចចូលរណសិរ្សជាមួយមិត្ត ម៉ុក សូរ៉ុត និងមិត្ត អ៊ុក ឈន តាមរយៈបង ឌិក សាគុន និងបងជួន ម៉ុ នៅប៉ារីស ។ នៅពេលនេះ ខ្មែរនៅញូវយ៉កបានសម្រេចបើកក្រុមមួយហៅថា «ក្រុមខេមរជាតិ នៅស្រុកអាមេរិក» ។ រណសិរ្សបានឲ្យខ្ញុំធ្វើជាតំណាងក្រុមនេះ ដើម្បីធ្វើការទាក់ទងជនជាតិអាមេរិកាំងដែលជឿជាក់លើសន្តិភាព និងយុត្តិធម៌ ហើយមានចិត្តគាំទ្រដល់ការតស៊ូរបស់ប្រជាជនកម្ពុជា ។ ភារកិច្ចស្នូលរបស់ខ្ញុំនៅពេលនោះ តាមការណែនាំរបស់រណសិរ្ស គឺត្រូវធ្វើការយោសនាក្នុងក្របខណ្ឌនយោបាយរបស់រណសិរ្ស គឺថាខ្ញុំត្រូវចុចនៅលើចំណុច សន្តិភាព អព្យាក្រិត ឯករាជ្យ និងប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។ ក្នុងពេលនេះ «ក្រុមខេមរជាតិ នៅស្រុកអាមេរិក» បានទទួលប្រាក់ខ្ចីពីរណសិរ្សនៅប៉ារីស ជួនកាលទទួលបាន១៥០ដុល្លារ ជួនកាល១០០ ដុល្លារ ក្នុងមួយខែ ដែលផ្ញើមកខ្ញុំតាមមិត្តអាមេរិកាំង ។

 អ្នកទោសជាប់ឃុំឃាំងមន្ទីរសន្តិសុខស-២១

នៅពេលនោះ ខ្ញុំបានស្នើរណសិរ្សមកធ្វើការនៅប៉េកាំង ប៉ុន្តែរណសិរ្សបានសម្រេចថា ខ្ញុំត្រូវតែនៅញូវយ៉ក ដើម្បីជួយធ្វើការមិត្តភ័ក្ដ្ធ ព្រោះនៅស្រុកអាមេរិកពុំសូវមានខ្មែរចូលរណសិរ្សទេ ច្រើនតែអ្នកប្រឆាំង ។ ខ្ញុំក៏ព្រមនៅញូវយ៉ក រហូតមកតាមការណែនាំរបស់រណសិរ្ស ។

ពេលនោះ ខ្ញុំបានទទួលពីបេសកកម្មនៅប៉ារីស នូវឈ្មោះ និងអាសយដ្ឋានជនជាតិអាមេរិកាំងជាច្រើននាក់ ដែលគាំទ្រការតស៊ូរបស់ប្រជាជនកម្ពុជា ហើយចង់ទាក់ទង «ក្រុមខេមរជាតិ នៅស្រុកអាមេរិក» ។ ដល់បានឈ្មោះ និងអាសយដ្ឋានរួចហើយ ខ្ញុំចាប់សរសេរទៅអ្នកទាំងនោះ ហើយផ្ញើឯកសារដែលក្រុមខ្ញុំទទួលបានពីប៉ារីស និងប៉េកាំង ។ ដោយសារមានការទាក់ទងនេះហើយ ទើបខ្ញុំត្រូវបានហៅឲ្យទៅនិយាយអំពីប្រទេសកម្ពុជាប្រាប់ដល់អ្នកទាំងនោះ ។ ក្នុងឋានៈជាសមាជិកនៃរណសិរ្ស ខ្ញុំបានបំពេញការកិច្ចដោយស្មោះត្រង់បំផុត តាំងពីឆ្នាំ១៩៧០ ដល់ដើមឆ្នាំ១៩៧៥ ។

៥) ការទាក់ទងជាមួយ សេ.អ៊ី.អា

ដល់ឆ្នាំ១៩៧៥ ខ្ញុំចាប់ផ្ដើមមានទំនាស់ជាមួយអង្គការបដិវត្តន៍ ព្រោះខ្ញុំយល់ថា តាមមាត៌ានយោបាយរបស់អង្គការបដិវត្តន៍ ប្រទេសយើងកសាងសង្គមនិយមរហ័សពេក ។ ប្រទេសយើងពុំទាន់មានមូលដ្ឋានឲ្យរឹងប៉ឹងទេ ទាំងផ្នែកសេដ្ឋកិច្ច នយោបាយ និងមនោគមវិជ្ជាប្រជាជន ។

ក្នុងខែមករា ឆ្នាំ១៩៧៥ ខ្ញុំបានចូល សេ.អ៊ី.អា តាមរយៈ ដុន លុស និងអ្នកស្រី ក្ងាំ ង៉ៃ នៅការិយាល័យញូវយ៉ក ។ លេខរៀងរបស់ខ្ញុំគឺ ស-ស ៥២៣-១៨-១០០០៩ ហើយខ្ញុំទទួលប្រាក់១.០០០ដុល្លារក្នុងមួយខែ ។ ការកិច្ចស្នូលរបស់ខ្ញុំ គឺធ្វើសកម្មភាពដើម្បីបំផុសបំដុលគំនិតសើរើនិយម ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានទទួលការហ៊ឹកហ៊ឺនពី ដុន លុស និងអ្នកស្រី ក្ងាំ ង៉ៃ ដើម្បីធ្វើឲ្យខ្ញុំជឿជាក់លើទ្រឹស្ដីនេះ ។ ឈ្មោះ ដុន លុស និង ក្ងាំ ង៉ៃ ខសត្យាហ៍ហៅខ្ញុំទៅហូបបាយជាមួយ ហើយនិយាយពីសភាពការណ៍ទូទៅនៅក្នុងសាកលលោក និយាយអំពីប្រទេសកម្ពុជា ដោយពោលថា ជាប្រសើរណាស់ បើប្រទេសកម្ពុជាវិវត្តទៅតាមលំនាំប្រទេសយូហ្គោស្លាវី ហើយបាននិយាយអំពីការកសាងប្រទេសដោយពឹងផ្អែកទៅលើខសត្យាហកម្ម ។ ដើម្បីធ្វើឲ្យខសត្យាហកម្មបានលូតលាស់តាមសមស្រប ប្រទេសកម្ពុជាត្រូវការទុនដើម្បីសង់រោងចក្រ ។ ចំពោះ ដុន លុស និង ក្ងាំ ង៉ៃ ទុនអាចបានមកពីបរទេសតាមរយៈជំនួយបរទេសក្ដី តាមខ្ចីពីធនាគារអន្តរជាតិ ឬតាមបើកឲ្យក្រុមហ៊ុនបរទេសមកដំឡើងរោងចក្រក្នុងប្រទេស ។

ខ្ញុំមិនទទួលទាំងស្រុងទេ នូវគំនិតរបស់ឈ្មោះ ដុន លុស និងអ្នកស្រី ក្ងាំ ង៉ៃ ជាពិសេសក្នុងរឿងកសាងប្រទេស ។ តាមមតិខ្ញុំ ការកសាងសង្គមនិយមនៅប្រទេសកម្ពុជាលឿនពេក ជាពិសេសក្នុងការបំបាត់ទីផ្សារលក់ដូរ បំបាត់ការប្រើលុយ និងបំបាត់នូវកម្មសិទ្ធិឯកជនខាងដី ទោះជាដីមួយដុំតូចក៏ដោយ ។ គំនិតខ្ញុំពឹងផ្អែកលើការរៀបចំ និងកសាងសង្គមនិយមនៅប្រទេសចិន ។ ខ្ញុំតែងនិយាយប្រាប់ឈ្មោះ ដុន លុស និងអ្នកស្រី ក្ងាំ ង៉ៃ ថា បដិវត្តន៍កម្ពុជាក្នុងពេលនេះត្រូវឆ្លងកាត់ថ្នាក់មួយ ដែលហៅថាថ្នាក់លទ្ធិប្រជាធិបតេយ្យប្រជាជន ។

នៅពេលដែលខ្ញុំជជែកជាមួយ ដុន លុស និងអ្នកស្រី ក្ងាំ ង៉ៃ ខ្ញុំបានប្រាប់អ្នកទាំងពីរនេះថា បដិវត្តន៍កម្ពុជាត្រូវការពេលយូរបន្ដិច ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យប្រជាជនថ្មី ព្រោះប្រទេសកម្ពុជាទើបតែនឹងឆ្លងកាត់សង្គ្រាមមួយដ៏វិនាសកម្ម ។ ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យប្រជាជនថ្មី មានន័យថា ប្រជាជនទាំងអស់ក្នុងប្រទេសត្រូវមានសិទ្ធិក្នុងការចូលរួមចំណែកក្នុងការស្ថាសេដ្ឋកិច្ចជាតិសិន ។ ខ្ញុំយល់ថា ការប្រយុទ្ធខាងផ្នែកមនោគមវិជ្ជា ត្រូវទុកមួយផ្នែកសិន ព្រោះប្រជាជនយើងមិនទាន់ជ្រះស្រឡះក្នុងរឿងនេះ ។ ចំណុចនេះហើយដែលខ្ញុំមានទំនាស់ជាមួយអង្គការបដិវត្តន៍មុនខ្ញុំចូលមកប្រទេសវិញ ។ ចំណុចមួយទៀតដែលខ្ញុំលើកមកនិយាយ គឺចំពោះផ្សារលក់ដូរបន្ដិចបន្ដួច ដោយឯកជនជាពិសេស លក់របស់របរហូប នំបន្ទែ ជាដើម ដែលឯកជនដលិតបាន ។ ចំពោះរឿងនេះ ក៏ខ្ញុំថាគួរឲ្យមានដែរ ហើយចំណុចនេះភ្ជាប់នឹងកម្មសិទ្ធិឯកជនខាងដី ។ នៅពេលនោះខ្ញុំយល់ថា គ្រួសារខ្លះគួរតែឲ្យមានដីមួយដុំ ដើម្បីដាំដំណាំដែលជាជំនួយដល់គ្រួសារ ហើយអាចជាជំនួយដល់រដ្ឋទៀត ។

ក្រៅពីហ៊ឹកហ៊ឺនពីឈ្មោះ ដុន លុស និងអ្នកស្រី ក្ងាំ ង៉ៃ ខ្ញុំបានចូលរៀនទ្រឹស្ដីសើរើនិយមនៅសាលាមួយក្រោមការណែនាំរបស់បក្សកុម្មុយនីស្ដអាមេរិកាំង ។ បក្សនេះបានបង្ក្រៀនខ្ញុំឲ្យស្រឡាញ់

សន្តិភាព ឲ្យដឿជាក់លើវិទ្យាសាស្ត្រដែលប្រទេសសូវៀតបានកសាងក្នុងរយៈពេលដ៏ខ្លី នេះសឲ្យឃើញថា មាត៌ានយោបាយរបស់សូវៀតត្រឹមត្រូវតាមមតិរបស់សាស្ត្រាចារ្យម្នាក់ដែលបង្ក្រៀននៅសាលានោះ ។

៥) ផែនការមុនត្រឡប់ចូលប្រទេស

ដល់ពេលជិតដាច់ឆ្នាំ១៩៧៥ ខ្ញុំបានសម្រេចចិត្តថា នឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ ខ្ញុំបានស្នើទៅគណៈប្រតិភូដែលធ្វើការនៅអង្គការសហប្រជាជាតិ មានសមាជិកបីនាក់ បង ជួន ប្រសិទ្ធ, មិត្ត ឈន ម៉ៃ និងមិត្ត អ៊ុន សូភាព ។

នៅពេលនោះ មានជនជាតិអាមេរិកាំងច្រើននាក់បានមកជួបបង ប្រសិទ្ធ ។ ការជួបជនជាតិអាមេរិកាំងច្រើនធ្វើនៅក្នុងបន្ទប់បង ប្រសិទ្ធ រាល់ថ្ងៃសៅរ៍ ដែលមានមិត្ត ម៉ុក សូវ៉ុត បានចូលរួមជារឿយៗ ។ ពេលនោះឈ្មោះ ដុន លុស មុននឹងមកជួបបង ជួន ប្រសិទ្ធ បានសរសេរលិខិតមួយមកបង ជួន ប្រសិទ្ធ ។ ខ្ញុំមិនបានអានសំបុត្រនោះទេ តែ ដុន លុស បានប្រាប់ខ្ញុំថា គឺរឿងជំនួយពីក្រុមគាត់មកប្រទេសកម្ពុជា ។

នៅពេលជួបបង ជួន ប្រសិទ្ធ ដុន លុស បានសួរបង ប្រសិទ្ធ អស់ពេលប្រហែលបួនម៉ោង ។ ចំណុច ដែល ដុន លុស បានសួរមានដូចតទៅ :

១) ចង់ដឹងនូវនយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះជំនួយបរទេស ដោយ បង ជួន ប្រសិទ្ធ បានប្រាប់វិញថា ចាំគាត់មកប្រទេសកម្ពុជាវិញ គាត់នឹងជូនព័ត៌មានចំពោះរឿងនេះដោយក្បោះក្ប្រាយ ហើយគាត់បន្ថែមទៀតថា កម្ពុជាទទួលទាំងអស់នូវជំនួយបរទេស តែឥឡូវនេះ យើងពុំទាន់មានគ្រោងការឲ្យច្បាស់ទេ ។

២) ចង់មកប្រទេសកម្ពុជាប្រជាធិបតេយ្យ ដើម្បីមកធ្វើការទាក់ទងជាមួយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចំពោះរឿងជំនួយដែលក្រុមគាត់ចង់ឲ្យមកប្រទេសកម្ពុជា ។ បង ជួន ប្រសិទ្ធ ក៏បានប្រាប់ថា មិត្តឯងគង់តែបានទៅប្រទេសកម្ពុជាទេ តែឥឡូវនេះ យើងមិនទាន់បានរៀបចំផ្ទះសម្បែងឲ្យបានស្រួលបួលដើម្បីទទួលភ្ញៀវទេ ។ ដុន លុស លើកឡើងថា បើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យទទួលជំនួយពីក្រុមខ្លួន នោះជាជ័យជម្នះមួយ ។ ដុន លុស ប្រាប់ខ្ញុំថា គាត់ខំធ្វើការទាក់ទងបង ជួន ប្រសិទ្ធ ឲ្យតែតែភ្ញាំងភ្ញាទៅត ព្រោះគាត់សង្ឃឹមតែបង ប្រសិទ្ធ មួយទេ ។ ដុន លុស ចាត់ទុកការទទួលជំនួយនេះ ជាជ័យជម្នះរបស់ សេ.អ៊ី.អា ព្រោះគាត់មានសង្ឃឹមធំណាស់ថា នឹងបានមកប្រទេសកម្ពុជា ។

ក្រៅពីនោះ ដុន លុស បាននិយាយពីការទាក់ទងរបស់គាត់ជាមួយបង ជួន ប្រសិទ្ធ ដល់ពេលបង ប្រសិទ្ធ មកភ្នំពេញវិញ ។ ដុន លុស ចង់រកមធ្យោបាយផ្សេងៗ ដើម្បីទទួលព័ត៌មានពីបង ប្រសិទ្ធ និងជូនព័ត៌មានដល់បង ប្រសិទ្ធ ។ ការជួបជុំគ្នាក៏ចប់ត្រឹមនោះ ហើយបង ជួន ប្រសិទ្ធ បានប្រាប់ឈ្មោះ ដុន លុស ថាចាំជួបគ្នាទៀត ។

ក្រោយមក ខ្ញុំបានជួប ដុន លុស ម្តងទៀត ហើយ ដុន លុស បានប្រាប់ខ្ញុំឲ្យខសត្យាប៉ាទាក់ទងមិត្ត ឈន ម៉ៃ និងមិត្ត អ៊ុន សូភាព ឲ្យខ្ញុំខំរៀនសូត្រអំពីនិន្នាការនយោបាយរបស់មិត្តទាំងពីរនេះ ។ ក្រោយពីប្រជុំនោះមក ខ្ញុំក៏បានប្រជុំ «ក្រុមខេមរជាតិ នៅស្រុកអាមេរិក» ដែរ ហើយមិត្ត ម៉ុក សូវ៉ុត និងមិត្តឯទៀតបានឯកភាពគ្នាថា ត្រូវតែខំធ្វើការពង្រឹងចំណងទាក់ទងជាមួយបង ប្រសិទ្ធ ព្រោះគាត់មាននិន្នាការនយោបាយសើរើ ដែលស្របតាមក្រុមនៅញូវយ៉ក ។

នៅឆ្នាំ១៩៧៦ គណៈប្រតិភូខ្មែរបានត្រឡប់មកញូវយ៉កម្តងទៀត ប្រហែលក្នុងខែមេសា ។ ពេលនោះ អ្នកស្រី ក្ងុ ង៉ៃ បានមកជួបបង ជួន ប្រសិទ្ធ តែខ្ញុំមិនបានចូលរួមទេ ។ គណៈប្រតិភូ នៅពេលនោះមានឈ្មោះ : ជួន ប្រសិទ្ធ, ចន្ធ យ៉ាន់ និង សាន ។ អ្នកស្រី ក្ងុ ង៉ៃ ជួបបង ប្រសិទ្ធ តែម្នាក់ឯងនៅក្នុងបន្ទប់របស់គាត់ ហើយខ្ញុំបានឃើញគាត់ទាំងពីរនាក់ដើរតាមផ្លូវឆ្ពោះទៅអង្គការសហប្រជាជាតិ ។ ក្រោយមក ខ្ញុំបានយកសំបុត្របង ប្រសិទ្ធ មួយទៅជូនដល់អ្នកស្រី ក្ងុ ង៉ៃ តាមសេចក្តីស្នើរបស់បង ប្រសិទ្ធ ។ ពេលណាខ្ញុំជួបអ្នកស្រី ក្ងុ ង៉ៃ អ្នកស្រីតែងតែសួរខ្ញុំអំពីបង ប្រសិទ្ធ ថានឹងមកធ្វើការនៅញូវយ៉កពេលណា ព្រោះងាយស្រួលធ្វើការជាមួយគ្នា ។

ក្រោយដែលបានប្រជុំជាមួយគណៈប្រតិភូ ខ្ញុំបានសម្រេចចិត្តថានឹងត្រឡប់មកប្រទេសវិញ ក្នុងខែមិថុនា ឆ្នាំ១៩៧៦ ។ ក្រោយដែលបានសម្រេចហើយ ខ្ញុំបានទៅជួបអ្នកស្រី ក្ងុ ង៉ៃ និងឈ្មោះ ដុន លុស ប្រាប់អ្នកទាំងពីរនូវថ្ងៃដែលខ្ញុំត្រូវចាកចេញ

ពីញូវយ៉ក ។ អ្នកស្រី ក្ងរ៉ា ង៉ៃ បានប្រាប់ខ្ញុំហើយប្រាប់ទៀតថា ខ្ញុំត្រូវតែទៅជួបបង ជួន ប្រសិទ្ធ នៅក្រសួងការបរទេស ហើយគាត់ និងឈ្មោះ ដុន លុស បានណែនាំខ្ញុំឲ្យមកជួបខ្ញុំវិញនៅពេលដែលខ្ញុំបានមកដល់ភ្នំពេញ ហើយធ្វើការនៅក្រសួងការបរទេស ។ ទិសដៅក្នុងការណែនាំនេះ គឺដើម្បីសម្រួលដល់បេសកកម្មដែលខ្ញុំត្រូវបំពេញ ។ បេសកកម្មរបស់ខ្ញុំ គឺមកពង្រីក និងពង្រឹងនូវទ្រឹស្តីសើរើនិយម ។ ដើម្បីបំពេញការកិច្ចនេះ តាមមតិរបស់ ដុន លុស និងអ្នកស្រី ក្ងរ៉ា ង៉ៃ ខ្ញុំត្រូវធ្វើការទាក់ទងមនុស្សមួយចំនួនដែលអ្នកទាំងពីរយល់ថា ជាមនុស្សសំខាន់ៗ រួមមាន : បង ជួន ប្រសិទ្ធ, បង ច័ន្ទ យ៉ាន់, បង ភោគ ឆាយ, បង ច័ន្ទ បូដា, មិត្ត ឈន ហៃ, មិត្ត ម៉ុក ស៊ីវ៉ុង និងមិត្ត អ៊ុន សូភាព ។

តាមការណែនាំរបស់ឈ្មោះ ដុន លុស និងអ្នកស្រី ក្ងរ៉ា ង៉ៃ មនុស្សដែលត្រូវធ្វើការជាមួយខ្ញុំ មានដូចតទៅ : មិត្ត ប៉ែន ថោងអាន, មិត្ត ម៉ុក សូវ៉ុត, មិត្ត ឈឹម ខេត្ត និងមិត្តនារី ទេព បូដា ។ តាមដុន លុស និងអ្នកស្រី ក្ងរ៉ា ង៉ៃ សន្និដ្ឋានមិត្ត ម៉ុក ស៊ីវ៉ុង ធ្វើកម្មាភិបាលនៅតំបន់ព្រះវិហារ ហើយការទាក់ទងជាមួយមិត្តនេះ ត្រូវតែធ្វើតាមមិត្ត ម៉ុក សូវ៉ុត ដែលត្រូវមកដល់ប្រទេសក្នុងខែកញ្ញា ឬខែតុលា ឆ្នាំ១៩៧៦ នេះ ។

តាមមតិរបស់អ្នកទាំងពីរថា ខ្ញុំ, មិត្ត ម៉ុក សូវ៉ុត, បង ជួន ប្រសិទ្ធ និងបង ច័ន្ទ យ៉ាន់ ត្រូវកដជាធ្វើការជាមួយគ្នានៅក្រសួងការបរទេស ហើយមិត្ត អ៊ុន សូភាពក៏ដូច្នោះដែរ ។ ចំពោះមិត្ត ឈន ហៃ ក៏អ្នកទាំងពីរស្មានថា ធ្វើកម្មាភិបាលនៅក្រសួងការបរទេសដែរ ។ ឈ្មោះ ដុន លុស បានសន្និដ្ឋានទៀតថា មិត្ត ភោគ ឆាយ ធ្វើការជាមួយគណៈប្រធានរដ្ឋ រីមិត្ត ច័ន្ទ បូដា ដឹងច្បាស់ថា ធ្វើកម្មាភិបាល ក្នុងមន្ទីរមួយទាក់ទងខាងតុលាការជាតិ នៅភ្នំពេញ ។

មិត្ត ប៉ែន ថោងអាន មានការកិច្ចទាក់ទងឈ្មោះ ង៉ៃ ផែល ជាមួយមិត្ត ឈឹម ខេត្ត រីឯមិត្ត ម៉ុក សូវ៉ុត វិញ ត្រូវទាក់ទងមិត្ត ម៉ុក ស៊ីវ៉ុង ហើយមិត្តនារី ទេព បូដា ត្រូវធ្វើការទាក់ទងមិត្តនារី ប៉ូ ច័ន្ទ ដែលត្រូវជាគ្រួសាររបស់មិត្ត ភ័ន នៅតាឡី ។ មិត្តនារី ទេព បូដា ត្រូវទាក់ទងមិត្តនារី ប៉ូ ច័ន្ទ ព្រោះមិត្តនារី ប៉ូ ច័ន្ទ ជាមិត្តរបស់គ្រួសារឈ្មោះ ចក់ សារឿន ដែលឈ្មោះ ដុន លុស ចង់ឲ្យមកជួប ។

មនុស្សឯទៀតដែលឈ្មោះ ដុន លុស និងអ្នកស្រី ក្ងរ៉ា ង៉ៃ ណែនាំខ្ញុំឲ្យមកជួបគឺមានដូចតទៅ : អ៊ុន សូកាន, ឌិក សាគុន, សារ៉ាន ឆាក, ង៉ៃ ផែល, ពីង សយ, ស្រី រ៉ិទ្ធី, កង ចូរ្យជាតិ និង ខៀវ កុម៉ារ,

តាមមតិរបស់ ដុន លុស អ្នកដែលមានឈ្មោះខាងលើនេះអាចធ្វើសកម្មភាពក្នុងការពង្រឹង និង ពង្រីកនូវគំនិតសើរើនិយម ។ ខ្ញុំត្រូវរៀបចំការទាក់ទងនេះឲ្យបានស្រួល ហើយទីបំផុត បង ជួន ប្រសិទ្ធ និង ច័ន្ទ យ៉ាន់ ទទួលបន្ទុកក្នុងការទាក់ទងទៅប្រទេសក្រៅ ។ នេះជាអំពើក្បត់របស់ខ្ញុំ ចំពោះអង្គការបដិវត្តន៍ និងប្រជាជន កម្មករ កសិករ ។

៣) សំណើទៅគណៈប្រតិភូ

បន្ទាប់មក ខ្ញុំបានស្នើគណៈប្រតិភូម្ចាងទៀត ចំពោះការវិលត្រឡប់មកប្រទេសវិញ ។ បង ប្រសិទ្ធ និងមិត្ត សាន បានឯកភាពគ្នាថា បើខ្ញុំអាចដោះស្រាយរឿងគ្រួសារ ហើយសម្រេចវិលមកប្រទេសវិញ នេះជាការល្អណាស់ ។ ខ្ញុំមកឲ្យអង្គការបដិវត្តន៍លត់ដំនៅក្នុងប្រទេសមួយខែ ឬពីរខែ ខ្ញុំអាចត្រឡប់មកធ្វើការនៅទីក្រុងញូវយ៉កវិញ ព្រោះខ្ញុំនៅញូវយ៉កយូរ ស្គាល់ស្រុកគេដូច្នេះងាយស្រួលធ្វើការ ។ ពេលមកដល់ប៉េកាំង បង ប្រសិទ្ធ បានប្រាប់ខ្ញុំទៀតថា ចាំមកដល់ភ្នំពេញ គាត់នឹងស្នើរឿងខ្ញុំទៅអង្គការ នៅក្រសួងការបរទេស ហើយដល់ពេលធ្វើចិនតុង មុននឹងបែកគ្នាគាត់ក៏បានឲ្យពរខ្ញុំឲ្យបានជ័យជម្នះក្នុងការបំពេញការកិច្ច ។

៤) នៅភូមិតាឡី

ឥឡូវនេះ ខ្ញុំបានមកដល់ប្រទេសកម្ពុជាបានប្រហែល ៨ខែហើយ ហើយខ្ញុំគ្មានបានបំពេញការកិច្ចបន្ទិចបន្ទួចសោះ ដោយខ្ញុំភ្ជាប់សកាពការណ៍ក្នុងប្រទេសមិនបាន នៅមុនខ្ញុំចូលមកប្រទេសវិញ ។ គោលបំណងផ្ទាល់ខ្លួនរបស់ខ្ញុំ ក៏មិនបានសម្រេចតាមការសន្យារបស់បង ប្រសិទ្ធ ថា ខ្ញុំត្រូវត្រឡប់ទៅធ្វើការនៅញូវយ៉ក ក្រោយដែលបានលត់ដំក្នុងរយៈមួយឬពីរខែដែរ ។ ដោយសារមានការអាក់រអួលនេះហើយ បានជានៅក្នុងប៉ុន្មានអាទិត្យមុនខ្ញុំមកនេះ សតិអារម្មណ៍របស់ខ្ញុំមិនធ្ងន់ទេ ដោយមនោសញ្ចេតនាចំពោះគ្រួសារកាន់តែខ្លាំងឡើង ធ្វើឲ្យខ្ញុំចូលចិត្តនិយាយជាមួយមិត្តឯទៀត ដូចជា មិត្ត សោ ភ័ន, មិត្ត ឈឹម ខេត្ត, មិត្ត ប៉ែន ថោងអាន, មិត្តនារី ប៉ូ ច័ន្ទ នៅភូមិតាឡី នូវរឿងរ៉ាវដែលទុកជាក្បត់អង្គការបដិវត្តន៍ ។

រឿងដែលខ្ញុំ និងមិត្តឯទៀតឧស្សាហ៍និយាយ គឺមានដូចតទៅ :

១) ខ្ញុំឧស្សាហ៍សាកសួរអ្នកនេះធ្វើអ្វី អ្នកនោះធ្វើអ្វីកាលនៅសង្គមចាស់ ឬសាកសួរគេពីនេះពីនោះក្នុងសង្គមចាស់ ។

២) ខ្ញុំចូលចិត្តនិយាយតែរឿងហូបនេះឆ្ងាញ់ ហូបនោះឆ្ងាញ់ ឬមួយចង់ហូបបបរស្ពរជាដើម ។

៣) ខ្ញុំប្រាប់មិត្ត ខេត្ត អំពីអ្នកមានធំៗនៅស្រុកអាមេរិកតាមគាត់សួរខ្ញុំ ហើយខ្ញុំបានពន្យល់គាត់នូវទ្រឹស្តី គីហ្សីង ហ្គ៍រ ស្តីពីចម្បាំង និងយុទ្ធវិធីរបស់ចក្រពត្តិអាមេរិកក្នុងសាកលលោក ។

៤) ខ្ញុំបានស្របមតិជាមួយមិត្ត ថោង អាន និង ឈឹម ខេត្ត ស្នើបង សាន់ ឲ្យយើងខ្ញុំឈប់លីតុ កៅអី មកដាក់កន្លែងហូបបាយតាមការណែនាំរបស់អង្គការ ។

ឈ) សកម្មភាពដែលនាំទៅដល់ការចាប់ខ្ជួន

១) ខ្ញុំបានរួមចំណែកជាមួយមិត្ត ប៉ែន ថោងអាន និងមិត្ត យ៉ែង សារុន ធ្វើការទិតៀន បង សាន់ ដែលជាយុទ្ធជន ហើយជាប្រធានផ្ទាល់របស់ខ្ញុំថា គាត់មិនសូវចេះអក្សរ ។

២) ខ្ញុំបានស្របជាមួយមិត្ត ប៉ែន ថោងអាន ធ្វើការទិតៀនបង យ៉ុង ប្រធានភូមិតាឡីថា គាត់ចូលចិត្តនិយាយតែដដែលៗ ហើយគាត់ច្រើននិយាយបំផ្លើស (នេះតាមសម្តី ប៉ែន ថោងអាន) ដូចជា នៅពេលចម្បាំង បងប្អូនខ្លះដឹកទឹកនោម ហូបស្លឹកឈើ ហើយយកស្លឹកឈើសរសេរ ព្រោះគ្មានក្រដាស ហើយបងប្អូនយើងនៅពោធ៍សាត់នាំគ្នាជីកប្រឡាយទឹក ហើយហូបបបរដាក់អង្ពរមួយកំប៉ុង សម្រាប់គ្នាប្រាំមួយនាក់ ។

៣) ខ្ញុំបានស្របមតិជាមួយ ប៉ែន ថោងអាន ធ្វើការទិតៀនកុមារបដិវត្តន៍ថា កុមារនេះគ្មានវិន័យសោះ ចូលចិត្តចង់បាននេះចង់បាននោះ ហើយចូលចិត្តបេះផ្លែឈើខ្ទីៗ ។

៤) បានសម្តែងនូវសេចក្តីរីករាយនៅពេលមិត្ត សោ ភ័ន និងគ្រួសារគាត់ បូ ច័ន្ទ ថា នឹងធ្វើនំកូប្រៃផ្អែម ។

៥) មិនបានរាយការណ៍ជូនអង្គការនៅពេលដែលមិត្ត ឈឹម ខេត្ត ធ្វើការទិតៀនចំពោះបង ចឿន ដែលជាយុទ្ធជន ហើយនៅក្នុងគណៈទទួលខុសត្រូវ ព្រោះបង ចឿន បានពោលថា មានមិត្តខ្លះធ្វើការដូចនាម៉ឺនចាស់ ឲ្យតែដល់ម៉ោងទម្លាក់ចបចោល ហើយឈប់ភ្លាម ។ មិត្ត ឈឹម ខេត្ត ថា មិត្ត ចឿន មិនដែលច្បាំងម្តងដងមើលទៅ ប្រហែលនៅតែសមរភូមិក្រោយទេមើលទៅ ។

ខ្ញុំបានរាយការណ៍ជូនដល់ប្រធាន គឺបង សាន់ ចំពោះរឿងខ្លះ ប៉ុន្តែមិនបានរាយការណ៍ឲ្យអស់ ហើយមិនដែលបានប្រាប់គាត់ថា ខ្ញុំក៏បានរួមចំណែក ទោះតិចក្តី ច្រើនក្តីដែរ ។

ក្រោយដែលខ្ញុំ, មិត្ត ប៉ែន ថោងអាន, មិត្ត ឈឹម ខេត្ត និងគ្រួសារ, មិត្ត សោ ភ័ន និងគ្រួសារ ត្រូវអង្គការបដិវត្តន៍ឲ្យទៅនៅភូមិខាងលិច ខ្ញុំ និងមិត្ត ប៉ែន ថោងអាន ត្រូវនៅផ្ទះជាមួយគ្នា ។ ខ្ញុំបានរួមធ្វើការងារពលកម្មបានកន្លះព្រឹក ក៏ឈប់ព្រោះខ្ញុំមុតដែកគោល ។ ខ្ញុំខកខានធ្វើការ ដោយធ្វើការណាដែលស្រាលៗជាមួយកុមារប៉ុណ្ណោះ ។ រហូតដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ ប្រហែលម៉ោង៥:១៥ នាទីល្ងាច បង សាន់ បានប្រាប់ខ្ញុំថា អង្គការស្នើឲ្យខ្ញុំទៅបំពេញភារកិច្ចនៅកន្លែងផ្សេង ។ ខ្ញុំខំរៀបចំប្រញាប់ប្រញាល់រកតែពេលផ្ទាស់ខោខ្មៅអាវខ្មៅមិនទាន់ ហើយអង្គការក៏ឃាត់ខ្ជួន ខ្ញុំចាប់តាំងពីពេលនោះរហូតមក ។

សោម ម៉ុនថន

ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី «សំឡេងអំពើប្រល័យពូជសាសន៍ : យុត្តិធម៌ និងការអត់ឃ្លាន» ចាក់ផ្សាយតាមស្ថានីយ៍វិទ្យុ ◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញវេលាម៉ោង១រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៤រសៀល ◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈរយៈទូរស័ព្ទ ០២៣ ២១ ១ ៨៧៥ ឬ ០ ៩២ ១ ៦៨ ៥ ៤៣ ។

ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរខ្មែក្រហមប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្ប្ធម៌ និងវិចិត្រសិល្ប: ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ីបការណ៍ឲ្យសេ.អ៊ី.អា ឬ ក.ហេ.ប.ប ជាដើម ។

ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរខ្មែក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឬា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទ លេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthpechet@dccam.org ។

◆ ទីកន្លែង : អាគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល

ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្ធឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើដែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្ងះទៀតរួមមាន : ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្ងា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។













អ៊ុន ភឿន : មេក្រមកងពិសេស ផ្ទៃកដើងទឹក ឈរដើងនៅកោះពួលវ៉ៃ និងក្រចកសេះ

អ៊ីប្រុស អ៊ុន ភឿន មានអាយុ ៦១ឆ្នាំ ជាកសិករ មានប្រពន្ធ និងកូនប្រុសស្រីបួននាក់ រស់នៅស្រុកសាលាក្រៅ ខេត្តប៉ៃលិន។ ភឿន មិនមែនមានស្រុកកំណើតនៅខេត្តប៉ៃលិននេះទេ គាត់ជានមកស៊ីនៅទីនេះ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទាំងស្រុង។ ភឿន មានស្រុកកំណើតនៅស្រុកសំរោង ខេត្តតាកែវ។ របបខ្មែរក្រហមជានបន្ទាស់ទុកនូវរឿងរ៉ាវជាច្រើនសម្រាប់ ភឿន។ រហូតដល់បច្ចុប្បន្ន ក៏ ភឿន មិនអាចបំភ្លេចជានូវជីវិតជាយោធាខ្មែរក្រហមជានដែរ។ គាត់ចូលក្នុងចលនាខ្មែរក្រហមក្នុងគោលបំណងតែមួយគត់ គឺចូលរួមតស៊ូដើម្បីនាំយកសម្តេចឪមកគ្រប់គ្រងប្រទេសវិញ។

អ៊ុន ភឿន

ភឿន កើតនៅក្នុងគ្រួសារកសិករដែលមានបងប្អូនប្រុសស្រីដប់នាក់។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ឆ្នាំ ១៩៧០ មានឃើញវត្តមានរបស់ចលនាតស៊ូខ្មែរក្រហមចូលមកក្នុងភូមិស្រុកគាត់ទៅហើយ ប៉ុន្តែខ្មែរក្រហមពេលនោះ មិនជានធ្វើទុក្ខបុកម្នេញដល់ប្រជាជនណាម្នាក់ទេ គឺគ្រាន់តែចុះមកធ្វើការយោសនាអប់រំដុសប្រជាជនឲ្យចូលរួមតស៊ូប្រឆាំងនឹងចក្រពត្តិនិយមអាមេរិក ដើម្បីនាំយកសម្តេចឪមកគ្រប់គ្រងប្រទេសវិញ។ ភឿន ក៏ដូចជាប្រជាជនក្នុងភូមិជាច្រើនជានសម្រេចចិត្តចូលរួមជាមួយចលនាតស៊ូរបស់ខ្មែរក្រហម។

នៅឆ្នាំ១៩៧៣ ក្នុងវ័យ ១៨ឆ្នាំ ភឿន ត្រូវជានចាត់តាំងឲ្យធ្វើជាយោធាខ្មែរក្រហម។ គាត់ចូលធ្វើយោធាជានប្រាំមួយខែ អង្គការចាត់តាំងឲ្យឡើងធ្វើជាប្រធានក្រុម ដោយអង្គការមើលឃើញគាត់ជាយុទ្ធជនអង់អាច និងសកម្មក្នុងការងារដែលអង្គការដាក់ឲ្យធ្វើ។ ភាពអង់អាច និងសកម្មប្រយុទ្ធរបស់ ភឿន ជានធ្វើឲ្យគាត់ឡើងដំណែងជាបន្តបន្ទាប់។

ក្រោយមក គាត់ត្រូវអង្គការចាត់តាំងជាប្រធានកងអនុសេនាតូចលេខ១ ត្រប់ត្រងសមាជិក៣៦នាក់ ចំណុះឲ្យកងវរសេនាតូចលេខ ៨២០។ ភឿន ជានដឹកនាំប្រយុទ្ធជាមួយទ័ពសាធារណរដ្ឋខ្មែរនៅសមរភូមិជាច្រើន ស្ថិតនៅតាមបណ្តាយផ្លូវជាតិលេខ ១៨ ទៅដល់ព្រលានយន្តហោះពោធិ៍ចិនតុង និងទទួលជានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ក្រោយថ្ងៃជ័យជម្នះជានមួយសប្តាហ៍ ត្រប់កងអនុសេនាតូចទាំងអស់ដែលចំណុះកងវរសេនាតូច ៨២០ រួមទាំងកងរបស់ ភឿនផង ត្រូវអង្គការបញ្ជូនទៅកំពង់សោម។ ទៅដល់ទីនោះ ភឿន មិនឃើញមានប្រជាជនណារស់នៅទេ គឺមានតែយោធាខ្មែរក្រហមប៉ុណ្ណោះ។ ប្រជាជនត្រូវខ្មែរក្រហមជម្លៀសឲ្យចេញទៅតំបន់ផ្សេងៗ។ សម្រាកនៅកំពង់សោមជានមួយរយៈ កងអនុសេនាតូចរបស់ ភឿន និងកងអនុសេនាតូចមួយចំនួនទៀត ត្រូវអង្គការប្តូរទិសឲ្យមកខាងកំពង់ដែរវិញ។ ក្រោយមក ភឿន និងសមា

ដ៏ក្រុម ត្រូវអង្គការបញ្ជូនបន្តតាមទូកឲ្យទៅឈរជើងការពារនៅកោះពួលូវ៉ៃ និងកោះក្រចកសេះ ។

នៅលើកោះពួលូវ៉ៃ ភ្ជឿន មិនឃើញមានមនុស្សរស់នៅទេ ។ ការរស់នៅទីនោះពិតជាលំបាកណាស់ សម្រាប់កងរបស់ ភ្ជឿន ហើយរបបអាហារទៀតសោត ទោះបីជាកងទ័ពក៏ដោយ ក៏នៅតែខ្វះខាតដែរ ។ កងរបស់ ភ្ជឿន ទទួលបានតែរបបអាហារពីរពេលប៉ុណ្ណោះ គឺ ថ្ងៃត្រង់ និងល្ងាច ដោយពេលថ្ងៃទទួលបានបាយ និងល្ងាចទទួលបានបបរ ។ ពីរខែក្រោយបន្ទាប់ពីកងរបស់ ភ្ជឿន ឈរជើងនៅកោះទាំងពីរ កងទ័ពវៀតណាមក៏រ៉ាយចូលមក ។ នៅខែមិថុនា ឆ្នាំ១៩៧៥ វៀតណាម បានចាប់ផ្តើមរ៉ាយប្រហារកាន់តែខ្លាំងមកលើយោធាខ្មែរក្រហម ដែលឈរជើងការពារនៅកោះទាំងនោះ ។ ការប្រយុទ្ធនេះបានអូសបន្លាយអស់រយៈពេលដប់ថ្ងៃ ។ ទីបំផុតយោធាខ្មែរក្រហមបានទទួលបរាជ័យ ហើយត្រូវកងទ័ពវៀតណាមចាប់ខ្លួនបានទាំងអស់ ៦៤៥ នាក់ ដោយបញ្ជូនបន្តទៅដាក់គុកនៅកោះត្រល់ ។ នៅទីនោះ វៀតណាមបានផ្តល់អាហារឲ្យហូប តែជារឿយ។ វៀតណាមបានយកឈ្លើយសឹកខ្មែរក្រហមយកទៅធ្វើទាសករណកម្ម ។ ដោយឡែកតែ ភ្ជឿន ក្នុងអំឡុងពេលច្បាំងជាមួយវៀតណាមដំបូង មានរបួស ហេតុនេះហើយទើបវៀតណាមមិនយកគាត់ទៅធ្វើទាសករណកម្មដូចសមាជិកក្រុមដទៃទៀត ដោយគ្រាន់តែចាប់យកទៅសួរចម្លើយថា «ហេតុអ្វីបានជាអ្នកឯងមករស់នៅលើកោះរបស់យើង?» ភ្ជឿន ឆ្លើយថា គាត់មកនេះ គឺតាមបញ្ជារបស់អង្គការលើប៉ុណ្ណោះ ។

បន្ទាប់ពីមានការចាប់ខ្លួនពីសំណាក់កងទ័ពវៀតណាម ក៏មានការចរចាមួយរវាងអង្គការ និង វៀតណាម ហើយវៀតណាមក៏យល់ព្រមដោះលែងឈ្លើយសឹកទាំងអស់ឲ្យត្រឡប់មកវិញ ។ នៅដើមឆ្នាំ១៩៧៦ ភ្ជឿន កងអនុសេនាតូចរបស់ ភ្ជឿន ត្រូវអង្គការចាត់តាំងឲ្យទៅឈរជើងការពារនៅកោះតាង ។ ភ្ជឿន បានឲ្យដឹងថា បន្ទាប់ពីដោះលែងមនុស្ស កោះពួលូវ៉ៃ គឺកម្ចាំងខាងខ្មែរក្រហមនៅគ្រប់គ្រងដដែល ឯកោះក្រចកសេះវិញ គឺខាងវៀតណាមជាអ្នកគ្រប់គ្រង ។

នៅខែកក្កដា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំង ភ្ជឿន ឲ្យទៅរៀននៅប្រទេសចិន ជាមួយនឹងមនុស្សមួយចំនួនទៀត ដែលអង្គការជ្រើសរើសពីកម្ចាំងដែលឈរជើងការពារនៅតាមកោះនីមួយៗ ។ សមាជិករបស់ ភ្ជឿន ពីរនាក់ទៀតដែលអង្គការជ្រើសរើសមាន ស៊ីមៀន នាទីជាប្រធានកងអនុសេនាធំលេខ១ និង ប៊ិន នាទីជាប្រធានអនុសេនាតូចលេខ២ ក្នុងកងវរសេនាតូចលេខ ៤២០ ។ បន្ទាប់ពីធ្វើការពិនិត្យសុខភាពរួចរាល់អស់ហើយ នៅដប់ថ្ងៃបន្ទាប់ ភ្ជឿន និងអ្នកដែលមកពីអង្គភាពផ្សេងៗទៀត សរុបជាង១០០នាក់ ត្រូវអង្គការដឹកតាមឡានមកកាន់ទីក្រុងភ្នំពេញ ។ មកដល់ភ្នំពេញ អង្គការឲ្យអ្នកទាំងអស់រស់នៅផ្ទះមុំដូរ៉ារអូរ ឬ ស្ងៃ តែមិនអនុញ្ញាតឲ្យដើរទៅណាមកណានោះទេ គឺគ្រាន់តែប្រាប់ថាលាក់ការណ៍រក្សាការសម្ងាត់ និងទិតទំរៀនសូត្រពីគ្នាទៅវិញទៅមក ។ នៅភ្នំពេញបានកន្ទុះខែ អង្គការបានកាត់ខោអាវឲ្យម្នាក់ពីរកំបេរ សម្រាប់ត្រៀមចេញដំណើរទៅប្រទេសចិន ។

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៦ មុននឹងចេញដំណើរទៅប្រទេសចិន អង្គការបានប្រមូលអ្នកដែលត្រូវទៅរៀនទាំងអស់មកប្រជុំនៅស្តាតអូរឡាំពិក ។ ពេលទៅដល់ ភ្ជឿន ឃើញមានវត្តមានរបស់ ខ្ចៀ សំដន នៅទីនោះទៀតផង ។ ខ្ចៀ សំដន បានណែនាំដល់អ្នកដែលទៅរៀនទាំងអស់ពីរបៀបរបបរស់នៅស្រុកគេ និងរំពឹងឲ្យអ្នកទាំងអស់គ្នាចេះសាមគ្គីគ្នា ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំដដែល យន្តហោះចិនបានមកទទួលនៅព្រលានយន្តហោះពោធិ៍ចិនតុង ។ អ្នកដែលចេញដំណើរទៅដំបូងមានចំនួនតែ៨៣នាក់ប៉ុណ្ណោះ រួមទាំង ភ្ជឿន សល់ពីនោះ នឹងចេញដំណើរទៅតាមក្រោយ ។

ភ្ជឿន ធ្វើដំណើរបានប្រហែលប្រាំម៉ោង យន្តហោះបានចុះចតនៅព្រលានយន្តហោះទីក្រុងសៀងហៃ ដោយមានការចាំទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ភាគីចិន ។ ក្ស្ជនឡានចាំទទួលជាស្រេច និងជូនអ្នកទៅរៀនទាំងអស់ទៅកាន់សាលាបច្ចេកទេសដើងទឹក ។ ភ្ជឿន សម្រាកនៅសាលាបានមួយសប្តាហ៍ ទើបអ្នកដទៃទៀតដែលចេញដំណើរមកតាមក្រោយមកដល់ ។ បន្ទាប់ពីសមាជិកទាំងអស់មកជុំគ្នាហើយ ខាងចិនបានរៀបចំពិធីដប់លៀងជាកិច្ចបើកវគ្គបណ្តុះបណ្តាល ។ ដោយសារតែមិនចេះភាសាចិន ភ្ជឿន និងសមាជិកទាំងអស់ ត្រូវខាងចិនតម្រូវឲ្យរៀនភាសាចិនរយៈពេល ៦ខែសិនមុននឹងចូលរៀនបច្ចេកទេស គឺរហូតដល់ឆ្នាំ១៩៧៧ ទើប

ជាន់ចូលរៀន ។

ការរៀនបច្ចេកទេសដើងទឹកនេះ គឺ មានរយៈពេល២៣ ខែ ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៧ ដដែលនេះ ក៏មានការស្នើពីអង្គការ ដកមនុស្សដែលជាប់និន្នាការមកពីភូមិភាគបូព៍ត្រឡប់មកកម្ពុជា វិញ ក្នុងនោះក៏មាន ស៊ីមៀន ជាសមាជិករបស់ ភឿន ម្នាក់ដែរ ។ ភឿន បញ្ជាក់ថា ការចាប់យក ស៊ីមៀន មកវិញនេះ គឺមិនមែន ស៊ីមៀន មាននិន្នាការនៅភូមិភាគបូព៍ទេ គឺអង្គការជាន្សោវជ្រាវ ប្រវត្តិដឹងថា ស៊ីមៀន ជាអតីតប៉ូលិសពីសង្គមចាស់ ។

នៅដើមខែមេសា ឆ្នាំ១៩៧៨ ភឿន និងសមាជិកផ្សេងៗ ជានបញ្ចប់វគ្គសិក្សាដោយជោគជ័យ និងជានត្រឡប់មកកម្ពុជា វិញមួយចំនួន ហើយអ្នកមួយចំនួនទៀត នៅបន្តការសិក្សានៅ ទីនោះបន្តទៀត ។ បន្ទាប់ពីមកដល់ភ្នំពេញជានបីថ្ងៃ អង្គការក៏ជាន រៀបចំពិធីខួបរំពុកអនុស្សាវរីយ៍នៃថ្ងៃជ័យជម្នះ ១៧ មេសា របស់ខ្លួននៅស្តាតអូរឡាំពិក ហើយ ភឿន ក៏ជានចូលរួមក្នុងពិធី នោះដែរ ។ ភឿន ទៅដល់ស្តាតអូរឡាំពិក ឃើញមានមនុស្សរាប់ ពាន់ដែលមកពីគ្រប់តំបន់នានាមកចូលរួមក្នុងកម្មវិធីនេះ ។ ក្នុង ការធ្វើមីទ្ទីងដ៏ធំនេះ ភឿន ជានឃើញថ្នាក់ដឹកនាំធំៗជាច្រើនមក ចូលរួម មានប៉ុល ពត, អៀង សារី, តា ម៉ុក និងកម្មាភិជាលជាន់ខ្ពស់ ជាច្រើនទៀត ដែលគាត់មិនជានស្គាល់ឈ្មោះ ។ ពិធីប្រព្រឹត្តទៅ ពេញមួយព្រឹក ហើយនៅពេល ភឿន ត្រឡប់មកកាន់កន្លែងស្នាក់ នៅវិញ អង្គការជានចេញបញ្ជាឲ្យក្រុមរបស់ ភឿន ត្រឡប់ទៅ កំពង់សោមវិញ ។ ប៉ុន្តែ អង្គការមិនឲ្យគាត់ធ្វើដំណើរតាមផ្លូវ ជាតិលេខ៤ទេ គឺអង្គការតម្រូវឲ្យធ្វើដំណើរកាត់ទៅតាមផ្លូវជាតិ លេខ៣វិញ ព្រោះអង្គការចង់បង្ហាញឲ្យអ្នកទាំងអស់គ្នាមើល ឃើញការកសាងទំនប់ ប្រឡាយនានា នៅតាមបណ្តោយផ្លូវជាតិ លេខ ៣នេះ មុននឹងទៅដល់កំពង់សោម ។

ភឿន និងសមាជិកទាំងអស់ ជានមកដល់កំពង់សោមនៅ ពេលយប់ ហើយមកស្នាក់នៅផ្ទះដែលអង្គការរៀបចំរួចជាស្រេច នៅឆ្នេរអូរឈើទាល ។ រយៈមួយអាទិត្យនៅទីនោះ ភឿន មិនមាន ការងារអ្វីធ្វើនោះទេ ។ បន្ទាប់មក ទើបអង្គការជានដាក់ទិសឲ្យ ក្រុមរបស់ ភឿន ចុះជួយប្រជាជននៅតាមសហករណ៍ ដូចជាការ កសាងទំនប់ ប្រឡាយ និងធ្វើស្រែជាដើម ។ នៅពាក់កណ្តាលខែ ឧសភា ឆ្នាំ១៩៧៨ ចិនជានបញ្ជូនកជ៉ាល់ចម្បាំងមកដល់កំពង់ដែ កំពង់សោមចំនួនពីរគ្រឿង ។ កជ៉ាល់ចម្បាំងនេះ គឺអាចផ្ទុកមនុស្ស រហូតទៅដល់៧៣នាក់ ។ អង្គការជានបើកវគ្គបណ្តុះបណ្តាលដល់ យោធាដើងទឹក ទាំងអស់អំពីរបៀបប្រើប្រាស់នាវាចម្បាំងនេះ ដោយមានគ្រូបង្រៀន គឺជាអ្នកដែលទើបត្រឡប់មកពីរៀននៅ ប្រទេសចិន ក្នុងនោះ ក៏មាន ភឿន ម្នាក់ដែរ ។ ភឿន បង្រៀនខាង ផ្នែកកាំភ្លើងធំ ២៥ មីលីម៉ែត្រ ។ ការបង្រៀននេះ បន្តរហូតដល់ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ទើបបញ្ចប់ ។ បន្ទាប់ពីបញ្ចប់ការរៀន នេះ ហើយ សមាជិកទាំងអស់ត្រូវឡើងទៅរស់នៅលើកជ៉ាល់ដែលមាន មូលដ្ឋានទៅរាម ។

នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ភឿន ជានទទួលបញ្ជាពី អង្គការលើថា ឲ្យត្រៀមកម្លាំងទាំងអស់នៅលើកជ៉ាល់ ព្រោះ កងទ័ពវៀតណាមជិតចូលមកដល់ហើយ ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បន្ទាប់ពីទទួលដំណឹងថា ភ្នំពេញត្រូវកងទ័ពវៀតណាម ជានរំដោះហើយ អង្គការជានបញ្ជាឲ្យ ភឿន និងកម្លាំងផ្សេងទៀត ប្រមូលកជ៉ាល់ទាំងអស់សរុប២២ និងទូកពីរ ដែលទើបយកមកពី ប្រទេសចិន ទៅលាក់ទុកនៅត្រពាំងរូង ក្នុងទឹកដីខេត្តកោះកុង ។ បន្ទាប់ពីលាក់កជ៉ាល់ទាំងនោះ រួចរាល់អស់ហើយ ភឿន ជានដឹកនាំ កម្លាំងមកវាយជាមួយវៀតណាម ដោយពេលនោះ ភឿន មាន នាទីជាមេក្រុមកងពិសេស ដែលមានសមាជិកទាំងអស់១២នាក់ ប៉ុន្តែ មិនអាចទប់ទល់នឹងកងទ័ពវៀតណាមជានទេ ដោយសារ ដាច់ទំនាក់ទំនងជាមួយអង្គការលើ និងខ្ទះខាតស្បៀង ហេតុនេះ ភឿន ជានដកថយមកខេត្តកោះកុងវិញ ដើម្បីបន្តដំណើរទៅថ៉ ។ មកដល់ខេត្តកោះកុង អង្គការជានចាត់ឲ្យ ភឿន ធ្វើជាអ្នកទាក់ ទងជាមួយភាគីថ៉ៃក្នុងការទិញទំនិញ ។ ថ្ងៃមួយ ពេលដែល ភឿន ទៅចរចារឿងដោះដូរទំនិញ ភាគីថ៉ៃជានចាប់ខ្លួនគាត់ និងអ្នក ឯទៀត យកទៅដាក់នៅជំរំមួយដែលគេជោះបង់ចោលតាំងពី ឆ្នាំ១៩៧៥ ព្រមទាំងជានរឹបអូសមាស ប្រាក់របស់គាត់អស់ជា ច្រើនទៀត ។

ក្រោយពីចាប់ខ្លួនជានមួយខែ នៅដើមឆ្នាំ១៩៨០ ភឿន និងសមាជិកឯទៀត ត្រូវជានដោះដែង បន្ទាប់ពីមានការចរចាពី សំណាក់ភាគីខាងខ្មែរក្រហម និងថ៉ ។ បន្ទាប់ពីត្រឡប់មកវិញ

ភឿន ត្រូវអង្គការចាត់តាំងឲ្យរស់នៅតាមព្រំដែនកម្ពុជា-ថៃ។ អង្គការបានឲ្យ ភឿន ជាមួយនឹងកម្លាំងទាំង ១៥នាក់របស់គាត់ចុះទៅតាមជំរំ។ ដោយអ្នកទាំង១៥នាក់នោះ ត្រូវបែងចែកទៅតាមជំរំនីមួយៗ ក្នុងនោះមានបួននាក់ ចុះទៅជំរុំខាវអ៊ីដាង ប្រាំពីរនាក់ទៀតចុះទៅជំរំនៅខេត្តស្រះកែវ និងបួននាក់ទៀត ចុះទៅជំរំខាំកុត។ ភឿន ជាមេក្រុមដឹកនាំចុះទៅជំរំខាំកុត។ ការចុះទៅតាមជំរំនេះ គឺក្នុងគោលបំណងដើម្បីអប់រំប្រជាជនត្រឡប់មកចូលរួមជាមួយខ្មែរក្រហមវិញ ដើម្បីប្រឆាំងទៅនឹងការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា។ ការចុះទៅឃោសនាតាមជំរំនេះមិនមានការហាមឃាត់ពីសំណាក់ភាគីថៃទេ ព្រោះថៃនាពេលនោះគឺជាអ្នកគាំទ្រខ្មែរក្រហម។ នៅឆ្នាំ១៩៨០ ភឿន បានរៀបការជាមួយអ្នកដែលនៅជំរំជាមួយគ្នា ហើយឆ្នាំ១៩៨១ ភឿន និងគ្រួសារព្រមទាំងប្រជាជនដែលយល់ព្រមចុះចូលជាមួយ ភឿន ប្រមាណ៣០០-៤០០នាក់ បានត្រឡប់មកខេត្តកោះកុងវិញ។ ពេលនោះ សង្គ្រាមប្រឆាំងនឹងវៀតណាម ក៏បានចាប់ផ្តើម និងអូសបន្ទាយរហូតដល់ឆ្នាំ១៩៨៥ ទើបវៀតណាម ដកថយចេញពីតំបន់នោះ។ ក្រោយពីវៀតណាមដកទ័ព ភឿន ធ្វើការចល័តតាមព្រំដែនថៃ និងបានចូលរួមចម្បាំងប្រឆាំងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជានៅតំបន់សំឡូត ដោយពេលនោះដឹកនាំប្រយុទ្ធ ដោយអៀង ដាន និង មាស មុត ជាប្រធានកងពលទី៣។ ការប្រយុទ្ធនេះអូសបន្ទាយដល់ឆ្នាំ១៩៩៦ ទើបបានស្ងប់ស្ងាត់។

នៅឆ្នាំ១៩៩៨ ដោយមានការឯកភាពជាតិទាំងស្រុង ភឿន និងកងកម្លាំងមួយចំនួនបានដាក់អាវុធចុះចូល និងបន្តរស់នៅតំបន់សំឡូត។ រហូតដល់ឆ្នាំ២០០៨ ទើបគាត់ផ្ទាស់មកនៅស្រុកសាលាក្រៅ ខេត្តប៉ៃលិនវិញ។

សាយ ធិត្យពិសី

ខ្សែភាពយន្តឯកសាររឿង «ក្ឍង់ទឹកធន្លូ»

«ក្ឍង់ទឹកធន្លូ» គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋការពីក្រសួងវប្ប:ធម៌ និងវិចិត្រសិល្ប:។ មកដល់ពេលនេះ ខ្សែភាពយន្ត «ក្ឍង់ទឹកធន្លូ» ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ។ «ក្ឍង់ទឹកធន្លូ» បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញ្ចក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្ប:ទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស បែលហ្ស៊ីក អាល្លឺម៉ង់ ហ្ក្រេវ៉ាន់ត្សូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏ត្រូវបានដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្ទាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនាវៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្ការ៉ាលី តាមរយៈទូរស័ព្ទលេខ: ០១២ ៥១១ ៩១៤។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*

ការចងចាំ «ឧីពុកម្តាយខ្ញុំស្លាប់ ដោយថាប់និន្នាការខ្មាំង»

សាំង សុធា

សាំង សុធា មានអាយុ៤៧ឆ្នាំ មានស្រុកកំណើតនៅឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ ធា មានឪពុកឈ្មោះ សាំង ហ៊ីន ស្លាប់តាំងពី សុធា មានអាយុ៨ឆ្នាំ ដោយសារជាប់និន្នាការទាហានចំណែកម្តាយ សុធា ឈ្មោះ លឹម ប៉ាត់ បានស្លាប់ដោយសារតែកាត់ទៅតាមប្អូនស្រីដែលឈ្លបខ្មែរក្រហមយកទៅនៅកន្លែងថ្មី ។

សុធា បានរៀបរាប់ថា ឪពុកគាត់មានស្រុកកំណើតនៅភូមិព្រៃក្មេង ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ។ ឪពុកគាត់បានចេញពីភូមិមករៀននៅភ្នំពេញនៅទសវត្សរ៍ឆ្នាំ១៩៤០ ដោយស្នាក់នៅវត្តលង្កា ក្រុងភ្នំពេញ ។ ពេលកំពុងរៀន ឪពុក សុធា មានឪពុកធម៌ម្នាក់ឈ្មោះ រាជ រ៉ត្ន ធ្វើជាតំណាងរាស្ត្រ និងមានផ្ទះនៅតាមបណ្តោយទន្លេវ៉ៃគោ ក្នុងក្រុងស្វាយរៀង ។ បន្ទាប់ពីរៀនចប់នៅឆ្នាំ១៩៥៤ ឪពុកគាត់ក៏ចេញទៅធ្វើនាយកសាលាបឋមសិក្សាសំបួរ ស្ថិតនៅឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ ឪពុកធា ធ្វើនាយកសាលាបានមួយឆ្នាំ ក៏លោក រាជ រ៉ត្ន បានរៀបចំ គាត់ឲ្យរៀបការជាមួយឈ្មោះ លឹម ប៉ាត់ (ត្រូវជាម្តាយរបស់ សុធា) មានទីលំនៅ នៅផ្សារប្រសូត្រ ស្ថិតនៅក្នុងឃុំប្រសូត្រ និងមានចម្ងាយប្រមាណ៦គីឡូម៉ែត្រពីសាលា ។

ក្រោយពីរៀបការរួច ឪពុកម្តាយ សុធា បានផ្លាស់មករស់នៅទីរួមខេត្តស្វាយរៀងវិញ ព្រោះពេលនោះមានកងទ័ពវៀតកុង (វៀតណាមខាងជើង) ចូលមកក្នុងភូមិប្រសូត្រ ហើយ ។ ស្របពេលនោះដែរ ក្រសួងក៏ចាត់តាំងឪពុក សុធា ឲ្យទទួលនាទីមួយទៀត គឺចូលធ្វើទាហាន រួចហើយបញ្ជូនឲ្យទៅវាយប្រយុទ្ធជាមួយខ្មែរក្រហមនៅសមរភូមិអ្នកលឿង ។

មកដល់ឆ្នាំ១៩៧៥ ឪពុកម្តាយ សុធា និងកូនប្រាំពីរនាក់រួមមាន : សាំង សុធី, សាំង សុន្ទរី, សាំង សុគន្ធ, (សុធា), សាំង រ៉ត្នធីតា, សាំង សុគន្ធពិដោរ និង សាំង សុធរ ត្រូវបានខ្មែរក្រហមជម្លៀសទៅឃុំស្វាយធំ ស្រុកស្វាយជ្រំ ។ សុធា បានចាំថា នៅពេលជម្លៀសឪពុកគាត់បានឲ្យគាត់កាន់មុងមួយ ។ ពេលទៅដល់ឃុំនោះ ឈ្លបភូមិបានឃាត់ខ្លួនឪពុករបស់ សុធា ទុក រួចយកទៅដាក់នៅមន្ទីរអប់រំកែប្រែវត្តជ្រៀង ដោយចោទឪពុករបស់គាត់ជាប់និន្នាការ ទាហាន លន់ នល់ (ខ្សែខ្មាំង) ។ ចំណែកម្តាយ និងបងប្អូន សុធា អង្គការឲ្យទៅរស់នៅក្នុងភូមិ ហើយ សុធា ត្រូវគ្រូសារអ្នកមូលដ្ឋានយកទៅនៅជាមួយដោយឲ្យគាត់ឃ្វាលគោ ព្រោះឃើញម្តាយគាត់មានកូនច្រើន ។ ដំបូងឈ្លប ខ្មែរក្រហមបានអនុញ្ញាតឲ្យបងស្រីរបស់ សុធា ឈ្មោះ សាំង សុគន្ធ ទៅជួបសាកសួរសុខទុក្ខ និង យកនំអាកោ និងនំជាលទៅឲ្យឪពុករបស់គាត់ហូបបាន ។ ប៉ុន្តែក្រោយពេលអង្គការបញ្ជូនឪពុកគាត់ ទៅឃុំឃាំងនៅវត្តអង្គប្ចស្សីទើបឈ្លបឈប់អនុញ្ញាតឲ្យបងស្រីគាត់ទៅជួបទៀត ។ នៅទីនោះ ឪពុករបស់ សុធា បានជួបនឹងអ្នកទោសម្នាក់ឈ្មោះ ប៉ុន អាង ជាគ្រូបង្រៀន នៅខេត្តស្វាយរៀង មានស្រុកកំណើតនៅឃុំព្រែកពោធ៏ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលត្រូវជាបងប្អូនជីដូនមួយមិត្តភក្តិរបស់ឪពុកគាត់ឈ្មោះ ចឹកតុង បើកហាងលក់មាសនៅម្ពុំផ្សារស្វាយរៀង ។ នៅក្នុងគុក ប៉ុន អាង បានមើលថែទាំឪពុករបស់ សុធា ដែលធ្លាក់ខ្លួនឈឺ ដូចបងប្អូនដូច្នេះដែរ ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនគ្រូសារគាត់ឲ្យមករស់នៅឃុំគ្រូសវិញ ទើបចាប់តាំងពីពេលនោះមកបងរបស់ សុធា

និងក្រុមគ្រួសារ សុធា លែងទទួលដំណឹងពីឪពុកទៀតហើយ ។ អង្គការបានបែងចែកគ្រួសារ សុធា ឲ្យនៅរស់នៅជាមួយប្រជាជនមូលដ្ឋានក្នុងភូមិគ្រាក តែនៅអនុញ្ញាតឲ្យហូបឯកជនក្នុងគ្រួសារបាន ។ អ្នកភូមិនោះបានស្រឡាញ់ និងរាប់អានគ្រួសារ សុធា យ៉ាងខ្លាំង ទោះបីដឹងថា គ្រួសារគាត់ជាប្រជាជនថ្មីក៏ដោយ ។ ចំណែក សុធា ពេលនោះអ្នកភូមិតែងហៅគាត់ថា «អាបារ» ព្រោះគាត់មានសប្បុរស ហើយធាត់ ។

ក្នុងអំឡុងឆ្នាំ១៩៧៦ ដដែល ឈ្លបខ្មែរក្រហមបានដឹក ប៊ុន អាង (ជាប់ឃុំជាមួយឪពុកសុធា) តាមកង់មករកម្តាយរបស់ សុធា ដោយយកទាំងអាវ និងសំបុត្រផ្តាំផ្ញើពីឪពុករបស់ សុធា មកជាមួយដើម្បីសម្គាល់ដង ។ នៅពេលជួបគ្នា ប៊ុន អាង ដែលឈឺហើមជើងពុំរួច បានចាប់ដៃ និងស្រែកហៅម្តាយ សុធា ថា «បង១» និងបានរៀបរាប់ពីស្ថានភាពជងឺបងថ្លៃ (ឪពុក សុធា) ដើម្បីឲ្យឈ្លបខ្មែរក្រហមជឿជាក់ ព្រោះក្រោយពេលឈ្លបចាកចេញទៅបាត់ ប៊ុន អាង បានរៀបរាប់ថា ខ្មែរក្រហមបានដោះលែងគាត់វិញ ដោយសារគាត់មិនជាប់និន្នាការទាហាន ។ នៅពេលនោះ ដោយសារ ប៊ុន អាង មិនមានបងប្អូនរស់នៅក្នុងខេត្តស្វាយរៀង ទើបគាត់ទៅប្រាប់ឪពុករបស់ សុធា ហើយឪពុក របស់ សុធា បានប្រាប់ ប៊ុន អាង ឲ្យឆ្លើយកុហកអ្នកសួរចម្លើយ ហើយបានសរសេរសំបុត្របញ្ជាក់មួយឲ្យ ប៊ុន អាង ថា ត្រូវជាបងប្អូនថ្លៃ ហើយឲ្យមករស់នៅជាមួយបងថ្លៃ (ម្តាយ សុធា) វិញ ព្រោះបើមិនធ្វើដូច្នេះទេ ឆ្ងាំគុកនឹងឲ្យ ប៊ុន អាង រស់នៅកន្លែងនោះបន្តទៀត ។ ប៊ុន អាង បានបន្តថា មុនពេលចាកចេញពីកន្លែងឃុំឃាំង គាត់បានឲ្យភ្ជួយដែលគាត់ដណ្តប់រាល់ថ្ងៃទៅឲ្យឪពុក សុធា ដែលធ្លាក់ខ្លួនឈឺធ្ងន់ ចំណែក ឪពុក សុធា ក៏បានឲ្យអាវមកគាត់វិញដែរ ។ ក្រោយមក សុធា បានទទួលដំណឹងតាមរយៈបងប្អូនរបស់គាត់ម្នាក់ទៀត ដែលរស់នៅជិតមន្ទីរឃុំឃាំងវត្តអង្គបុស្សី ជាទីដែលខ្មែរក្រហមឃុំឃាំងឪពុកគាត់ថា បានជួបឪពុករបស់គាត់ដែលមានរូបរាងស្គមស្គាំង និងស្លៀកតែខោខ្ចី និងក្រមាមួយប៉ុណ្ណោះ ពេលឈ្លបបណ្តើរចេញទៅផ្ញើស្រែនៅខាងក្រៅមន្ទីរឃុំឃាំង ។ យើញដូច្នេះ បងប្អូនរបស់គាត់ក៏យកក្រណាត់ និងអាវឲ្យឪពុក ធា ស្លៀកពាក់ដែរ ។ ឪពុក សុធា បានស្លាប់នៅក្នុងអំឡុងឆ្នាំ១៩៧៧ ដោយសារអត់អាហារ ហើយខ្មែរក្រហមបានបញ្ជូនឲ្យ មាស ឌីម ជាអតីតអគ្គស្នងការយុវជន និងជាសាស្ត្រាចារ្យផ្នែកគីមី បង្ក្រៀនៅវិទ្យាល័យព្រះស៊ីសុវត្ថិ យកឪពុកគាត់ទៅកប់ (ក្រោយរបបខ្មែរក្រហមដួលរលំ ប្រជាជនរស់នៅក្បែរវត្តអង្គបុស្សីបានប្រមូលឆ្អឹងពីក្នុងស្រែដែលភ្ជួរប៉ះ និងឆ្អឹងនៅក្នុងមន្ទីរកែប្រែវត្តអង្គបុស្សី ដែលសរុបសាកសពទាំងអស់ប្រមាណជាង ១ ០ ០ មកដាក់តម្កល់នៅក្នុងចេតិយ) ។

ប៊ុន អាង បានមកស្នាក់នៅក្រោមផ្ទះរបស់ សុធា ហើយពេលគាត់ចេញដើរម្តងៗ គាត់ត្រូវកាន់ឈើច្រត់ដើម្បីជួយទប់ខ្លួន ។ មួយរយៈក្រោយមកទើប ប៊ុន អាង បានជាសះស្បើយ ។ ប៊ុន អាង ជាមនុស្សសកម្មក្នុងការងារ ដាំបន្លែ កាប់គាស់ រែកទឹក ហើយនៅពេលទំនេរយប់គាត់បាននាំ សុធា ចេញទៅផ្ទុះកង្កែបនៅតាមវាលស្រែយកមកធ្វើម្ហូបទៀតដង ។ យើញដូច្នេះ ទើបអ្នកភូមិជាច្រើនស្រឡាញ់ រាប់អាន ប៊ុន អាង ។ បន្ទាប់ពី ប៊ុន អាង រស់នៅជាមួយគ្រួសារ សុធា បានរយៈពេលមួយខែ ក៏មានអ្នកមូលដ្ឋានមួយគ្រួសារដែលមានផ្ទះនៅទល់មុខនឹងផ្ទះ សុធា សុំយក ប៊ុន អាង ទៅរស់នៅជាមួយវិញ ។

សុធា បន្តថា នៅក្នុងភូមិដែលគាត់រស់នៅមានទួលពីរគឺ ទួលមួយសម្រាប់កប់ខ្មោច និងទួលមួយទៀត គឺ ទួលបុរាណដែលមានដើមស្នែងគង់ (មានសំបកពណ៌ស និងមានផ្លែវែងៗ) ធំមួយដុះលើ ។ ទួលបុរាណនោះនៅជាប់នឹងត្រពាំង និងមានវាលព័ទ្ធជុំវិញ ។ អ្នកមូលដ្ឋានក្នុងភូមិនោះមានជំនឿថា មានបារមីអ្នកតាកាន់ជាប់នៅលើដើមឈើនោះ និងមិនដែលហ៊ានប៉ះពាល់ទួលនោះទេ ។ ចំណែក សុធា ក៏មិនដែលហ៊ានទៅដល់ទួលនោះដែរ ទោះទួលនោះស្ថិតនៅជិតនឹងផ្ទះរបស់គាត់ និងដឹងថាទួលនោះសម្បូរសត្វក៏ដោយ ។ មានថ្ងៃមួយ ខ្មែរក្រហមបានបញ្ជូនឲ្យបុរសម្នាក់ទៅកាប់ដើមស្នែងគង់ ដែលដុះលើទួលនោះចោល ប៉ុន្តែក្រោយពីកាប់ដើមឈើនោះមិនបានប៉ុន្មានថ្ងៃដង បុរសនោះក៏ធ្លាក់ខ្លួនឈឺស្លាប់ ដោយបន្សល់កូនចៅរស់នៅក្នុងក្រុងស្វាយរៀងរហូតមកដល់សព្វថ្ងៃនេះ ។

នៅឆ្នាំ១៩៧៧ ដដែល កងទ័ពរបស់វៀតណាមចាប់ផ្តើមវាយឆ្លងព្រំដែនចូលមក ទើបក្រុមគ្រួសាររបស់ សុធា បានរត់ភៀសខ្លួនចេញពីភូមិ ។ នៅតាមផ្លូវ ប្អូនរបស់ សុធា ឈ្មោះ សាំង

សុគន្ធពិដោរ បានធ្លាក់ឈឺធ្ងន់ ហើយស្លាប់នៅពេលនោះទៅ ។ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារ សុធា ដោយឲ្យដើរថ្មើរជើងសំដៅមកអ្នកលឿង ក្នុងខេត្តព្រៃវែង ។ មកដល់កំពង់ចម្ងង សុធា បានព្ទពាក្យចចាមអារ៉ាមនិយាយតគ្នាថា អង្គការនឹងធ្វើឲ្យស្រឡាងក្រឡាប់ក្នុងទន្លេ ដើម្បីសម្លាប់អ្នកជម្លៀសដែលធ្វើឲ្យគ្រួសារគាត់ភិតភ័យយ៉ាងខ្លាំង ប៉ុន្តែគាត់មិនបានឃើញហេតុការណ៍នោះកើតឡើងទេ ។ បន្ទាប់ពីឆ្លងទន្លេរួច ទើបខ្មែរក្រហមយកឡានមកដឹកគ្រួសារគាត់មកឈប់នៅច្បារអំពៅ ។ ពេលនោះ ដោយសារមានការខ្វះខាត ទើបប្រជាជនមួយចំនួនបានទៅវាយបង្ហួចយ្លាំងដាក់ក្រដាស់ដើម្បីរកសម្ភារ និងអាហារ ។ ក្រោយមកខ្មែរក្រហមបានចែកត្រីចំហុយឲ្យគ្រួសារ សុធា ហូប រួចហើយ ទើបដឹកបន្តមកដាក់នៅស្ថានីយ៍រថភ្លើង ក្នុងក្រុងភ្នំពេញ ។ ខ្មែរក្រហមបានដឹកក្រុមគ្រួសារ សុធា តាមរថភ្លើងទៅដល់ចំណតរថភ្លើងនៅម្ពុំស្វាយដូនកែវ (ក្នុងស្រុកបាកាន) ទើបឲ្យគ្រួសារគាត់ចុះ ។ នៅទីនោះ សុធា បានឃើញកញ្ចប់បាយរបស់អ្នកដំណើរដែលជម្លៀសមកមុនគ្រួសារគាត់ នៅរាយប៉ាយពាសពេញដី ។

ខ្មែរក្រហមបានបែងចែកគ្រួសារ សុធា ឲ្យទៅនៅភូមិមួយ (មិនចាំឈ្មោះ) ស្ថិតនៅឆ្ងាយពីផ្លូវរថភ្លើង ក្នុងស្រុកបាកាន ខេត្តពោធ៍សាត់ ដោយបំបែកម្តាយគាត់ បងស្រីគាត់ និងគាត់ឲ្យរស់ដាច់ដោយឡែកពីគ្នា ។ សុធា បានចូលទៅនៅក្នុងកងកុមារដោយគាត់មានភារកិច្ចចាំចាបនៅវាលស្រែ និងជីកអាងបឹងទំលែង ។ នៅទីនោះ ប្រធានកងស្រឡាញ់ពេញចិត្ត សុធា យ៉ាងខ្លាំង ហើយតែងតែនាំគាត់ទៅដេកជាមួយ ព្រោះ សុធា ចេះអាន និងចេះសរសេរអក្សរ ។ នៅមុនពេលជម្លៀសឆ្នាំ១៩៧៥ សុធា រៀនដល់ថ្នាក់ទី១១ (នៅសាលាបឋមសិក្សាស្វាយរៀងក្រុង) ។ ដោយសារ ធា ជិតស្និទ្ធជាមួយនឹងប្រធានកង ទើបនៅពេលទំនេរពីការងារ គាត់អាចចេញទៅដើររកក្តាម និងកង្កែបនៅតាមវាលស្រែមកហូបថែមទៀត ។ នៅពេលនោះដែរ បងស្រីរបស់ សុធា ក៏ត្រូវអង្គការចាត់ឲ្យនៅខាងដាំបាយឲ្យប្រធានកងសេដ្ឋកិច្ច និងកងកុមារក្បែរ សុធា ដែរ ។ នៅទីនោះ សុធា និង បងស្រីរបស់គាត់បានហូបគ្រប់គ្រាន់ ។

មានថ្ងៃមួយ នៅក្នុងឆ្នាំ១៩៧៨ សុធា បានព្ទដំណឹងថាប្ហូនស្រីគាត់ឈ្មោះ សាំង សុធរ ឈឺសម្រាកព្យាបាលនៅមន្ទីរពេទ្យមួយកន្លែង (មិនចាំឈ្មោះ) ដែលសង់ជារោងវែង និងដាក់ត្រែតម្រៀបជួរគ្នា ។ នៅពេលនោះ សុធា ក៏បានជួបនឹងម្តាយដែលនៅដេកកំដរប្ហូនដែរ ។ ពេលត្រឡប់មកកងវិញបានមួយរយៈ ស្រាប់តែអ្នកនៅក្នុងកងជាមួយមកប្រាប់ សុធា ថាប្ហូនរបស់គាត់ស្លាប់ហើយ ។ ព្ទដូច្នេះ សុធា ទៅសុំបាយពីខាងសេដ្ឋកិច្ចបានមួយកញ្ចប់ រួចហើយរត់កាត់ព្រៃសំដៅទៅរកប្ហូន និងម្តាយ ។ នៅតាមផ្លូវ ចម្ងាយប្រមាណជាង២គីឡូម៉ែត្រពីកងកុមារទៅមន្ទីរពេទ្យ សុធា ព្ទតែសំឡេងឆ្កែចចកលូរំពងព្រៃ ។ សុធា មិនបានជួបមុខប្ហូនទេ ព្រោះមុនពេលគាត់ទៅដល់ម្តាយគាត់ បានយកសាកសពប្ហូនគាត់ទៅកប់បាត់ទៅហើយ ។ ម្តាយ សុធា បានយំរៀបរាប់ប្រាប់ សុធា ថា «កូនឯងយកបាយមកធ្វើអ្វី ព្រោះប្ហូនកូនឯងស្លាប់បាត់ទៅហើយ» ។

សុធា អាណិតម្តាយគាត់យ៉ាងខ្លាំង ព្រោះម្តាយគាត់ខូចចិត្ត និងស្ទើរវង្វេងស្មារតីដោយសារតែកូនស្លាប់ រហូតដល់អ្នកភូមិមួយចំនួននិយាយថា «ម្តាយគាត់ឆ្ពួតទៀតផង» ។ ពាក្យដែលអ្នកភូមិនិយាយនោះ បានធ្វើឲ្យ សុធា មិនហ៊ានទៅជួបមុខម្តាយគាត់ដូចមុនទេ គឺមានតែបងស្រីរបស់គាត់ សាំង សុគន្ធ ប៉ុណ្ណោះ ដែលនៅតែហ៊ានទៅជួបមុខម្តាយ ។

ក្រោយមក អង្គការបានប្ហូរម្តាយ សុធា ពីកងមនុស្សចាស់ឲ្យមកធ្វើការនៅកងចល័តជា មួយប្ហូនស្រីពៅគាត់ឈ្មោះ លឹមស្រីពៅ (ត្រូវជាមីងរបស់ សុធា) លើកទំនប់អាងទំលែងវិញ ។ មីងរបស់ សុធា ជាអ្នកដែលចូលចិត្តសប្បាយ និងតុបតែងខ្លួន និងស្លៀកតែខោជើងធំប៉ុណ្ណោះកាលពីសម័យមុន ហើយនៅក្នុងសម័យខ្មែរក្រហមគាត់មិនសូវសកម្មក្នុងការងារទេ ហើយតែងតែឈឺ ។ ដោយសារមូលហេតុនេះហើយ ទើបឈ្លបសួរទៅមីងរបស់ សុធា និងប្តី (ត្រូវជាពូរបស់ សុធា) ដើម្បីផ្ទាស់ឲ្យទៅដាំដំឡូងវិញ ។ ព្ទដូច្នេះ ម្តាយរបស់ សុធា ក៏សុំទៅតាមប្ហូនស្រី ។ ក្រោយពីអង្គការយកម្តាយ, មីង និង ពូ របស់ សុធា ទៅបាត់រយៈពេលបីថ្ងៃ សុធា ឃើញឈ្លបខ្មែរក្រហមយកខោអាវមីងរបស់គាត់ដែលគាត់នៅចំណាំថា មានខោជើងប៉ាត់ និងអាវចម្រុះពណ៍ជាច្រើនដែលមីងគាត់ចូលចិត្តស្លៀកពាក់កាលពីនៅរស់ ។ ស្របពេលនោះដែរ បងរបស់ សុធា នៅខាងសេដ្ឋកិច្ចក៏បានប្រាប់ សុធា ថា ម្តាយ

យើងត្រូវខ្មែរក្រហមយកទៅសម្លាប់ចាត់ហើយ ។

នៅចុងឆ្នាំ១៩៧៨ សុធា បានឮស្នូរកាំភ្លើង ពេលនោះកុមារទាំងអស់ចាប់ផ្តើមហ៊ានញ្ជ្រៀវ ព្រោះឮថាអង្គការរំសាយឲ្យត្រឡប់ទៅជួបឪពុកម្តាយវិញ ។ ប៉ុន្តែមួយរយៈខ្លីក្រោយមក ស្រាប់តែប្រធានកងប្រមូលកុមារឲ្យទៅជញ្ជូនស្រូវពីអាងបឹងទំលែង យកទៅលាក់ទុកនៅស្តុកប្រវឹក ស្ថិតនៅក្នុងព្រៃ (តាមបណ្តោយជួរភ្នំដងរែក) វិញ ។ នៅទីនោះ ខ្មែរក្រហមបានឲ្យ សុធា រស់នៅជាក្រុម និង ហូបតែបបរប៉ុណ្ណោះ ។ នៅពេលយប់ឡើងខ្មែរក្រហមបានចាត់កុមារឲ្យដ្ឋាស់រ៉ែនគ្នាដើម្បីយាម ព្រោះពេលនោះមានកើតចោរព្រៃ ហើយតែងតែលួចចូលមកភូមិ ។ ថ្ងៃមួយពេលកំពុងដេក ស្រាប់តែ សុធា ឮ កុមារក្នុងកងស្រែកថា «ចោរចូលមកហើយ ។» ទើប សុធា ក្រោកវត់ទាំងមមីមមើ ។

សុធា នៅស្តុកប្រវឹក រហូតដល់កងទ័ពវៀតណាមចូលមកឆ្នាំ១៩៧៩ ទើបគាត់ត្រឡប់មកបឹងទំលែងវិញ ។ នៅទីនោះ សុធា បានជួបនឹងបងស្រីគាត់ម្នាក់ដែលរស់នៅជាមួយប្រធានកងកុមារ រួចហើយបាននាំគ្នារត់ភៀសខ្លួនតាមខ្មែរក្រហម ។ សុធា និងបងស្រីបានទៅរស់នៅជាមួយប្រជាជនមូលដ្ឋាន (ខ្មែរក្រហម) នៅលើភ្នំដងរែក នៅក្នុងខេត្តបាត់ដំបង ។ ប៉ុន្តែនៅទីនោះ សុធា តែងតែចល័ត ព្រោះកងទ័ពវៀតណាមវាយចូលមក ។ ក្រោយមក ក៏អស់ស្បៀង ទើបប្រធានកងកុមារ ប្រាប់បង សុធា និង សុធា ថា ប្រសិនបើរស់នៅដូច្នេះទៀតនឹងស្លាប់មិនខាន ដូច្នេះត្រូវត្រឡប់ទៅក្រោយវិញទោះបីត្រូវវៀតណាមវ៉ះពោះក៏ដោយ ជំនាន់នោះមានពាក្យចចាមអារ៉ាមថា ប្រសិនបើវៀតណាមចាប់ខ្លួនបានវៀតណាមនឹងអាក និងវ៉ះពោះ ។ នៅពេលយប់ឡើង ខ្មែរក្រហមចាប់ផ្តើមចល័តទៅមុខឆ្ងៀតឱកាសនោះ កងរបស់ សុធា ដែលមានសមាជិកទាំងអស់ប្រមាណជាង១០ នាក់ក៏ធ្វើដំណើរត្រឡប់មកក្រោយវិញ ។ សុធា បានដើរឆ្លងស្ទឹងសំដៅទៅលាច (ទីប្រជុំជនស្រុកក្រវ៉ាញ) ខេត្តពោធិ៍សាត់ ។ នៅតាមផ្លូវ សុធា បានជួបនឹងឈ្លបខ្មែរក្រហមបីនាក់ ដែលកាន់កាំភ្លើងអាការគ្រប់ដៃ ។ ឈ្លបទាំងនោះបាននាំកងរបស់ សុធា ទៅយកស្រូវសាឡីមកដាំលាយជាមួយគ្រប់ពុតលំញ្ជង់ហូប ។

កងរបស់ សុធា បានស្នាក់នៅជាមួយឈ្លបខ្មែរក្រហមរយៈពេលបីថ្ងៃ ទើបបន្តដំណើរទៅមុខទៀត ។ នៅតាមផ្លូវ ធា បានជួបនឹងកងទ័ពវៀតណាម ទើបវៀតណាមដឹកគាត់យកទៅដាក់នៅជំរំប្រមូលផ្តុំនៅលាច ។ ក្រោយមក ទើបប្រធានកងប្រាប់ សុធា និងបងស្រីឲ្យត្រឡប់ទៅស្រុកកំណើតវិញ ប៉ុន្តែពេលនោះ ប្រធានភូមិក៏សុំយក សុធា និងបងស្រីទៅរស់នៅជាមួយរយៈពេលមួយឆ្នាំ ។ មួយរយៈក្រោយមក បងរបស់ សុធា បានទទួលដំណឹងពីអ្នកវត់ពន្ធទំនិញទៅលក់នៅខេត្តពោធិ៍សាត់ប្រាប់ថា បានឃើញបងប្រុសរបស់គាត់ សាំង សុធី រស់នៅខេត្តស្វាយរៀង ទើប សុធា និងបងស្រីដិះរនេះភ្លើងត្រឡប់មករកបងប្អូននៅស្រុកកំណើតវិញ ។

សុធា បានរស់នៅជួបជុំបងប្អូនវិញ ។ ក្រោយមក សុធា បានចូលរៀន ហើយបច្ចុប្បន្ន សុធា ធ្វើការឲ្យការសែតក្នុងស្រុកដ៏មានប្រជាប្រិយមួយនៅក្រុងភ្នំពេញ ។

សោម ប៊ុនថន

រ៉ែនរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខ: (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខ: (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

ខ្ញុំម្នាក់ប៉ុណ្ណោះ ដែលមានជីវិតរស់

អ៊ុន ឈាម

«២០ ខសភា សម្រាប់ខ្ញុំ គឺជាថ្ងៃចងចាំដង និងថ្ងៃឈឺចាប់ដង គឺរបបខ្មែរក្រហមនេះហើយ ដែលបានធ្វើឲ្យខ្ញុំបាត់បង់ឪពុកម្តាយ និងបងប្អូនប្រុសស្រីជ្រាំបីនាក់ ។ ទីបំផុត បន្ទាប់ពីរបបនេះដួលរលំ ក្នុងចំណោមគ្រួសារដែលមានសមាជិកចំនួន១១នាក់ គឺនៅសល់តែខ្ញុំម្នាក់ប៉ុណ្ណោះ ដែលនៅមានជីវិត» ។

ទាំងនេះ គឺជាការរៀបរាប់ប្រកបដោយក្តីទុក្ខព្រួយរបស់លោកតា អ៊ុន ឈាម ដែលបានមកចូលរួមក្នុងទិវានៃការចងចាំពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហម នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤នេះ ។ ជារៀងរាល់ឆ្នាំ ឈាម តែងតែមកចូលរួមក្នុងពិធីនេះ ដើម្បីបង្សុកូលឧទ្ទិសកុសល ផលបុណ្យទៅឲ្យឪពុកម្តាយ បងប្អូន ញាតិមិត្ត ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ ទោះបីជាមានវ័យ៧៧ឆ្នាំហើយក៏ដោយ តែគាត់មានសុខភាព និងរាងកាយមាំមួនជាងមនុស្សចាស់មួយចំនួនដែលមានវ័យស្របាលគាត់ ។

អង្គុយជជែកគ្នា រំពឹកពីរឿងរ៉ាវដែលកើតឡើងក្នុងរបបខ្មែរក្រហមក្រោមម្លប់ឈើក្នុងបរិវេណសារមន្ទីរប្រល័យពូជសាសន៍ជើងឯក ឈាម បានរៀបរាប់ពីបទពិសោធដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមប្រាប់ខ្ញុំ ទោះបីជាគាត់មានការភ្លេចភ្លាំងខ្លះ ព្រោះហេតុការណ៍ទាំងនេះបានកន្លងផុតទៅជាងសាមសិបឆ្នាំហើយក៏ដោយ តែគាត់ព្យាយាមប្រាប់ខ្ញុំដោយយកចិត្តទុកដាក់ ។

គ្រួសារ

អ៊ុន ឈាម មានស្រុកកំណើតនៅស្រុកពារាំង ខេត្តព្រៃវែង ។ គាត់រស់នៅក្នុងគ្រួសារធំមួយ ដែលមានសមាជិកទាំងអស់១១នាក់ គឺ ឪពុកម្តាយ និងបងប្អូនប្រុសស្រី៩នាក់ រាប់ទាំងគាត់ដង ។ ឈាម បានរៀនត្រឹមថ្នាក់ទី៧ ប៉ុណ្ណោះ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ឈាម បានចាកចេញពីផ្ទះតែម្នាក់ឯងមកធ្វើការនៅភ្នំពេញ និងបានរៀបការ និងមានកូនម្នាក់នៅពេលនោះ ។ គាត់ និងប្រពន្ធឈ្មោះ អេម រស់នៅភូមិសាក់សំពៅ (ក្នុងខណ្ឌដង្កោបច្ចុប្បន្ន) ។ គាត់ បានមកធ្វើការនៅសាលា អ៊ី.អ៊ិន.អេស រហូតដល់ថ្ងៃដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ពេលដែលយោធាខ្មែរក្រហមចូលមកដល់ភ្នំពេញ ឈាម កំពុងតែធ្វើការនៅសាលា បន្ទាប់មក គាត់បានចេញមកជួបប្រពន្ធកូនគាត់ មុនពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញ ។ មិនខុសពីប្រជាជននៅក្នុងទីក្រុងទេ ឈាម និងគ្រួសារ ត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីផ្ទះ ដោយប្រាប់ថា ឲ្យចាកចេញតែបីថ្ងៃប៉ុណ្ណោះ ។

ខេត្តតាកែវ

ឈាម និងគ្រួសារ ត្រូវខ្មែរក្រហមជម្លៀសទៅខេត្តតាកែវ ដែលជាទិសដៅដំបូងនៃការចេញដំណើររបស់គ្រួសារគាត់ ។ ប៉ុន្តែការជម្លៀសទៅខាងខេត្តតាកែវនេះ គ្រាន់តែទៅរស់នៅបណ្តោះអាសន្ន គឺរយៈពេលត្រឹមតែពីរបីខែប៉ុណ្ណោះ ។ ធ្វើដំណើរដោយថ្មើរជើងជាច្រើនថ្ងៃ ទីបំផុត គ្រួសាររបស់ ឈាម បានទៅដល់ខេត្តតាកែវ ។ ដំបូង អង្គការមិនទាន់បែងចែកការងារដល់ប្រជាជនទេ ។ ចំណែក ការហូបចុក ក៏មិនលំបាកអ្វីដែរ គឺអាចហូបចុកជាឯកជនបាន ហើយប្រជាជនមូលដ្ឋាន ក៏មិនបានធ្វើបាបអ្វីដល់អ្នកជម្លៀសដែរ ។ មិនតែប៉ុណ្ណោះ អ្នកភូមិតែងតែផ្តល់អាហារ ឬថ្នាំសង្ហរដល់អ្នកជម្លៀសទៀតផង ។

ដំណើរតាមរថភ្លើង

ពីរខែក្រោយមក ឈាម និងគ្រួសារ ព្រមទាំងប្រជាជន

មួយចំនួនទៀត ត្រូវអង្គការជម្លៀសបន្តតាមរថភ្លើងទៅកាន់ខេត្តបាត់ដំបង ។ មានមនុស្សជាច្រើននៅលើរថភ្លើង តែ ឈាម មិនដឹងថាអ្នកទាំងអស់នោះមកពីភូមិស្រុកណាខ្លះទេ ។ អំឡុងពេលធ្វើដំណើរតាមផ្លូវ ខ្មែរក្រហមបានចែកអង្ករឲ្យម្នាក់ៗប្រាំកំប៉ុងរួមជាមួយត្រីងៀតខ្លះ ។ ដូចនេះ ឈាម មានសមាជិកបីនាក់ គឺទទួលបាន១៥កំប៉ុង ហើយពេលដល់កន្លែងដែលមានទឹក ខ្មែរក្រហមផ្អាកដំណើរដើម្បីអនុញ្ញាតឲ្យប្រជាជនឈប់ដាំបាយហូបសិន មុននឹងបន្តដំណើរទៅមុខទៀត ។

ទៅដល់ស្នាយមាន់

បន្ទាប់ពីធ្វើដំណើរមួយយប់មួយថ្ងៃ ឈាម និងគ្រួសារបានមកភូមិស្នាយមាន់ ។ ឈាម ចាំមិនច្បាស់ថា ភូមិស្នាយមាន់នេះស្ថិតនៅក្នុងឃុំស្រុកអ្វីនោះទេ ។ ទៅដល់ដំបូង អង្គការតម្រូវឲ្យអ្នកជម្លៀសទាំងអស់ស្វែងរកទីកន្លែងស្នាក់នៅតាមគ្រួសាររៀងៗខ្លួន ។ ឈាម បន្តថា គាត់ និងគ្រួសារហាក់បីដូចជាសំណាង ព្រោះគ្រប់ទីកន្លែងដែលគាត់ជម្លៀសទៅដល់ សម្រាប់រូបគាត់ និងប្រពន្ធកូនមិនសូវលំបាកខ្លាំងនោះទេ តែផ្ទុយទៅវិញ គាត់ទទួលបានការអាណិតស្រឡាញ់ពីកម្មាភិបាល ក៏ដូចជាប្រជាជនមូលដ្ឋានទៅវិញ ។ ចំណែកឯការធ្វើការងារក្នុងកងវិញ គឺតែងតែជួបប្រធានកងដែលមានចិត្តល្អ និងមានអធ្យាស្រ័យជានិច្ច ។ ពេលនៅស្នាយមាន់ អង្គការចាត់តាំង ឈាម ឲ្យធ្វើការនៅកងដាំបន្លែ ។ ការរស់នៅស្នាយមាន់សម្រាប់ ឈាម និងគ្រួសារ មិនសូវលំបាកនោះទេ ជាពិសេសការហូបចុក ទោះបីជាទទួលរបបអាហារតែពីរពេលក្នុងមួយថ្ងៃក៏ពិតមែន តែបានហូបគ្រប់គ្រាន់ ដោយពេលខ្លះបាយ ហើយពេលខ្លះទៀតបបរ និងមានបន្លែមខ្លះទៀតផង ។

ផ្លាស់បន្តមកកកោះ

ឈាម និងគ្រួសារ រស់នៅស្នាយមាន់ បានត្រឹមមួយរយៈប៉ុណ្ណោះ ។ ក្រោយមក អង្គការបានផ្លាស់គាត់ និងគ្រួសារ ជាមួយនឹងប្រជាជនមួយចំនួនទៀតមកនៅកកោះ ។ ឈាម មិនដឹងថាកកោះ ជាភូមិ ឬឃុំស្ថិតក្នុងភូមិស្រុកអ្វីទេ ដឹងត្រឹមតែថា ស្ថិតក្នុងខេត្តបាត់ដំបង ។ មកដល់កកោះ ប្រពន្ធរបស់ ឈាម ត្រូវអង្គការ

ព្រះសង្ឃសូត្រមន្តបង្សុកូលនៅសារមន្ទីរប្រល័យពូជសាសន៍ជើងឯក

ចាត់តាំងឲ្យធ្វើការនៅរោងបាយ និងកូនប្រុសរបស់គាត់ដែលមានវ៉ៃយប្រហែលប្រាំមួយឆ្នាំ ធ្វើនៅក្នុងកងកុមារ ។ ចំណែក ឈាម ត្រូវអង្គការចាត់តាំងមកធ្វើការនៅពេទ្យ ប៉ុន្តែមិនមែនធ្វើពេទ្យនោះទេ ព្រោះពេលនោះ អង្គភាពពេទ្យ អង្គការបានផ្តល់ដីស្រែប្រាំហិកតា សម្រាប់ធ្វើស្រែផ្គត់ផ្គង់អង្គភាពខ្លួន ។ ហេតុនេះ ឈាម និងក្រុមដប់នាក់ទៀត គឺមាននាទីធ្វើស្រែសម្រាប់អង្គភាពពេទ្យ ។ អ្វីដែលប្លែកពីប្រជាជនដទៃដែលកំពុងអត់ឃ្លាន គឺកងរបស់ ឈាម បានហូបចុកគ្រប់គ្រាន់ ដោយពេលថ្ងៃត្រង់ នារីនៅអង្គភាពពេទ្យ យកបាយទៅឲ្យដល់ស្រែ ហើយលើសពីនេះទៅទៀត មានបង្អែមហូបក្នុងមួយអាទិត្យពីរដងទៀតផង ។

ចំពោះការរស់នៅជាមួយគ្រួសារវិញ ស្របពេលដែលប្រជាជនដទៃត្រូវអង្គការបំបែកឲ្យរស់នៅបែកឆ្ងាយពីគ្រួសារនោះ ឈាម មិនបានរស់នៅបែកពីប្រពន្ធ និងកូននោះទេ គឺរៀងរាល់យប់ បន្ទាប់ពីសម្រាកពីការងារ គាត់អាចត្រឡប់មកសម្រាកជួបជុំប្រពន្ធកូនវិញ ។

ការរស់នៅកកោះនេះ គ្រួសាររបស់ ឈាម និងប្រជាជនដទៃទៀត ហាក់ដូចជាមិនសូវលំបាកប៉ុន្មានទេ ដោយមានការហូបចុកគ្រប់គ្រាន់ ។ ទោះបីជាហូបរួមក៏ពិតមែន តែមានពេលខ្លះមានបាយ បបរ និងត្រីផៀតហូបទៀតផង ។ ឈាម មិនដឹងថា តើកន្លែងដទៃដូចគាត់ដែរឬយ៉ាងណាទេ? ប៉ុន្តែ ពេលគាត់ដើរកាត់ការដ្ឋានគាត់សង្កេតឃើញថា ប្រជាជនជាច្រើនស្គមស្គាំង សល់តែស្បែកដណ្តប់ឆ្អឹង ។ គាត់គិតថា អ្នកទាំងនោះខ្វះខាត និងហូបមិនគ្រប់គ្រាន់ ព្រោះម្នាក់ៗធ្វើការលើកដើងដើរស្ទើរតែមិនរួចផង ។ ឈាម ពិតជាឆ្ងល់ណាស់ថា ហេតុអ្វីកន្លែងខ្លះមានហូបគ្រប់គ្រាន់ ហើយកន្លែងខ្លះបែរជាគ្មានហូបទៅវិញ ។ ជាក់ស្តែង ដូចជាកន្លែងដែល ឈាម រស់នៅទោះបីជាអង្គការចាត់តាំងឲ្យធ្វើការគ្មានពេលកំណត់ច្បាស់លាស់មែន តែការហូបចុកគ្រប់គ្រាន់ ហើយម៉ោងធ្វើការគឺមិនមានកំណត់ត្រឹមត្រូវនោះទេ គឺសម្រាកបានតែពេលហូបបាយ បបរ ប៉ុណ្ណោះ ។ ឈាម ធ្វើស្រែនៅកកោះ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាមចូលមករំដោះ ។

វត្តមានកងទ័ពវៀតណាម

ថ្ងៃមួយពេលដែល ឈាម កំពុងធ្វើស្រែស្រាប់តែឃើញយន្តហោះហោះពីលើ តែគាត់ក៏មិនចាប់ភ្លឹកអ្វីដែរ ។ ប៉ុន្មានថ្ងៃបន្ទាប់មកទៀត ឈាម ក៏ឃើញយោធាខ្មែរក្រហមជាច្រើនឡានជិះកាត់តាមកកោះ តែគាត់មិនដឹងថាតើយោធាទាំងនោះទៅណានោះទេ ។ មិនយូរប៉ុន្មាន កងទ័ពវៀតណាមបានវាយមកដល់កកោះ កម្មាភិបាលខ្មែរក្រហមបាននាំគ្នារត់គេចអស់ ប្រជាជនទាំងអស់បាននាំគ្នារត់ត្រឡប់ក្រោយវិញ ។ ពេលដែលកំពុងតែជ្ជួលច្របល់ ឈាម បានបែកពីប្រពន្ធ និងកូន តែជាសំណាង គាត់បានមកជួបប្រពន្ធកូនវិញ នៅមោងបុស្ស៊ី ។

ចាប់ផ្តើមជីវិតថ្មី

បន្ទាប់ពីបានជួបជុំគ្នាវិញ ឈាម និងប្រពន្ធបាននាំគ្នាបន្តដំណើរមកភ្នំពេញ ។ មកដល់ភ្នំពេញ គាត់ និងគ្រួសារបានមកស្នាក់នៅសាលា អឺ.អិន.អេស អតីតកន្លែងដែលគាត់ធ្លាប់ធ្វើការពីមុន ។ បន្ទាប់ពីរស់នៅទីនោះបានពីរខែ ឈាម បានសម្រេចចិត្តមករស់នៅផ្ទះចាស់របស់ខ្លួនវិញ នៅភូមិសាក់សំពៅ និងបន្តរស់នៅរហូតដល់បច្ចុប្បន្ន ។ មកដល់ភ្នំពេញដំបូង នៅអំឡុងឆ្នាំ១៩៨០-១៩៨១ ឈាម បានចូលធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាសាក់សំពៅ ។ អំឡុងពេលដែលគាត់បង្រៀន គាត់តែងតែដឹកនាំសិស្សទៅទស្សនានៅដើងឯក និងទួលស្លែង ដើម្បីឲ្យសិស្សទាំងអស់បានដឹង និងស្គាល់ពីរបបខ្មែរក្រហមដែលទើបតែបញ្ចប់ទៅថ្មីៗនេះ ។

ឈាម បានបែកពីគ្រួសារទាំងអស់ចាប់តាំងពីថ្ងៃដែលគាត់ចាកចេញមកធ្វើការនៅភ្នំពេញម្ល៉ះ ហើយថ្ងៃនោះ ក៏ជាថ្ងៃចុងក្រោយរបស់គាត់ដែលបានឃើញមុខសមាជិកគ្រួសារទាំងអស់ដែរ ។ បន្ទាប់ពីធ្វើគ្រូបង្រៀនបានជាងមួយឆ្នាំ គាត់បានផ្លាស់មកធ្វើការនៅក្រសួងកសិកម្ម រហូតដល់ថ្ងៃចូលនិវត្តន៍ ។

បច្ចុប្បន្ន ឈាម រស់នៅភូមិសាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាមួយនឹងប្រពន្ធ និងកូនប្រុសស្រីបួននាក់ ។ ទោះបីជារបបខ្មែរក្រហមកន្លងផុតទៅជាងសាមសិបឆ្នាំហើយក៏ដោយ តែសម្រាប់ ឈាម ហាក់ដូចជានៅថ្មីៗ ហើយក៏មិនអាចយកអ្វីមកសងគាត់វិញបាននូវភាពឈឺចាប់ចំពោះការបាត់បង់ឪពុកម្តាយ និងបួនទាំងប្រុសស្រីទាំងប្រាំបីនាក់របស់គាត់បានដែរ ។

ធាវ សារៈមុនិន្ទ

ឈួន ណាវែន : ដេកយាមស្រូវ ត្រូវវាយនឹងដងច្រវា

ឈួន ណាវែម

ក្នុងទិវារំឭកដល់ថ្ងៃបង្ករាំពីអំពើប្រល័យពូជសាសន៍ ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៤ បុរសចំណាស់មាឌធំ ស្ថិតនៅក្នុងវ័យជាង៥០ឆ្នាំ សព្វថ្ងៃជាបុគ្គលិកនៅមន្ទីរសិល្បៈ និងវៀតរត់ឡានផង បានអង្គុយតែម្នាក់ឯងដោយភ្នែកសម្លឹងមើលរណ្តៅសាកសព ។ គាត់មានឈ្មោះថា ឈួន ណាវែន មានស្រុកកំណើតនៅឃុំផ្ទះកណ្តាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ណាវែន មានបងប្អូនបួននាក់ និងមានឪពុកឈ្មោះ មែន ឃីម អតីតគ្រូបង្រៀន និងម្តាយឈ្មោះ ឃីម សុឡី ជាមេផ្ទះ ។

នៅថ្ងៃរដ្ឋប្រហារ១៨ ខែមីនា ឆ្នាំ១៩៧០ វែន មានអាយុ ១០ឆ្នាំប៉ុណ្ណោះ រស់នៅជាមួយក្រុមគ្រួសារនៅស្រុកកំណើតដែលស្ថិតនៅក្នុងតំបន់រំដោះ លើកលែងតែឪពុកគាត់ជាគ្រូបង្រៀនធ្វើការនៅទីរួមខេត្ត ទើបស្ថិតនៅក្នុងតំបន់គ្រប់គ្រងរបស់ លន់ នល់ ។ ដោយសារតំបន់រំដោះ មានក្រុមខ្មែរក្រហមឃោសនា អ្នកភូមិជាច្រើនបានសុខចិត្តចូលបម្រើកងទ័ពរំដោះដោយស្ម័គ្រចិត្ត ។ ពេលចូលក្នុងជួរកងទ័ពរំដោះនោះ គឺយើងសប្បាយរីករាយ ដឹកស៊ីរាំច្រៀង ដោយភ្លេចអស់ពីការបោកបញ្ឆោតរបស់ខ្មែរក្រហម ។ នៅពេលខ្មែរក្រហមក្តោបក្តាប់ប្រទេសកម្ពុជាទាំងមូល នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ រយៈពេលពីរឬបីថ្ងៃបន្ទាប់ គ្រួសាររបស់ វែន ត្រូវខ្មែរក្រហមជម្លៀសទៅស្រុកស្ទោង ក្នុងខេត្តកំពង់ធំ ជាទីដែលគ្រួសាររបស់គាត់ ត្រូវរងទុក្ខវេទនាគ្មានស្រាកស្រាន្តក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនៅទីនោះ ។

វែន និងក្រុមគ្រួសារត្រូវធ្វើការនៅក្នុងកងចល័តផ្សេងគ្នា ដោយត្រូវបែងចែកទៅតាមអាយុរៀងៗខ្លួន ។ គ្រួសាររបស់ វែន ត្រូវធ្វើការងារនៅកន្លែងឆ្ងាយពីគ្នា តែពេលយប់អាចមកដេករួមគ្នានៅក្នុងផ្ទះមួយអតីតជាកម្មសិទ្ធិរបស់ចៅកែម៉ាស៊ីនស្រូវ ។ នៅក្នុងកងចល័តឃុំដែលមានគ្នារាប់រយនាក់នោះ វែន ត្រូវធ្វើការងារវែកដី លើកភ្លឺ ជីកប្រឡាយ ស្ទូង និងច្រូតស្រូវ និងធ្វើការងារផ្សេងតាមការស្នើ ។ ចំណែកឪពុករបស់គាត់ត្រូវវែកដី ក្នុងកងចល័តវ័យកណ្តាល ហើយម្តាយវិញត្រូវដាំបន្លែ ។ ក្នុងវ័យប្រមាណ១៥ឆ្នាំ វែន ចូលជាកងចល័តឃុំ ដែលត្រូវធ្វើការងារធ្ងន់ធ្ងរ ដោយមានពេលមួយនោះគាត់ត្រូវប្រធានកងចល័តវាយយ៉ាងដំណំ ។ វែន ធ្វើការពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់ ហើយពីម៉ោង២ថ្ងៃត្រង់ ដល់ម៉ោង៥ល្ងាច ។ ក្នុងរបបខ្មែរក្រហម ការគោរពពេលវេលាត្រូវរក្សាឲ្យបានខ្ជាប់ខ្ជួន ទោះបីជាមានភ្លៀងក៏ដោយ កងចល័តទាំងអស់ត្រូវតម្រង់ជួរដើរចេញទាំងអស់គ្នា ។ ចំពោះការហូបចុកវិញ ប្រសិនបើជាបក្ខពួករបស់ចុងភៅ នោះចុងភៅដួសឲ្យបានច្រើនបន្តិច ប៉ុន្តែបើមិនមែនជាបក្ខពួកទេ ជួនកាលទទួលបានតែសម្លដែលគ្មានត្រី ។ នៅរដូវច្រូត ការហូបចុកទទួលបានគ្រប់គ្រាន់ ជារឿយៗទទួលបានបាយមួយស្រាក់ក្នុងមួយពេលរួមជាមួយ នឹងសម្ល ។

ក្នុងការងារជាកងចល័តឃុំ វែន ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការជាច្រើនកន្លែង ។ គាត់ធ្លាប់ទៅជីកប្រឡាយដល់ស្ទឹងជីនិត និងទំនប់១មករា ។ ការងារជីកប្រឡាយនោះ មានការលំបាកយ៉ាងខ្លាំង ដោយសារតែត្រូវធ្វើការងារក្រោមកម្តៅថ្ងៃ និងធ្វើការងារច្រើនម៉ោង ។ មានមនុស្សជាច្រើន បានដេកដួលសន្លប់ពេលកំពុងស្ទូង តែបានអ្នកធ្វើការក្នុងកងចល័តរួមគ្នាជួយ ។ វែន ធ្លាប់ឃើញ

ហេតុការណ៍ដ៏គួរឲ្យរន្ធត់នៅពេលមនុស្សជាច្រើនត្រូវចង់បន្ពកន្ទុយគ្នា រួចឈ្លបខ្មែរក្រហមវាយក្បាលអ្នកទាំងនោះពីក្រោយ ។ រែនមិនហ៊ានសួរដេញដោលពីការសម្លាប់នោះទេ គ្រាន់តែបានដឹងថាអ្នកទាំងនោះគឺជាខ្មាំង ។ រែន បានស្គាល់អត្តសញ្ញាណអ្នកដែលត្រូវសម្លាប់ម្នាក់ជាអ្នកស្រុកភូមិរបស់ខ្ជួនផ្ទាល់ ជាអតីតគ្រូបង្រៀនដែលបានប្រព្រឹត្តកំហុស ។ សម្រាប់ស្រុកភូមិដែល រែន រស់នៅចំពោះអតីតកាលជាគ្រូបង្រៀន អង្គការមិនបានចាត់ថាជាខ្មាំងនោះទេ ។ អតីតគ្រូបង្រៀនទាំងអស់ អាចប្រាប់នូវប្រវត្តិរបស់ខ្ជួនបាន ហើយក៏មិនមានការយកទោសពៃរ៍ដែរ ។ តែការសម្លាប់អតីតគ្រូបង្រៀនម្នាក់នេះមិនមែនជាការជាប់ទាក់ទងទៅនឹងប្រវត្តិរូបទេ ។

មានគ្រាមួយ រែន បានទៅលេងផ្ទះពូរបស់ខ្ជួន ហើយចៃដន្យគាត់បានឃើញយោធាខ្មែរក្រហម បានចាប់ចង់អឹរបស់ខ្ជួន ។ រែន ភ័យតក់ស្ទុតយ៉ាងខ្លាំង ចំណែកប្រពន្ធ និងកូនប្រុសអឹរបស់គាត់ឈ្មោះ មាស បានស្រែកយំនៅលើផ្ទះយ៉ាងខ្លាំង ។ គ្រាន់តែឃើញដូច្នេះ រែន បានលាក់ខ្ជួន ហើយរត់ចេញមកក្រៅ សំដៅទៅផ្ទះរបស់ខ្ជួន ។ មួយខែក្រោយមក រែន ទទួលដំណឹងថា កូនប្រុសនិងប្រពន្ធអឹរបស់គាត់ ត្រូវឈ្លបខ្មែរក្រហមយកទៅសម្លាប់ទៀត ។

រៀងរាល់ថ្ងៃ រែន ត្រូវលត់ដំទាំងកម្លាំងកាយ និងសតិអារម្មណ៍ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យដំអក់មិនចង់ធ្វើការនោះទេ ។ អង្គការតែងលើកឡើងថា យើងវាយចក្រពត្តិអាមេរិកបានគ្រាន់តែការងារប៉ុណ្ណោះ ហេតុអ្វីធ្វើមិនបាន ។ កង់ប្រវត្តិសាស្ត្រកំពុងវិលទៅមុខ ហើយប្រសិនបើបុគ្គលណារារាំង កង់ប្រវត្តិសាស្ត្រនោះនឹងកាត់ដៃនិងជើងបុគ្គលនោះ ។ រែន ធ្លាប់ត្រូវចាត់តាំងឲ្យទៅយាមស្រូវ ដែលក្នុងមួយក្រុមមានគ្នាបួននាក់ ។ អ្នកទាំងអស់គ្នាត្រូវធ្វើការបត្ថូរវេនគ្នាដើម្បីយាមស្រូវ ។ ថ្ងៃមួយ អ្នកយាម

កម្មាភិបាលខ្មែរក្រហមកំពុងរោយស្រូវ នៅវាលស្រែ

នៅពេលយប់ មិនបានដាស់ រ៉ែន ឲ្យដើរយាមបន្ទន់ដោយសារម្នាក់នោះ បានដេកលង់លក់តាំងពីព្រលប់ ។ យប់នោះប្រធានកងចល័តឈ្មោះ ហាន បានអូសដើង រ៉ែន ទម្លាក់ទឹក ។ ពេលនោះ រ៉ែន បានបដិសេធថា មិនមែនជារ៉ែនរបស់ខ្លួននោះទេ ទោះយ៉ាងណាហាន មិនស្តាប់ហេតុផល រួចហើយបានយកច្រវ៉ាដាយ រ៉ែន តែម្តង ។ រ៉ែន មិនហ៊ានធ្វើអ្វីឡើយ គ្រាន់តែមានចិត្តចង់តំនុំក្នុងខ្លួនទាំងសួរខ្លួនឯងថាតើហេតុអ្វីបានជាមនុស្សមានចិត្តសាហាវយ៉ាងដូច្នេះ?

នៅពេលជួបជាមួយកងចល័តជាមិត្តភក្តិរបស់ខ្លួន រ៉ែន បានជជែកពីរឿងនោះ ដោយនឹកគិតថា សង្គមនឹងមិនទៅជារបៀបនេះទេ ។ ភាពអត់ឃ្លាន ការខ្វះខាតអាហារហូបចុក បានធ្វើឲ្យកងចល័តទាំងមូលបាក់កម្លាំង ធ្វើការងារធ្ងន់ធ្ងរលែងកើត ។ មិត្តភក្តិជិតស្និទ្ធម្នាក់របស់រ៉ែន ឈ្មោះ លុច ដែលនៅក្នុងកងចល័តរួមគ្នា និងមានអាយុប្រហាក់ប្រហែលគ្នានោះ បានដេកស្ងាប់ក្នុងទឹកបឹងពេលទៅបេះព្រលិត ព្រោះមិនអាចដើរចេញពីទឹកភក់បានដោយសារតែភាពហេវហត់ ។ សូម្បីតែ រ៉ែន ក៏ធ្លាប់ជាប់ក្នុងបឹងដែរ តែសំណាងល្អត្រូវបានកងចល័តដទៃជួយ ។

ចំពោះគ្រួសាររបស់ រ៉ែន ដោយសារភាពអត់ឃ្លានបានធ្វើឲ្យបួនៗរបស់គាត់នៅក្នុងកងចល័តកុមារត្រូវបង្ខំចិត្តលួចបេះក្តឹបត្រលាចរបស់ខ្មែរក្រហម ពេលនោះហើយដែលខ្មែរក្រហមវាយបួនរបស់ រ៉ែន បែកមាត់ ។ សូម្បីសត្វថ្លែន និងបង្ហ្ស ក៏ រ៉ែន និងបួនដេញចាប់ដើម្បីយកមកដុតហូបបំបាត់ការអត់ឃ្លានដែរ ។ ភាពអត់ឃ្លាននេះដែរ បានធ្វើឲ្យពួកម្នាក់ឈ្មោះ ចុិល មកពីស្រុកភូមិជាមួយ រ៉ែន បានលួចដំឡូង រួចត្រូវខ្មែរក្រហមវាយនៅចំពោះមុខមហាជន ។ ដោយឃើញសភាពបែបនោះ កូនរបស់គាត់បានរត់ទៅជួយ ហើយក៏ត្រូវខ្មែរក្រហមវាយទាំងកូននោះទៀត ។ តែក្រោយមក ខ្មែរក្រហមយកតែពួ ចុិល ម្នាក់ប៉ុណ្ណោះទៅសម្លាប់ចោល ។

នៅសម័យនោះ ក៏មានការលើសអើងខ្លាំងដែរ ទោះបីជាក្នុងចំណោមប្រជាជនធម្មតាក៏ដោយ ។ ប្រជាជនមូលដ្ឋាន តែងតែស្អប់ចំពោះប្រជាជនថ្មី ។ ក្នុងនោះដងដែរ ប្រជាជនមូលដ្ឋានមិនត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយប្រជាជនថ្មីនោះទេ ។ តែស្ថានភាពបានធូរស្រាលឡើងវិញ នៅពេលដែលរបបខ្មែរក្រហមជិតត្រូវបានរំលំនៅចុងឆ្នាំ១៩៧៨ ។ ប្រធានឃុំ និងប្រធានកងចល័តថ្មីមកពី ភូមិភាគនិរតីបានចូលកាន់តាប់នៅតំបន់របស់ រ៉ែន ហើយការរស់នៅបានធូរស្រាលជាងមុន ។ ប្រជាជនទាំងអស់អាចរៀបការជាមួយគ្នាបាន មិនមានការប្រកាន់ប្រជាជនថ្មីឬប្រជាជនមូលដ្ឋាននោះទេ ។ ការហូបចុកទទួលបានគ្រប់គ្រាន់ជាងមុន ។ ប្រធានកងចល័តថ្មីឈ្មោះ ចយ បានឲ្យចុងភៅដាំអង្ករ ៨០ កំប៉ុងក្នុងមួយពេលសម្រាប់កងចល័ត ។ ចយ បានប្រាប់ថាកងចល័តទាំងអស់ អាចហូបមួយចម្អែតតាមការចង់ តែមិនត្រូវវេចខ្ចប់យកទៅផ្ទះនោះទេ ។ ការរស់នៅកាន់តែស្រួលជាងមុន រហូតដល់ពេលបែក ។

មុនពេលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ខ្មែរក្រហមបានកេណ្ឌប្រជាជនឲ្យទៅតាមខ្លួន ហើយបានឃោសនាប្រជាជនឲ្យខ្លាចវៀតណាម ។ ខ្មែរក្រហមទាំងនោះ បាននិយាយថា វៀតណាមនឹងមកសម្លាប់ប្រជាជនវ៉ះពោះញ្ជាត់ស្មៅ ។ ដោយជឿការឃោសនានោះ ប្រជាជនមួយចំនួនសុខចិត្តទៅតាម ។ ចំណែក រ៉ែន មិនព្រមទៅតាមនោះទេ ។ គ្រួសាររបស់ រ៉ែន ទ្រាំរស់នៅក្នុងស្រុកស្នាងមិនព្រមចាកចេញតាមការឃោសនា ។ មិនយូរប៉ុន្មាន វៀតណាមបានរំដោះស្រុកស្នាង ហើយបានប្រកាសប្រាប់ប្រជាជនទាំងអស់ឲ្យត្រឡប់ទៅកាន់ស្រុកភូមិរបស់ខ្លួនវិញ ។ រ៉ែន និងគ្រួសារសប្បាយរីករាយយ៉ាងខ្លាំង នៅពេលដែលឮវៀតណាមនិយាយដូច្នេះ ។ គ្រួសារ រ៉ែន បានរៀបចំបង្វេចអង្ករ និងក្រោកឡើងតាំងពីម៉ោងពីរទៀបភ្លឺ ដើរសំដៅទៅស្រុកភូមិកំណើតរបស់ខ្លួន ដោយមិនបង្ហង់យូរឡើយ ។

ពេញមួយរបបខ្មែរក្រហម មានតែភាពឈឺចាប់ប៉ុណ្ណោះដែល រ៉ែន បានចងចាំ ជាពិសេស របបមួយនេះបានឆក់យកជីវិតឪពុករបស់ រ៉ែន នៅក្នុងឆ្នាំ១៩៧៨ ដោយមិនដឹងពីមូលហេតុនៃការសម្លាប់ ហើយយាយរបស់គាត់ត្រូវស្លាប់ដោយអត់បាយ ។ រ៉ែន នឹកឃើញដល់រឿងនេះឡើងវិញ រាល់ពេលនិយាយអំពីរបបខ្មែរក្រហម ហើយគាត់តែងតែធ្វើបុណ្យ ដាក់ទាន ឧទ្ទិសដល់បុណ្យជូនដល់ឪពុក និងយាយរបស់ខ្លួន ។

ភួង ច័ន្ទប្រណិត

ទិវាចងចាំ

WOULD YOU PLEAS
KINDLY SHOW YO
RESPECT TO MANY
MILLION PEOPLE
WHO WERE KILLED
UNDER THE GENOCIDAL
POL POT REGIME

២០ ខែឧសភា

WOULD YOU PLEA
KINDLY SHOW YO
RESPECT TO MANY
MILLION PEOPLE
WHO WERE KILLED
UNDER THE GENOCIDAL
POL POT REGIME


RESPECT TO MANY
MILLION PEOPLE
WHO WERE KILLED
UNDER THE GENOCIDAL
POL POT REGIME

RESPECT TO MANY
MILLION PEOPLE
WHO WERE KILLED
UNDER THE GENOCIDAL
POL POT REGIME



វេទិការអប់រំសាធារណៈពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅឃុំ

ខ្សឹម ស្រុកស្ជួល ខេត្តក្រចេះ កាលពីថ្ងៃ២៩ ខែឧសភា ឆ្នាំ២០១៤



សៃមយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០ ០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២ ០ ១ ១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២ ០ ១ ៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ខទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី «សហកម្មខក្រិដ្ឋកម្មរួម» ដែលភាសាអង់គ្លេសហៅថា «Join Criminal Enterprise» ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម «ផែនការខក្រិដ្ឋរួម» ដែលភាសាអង់គ្លេសហៅថា «Common Criminal Plan» ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះប្ថបទអត្ថាធិប្បាយរបស់អ្នកជំនាញ ដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី ៦ ទៅ ៨ ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

រ៉ាន់ថាន់ ពៅដារ៉ា

សំណុំរឿង០០៣ និង ០០៤ : និយមន័យនៃពាក្យអ្នក ឧទ្ធលខុសត្រូវខ្ពស់បំផុតផ្នែកលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិទ្រង់ទ្រាយធំដទៃទៀត មានជាប់ទាក់ទងទៅជនដៃដល់ដែលប្រព្រឹត្តសកម្មភាពទាំងនោះ ។ ដូច្នេះហើយ មានការដាក់ឲ្យទទួលខុសត្រូវចំពោះបុគ្គលដែលប្រព្រឹត្តឧក្រិដ្ឋកម្ម បន្ទាប់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះជាប់ពាក់ព័ន្ធនឹងសេចក្តីសម្រេចដ៏ចម្រូងចម្រាសថា តើបុគ្គលណាត្រូវចោទប្រកាន់ ។ ការប្រឈមនោះត្រូវគូសបញ្ជាក់ ជាឧទាហរណ៍តាមរយៈភាពចម្រូងចម្រាសដែលបន្តនៅក្នុងប្រទេសកម្ពុជាទាក់ទងទៅនឹងវិសាលភាពនៃការចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅស្របពេលដែលសំណុំរឿង០០៣ និង ០០៤ របស់តុលាការបានអូសបន្ទាយ ដោយសារភាពចម្រូងចម្រាសអស់រយៈពេលជាច្រើនឆ្នាំ ។ ឯកសារនេះនឹងពន្យល់ថា តើជនសង្ស័យដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងសំណុំរឿង ០០៣ និង ០០៤ អាចត្រូវបានចាត់ទុកថា ជាបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ក្នុងប្រទេសកម្ពុជាដែរឬយ៉ាងណា ។ តាមរយៈការពិចារណាអំពីព័ត៌មានស្តីពីជនសង្ស័យក្រោមយុត្តាធិការរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយឯកសារនេះនិយាយយោងលើហេតុផលថា ជនសង្ស័យ

តំណាងសហព្រះរាជអាជ្ញា អេនឡូ ប៊ូយល៍ រៀបរាប់ពីដំណើរការស៊ើបអង្កេតនៅសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រាប់ដល់ប្រជាជន និងសិស្សានុសិស្សនៅក្រុងសំរោង ខេត្តឧត្តរមានជ័យ

ទាំងអស់ស្ថិតក្នុងនិយមន័យច្បាប់នៃពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ដោយសារជនសង្ស័យនីមួយៗ ជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ដូច្នេះហើយ យើងអាចសន្មតបានថា មិនមានជម្រើសតាមផ្លូវច្បាប់ណាដែលអាចបញ្ចប់សំណុំរឿងទាំងពីរដើម្បីជួយដល់ការជំនុំជម្រះ ។

សេចក្តីផ្តើម

ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិដទៃផ្សេងទៀត គឺជាការប្រព្រឹត្តទ្រង់ទ្រាយធំមានលក្ខណៈជាក្រុម ។ ដូច្នេះហើយ ការជ្រើសរើសអ្នកដែលត្រូវចោទប្រកាន់បានបង្ហាញអំពីការប្រឈមផ្ទួនៗសម្រាប់អ្នកអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងស្ថានភាពក្រោយកើតមានអំពើយង់ឃ្នង ។ មកដល់ពេលបច្ចុប្បន្ននេះ ក្រោមការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ព្រះរាជអាជ្ញាបានកំណត់ជាសំខាន់លើបុគ្គលដែលមានតួនាទីកាន់អំណាចដ៏សំខាន់ ឬជាប់ពាក់ព័ន្ធឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ស្របពេលជាមួយគ្នានេះតុលាការយោធា ឬតុលាការជាតិថ្នាក់ទាប ត្រូវបានប្រើសម្រាប់ចោទប្រកាន់ជនដៃដល់ប្រព្រឹត្តបទឧក្រិដ្ឋស្រាល ។

ភាពលំបាកក្នុងការកំណត់នូវវិសាលភាពនៃការចោទប្រកាន់ ក្រោយមានឧក្រិដ្ឋកម្មធ្ងន់ធ្ងរ បានបង្ហាញឲ្យឃើញតាមរយៈភាពចម្រូងចម្រាសដែលអូសបន្លាយយ៉ាងយូរទាក់ទងនឹងចំនួនជនសង្ស័យ នឹងត្រូវចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការចម្រុះ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ជាទូទៅត្រូវបានស្គាល់ថា ជាសាលាក្តីខ្មែរក្រហម ។ ខ្មែរក្រហមបានកាន់អំណាចក្នុងប្រទេសកម្ពុជាចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។ អំឡុងពេលនោះ នៅពេលដែលប្រទេសកម្ពុជាត្រូវបានដាក់ឈ្មោះថ្មីជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យ ជនដៃដល់រាប់ពាន់នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិទ្រង់ទ្រាយធំប្រឆាំងនឹងជនរងគ្រោះរាប់លាននាក់ ។ នៅក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់ពីមានការចរចាអូសបន្លាយយ៉ាងយូរ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានយល់ស្របថា តុលាការនឹងមានយុត្តាធិការដាយផ្ទាល់លើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងក្នុងស្រុកដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

ឯកសារនេះនឹងពិចារណាអំពីអត្ថន័យនៃពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ទាក់ទងនឹងភាពចម្រូងចម្រាសក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលបានអូសបន្លាយនៅក្នុងដំណាក់កាលស៊ើបអង្កេតអស់ពេលជាច្រើនឆ្នាំ ។ ជាក់ស្តែង សំណេរនេះ និយាយយោងលើកហេតុផលថា ពាក្យនោះគួរតែត្រូវបានបកស្រាយ

សិស្សវិទ្យាល័យ នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ សួរសំណួរទាក់ទងនឹងដំណើរការកាត

ដោយយោងលើយុត្តិសាស្ត្រនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិទូទៅហើយថា ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿងទាំងពីរ ស្ថិតក្រោមការបកស្រាយតាមផ្លូវច្បាប់នៃពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ។ ដូច្នេះ យើងអាចសន្មតបានថា មិនមានយន្តការផ្លូវច្បាប់ណាក្រៅពីការជំនុំជម្រះ ដើម្បីបញ្ចប់សំណុំរឿង ០០៣ និង ០០៤ ដោយត្រឹមត្រូវនោះទេ ។ ដូច្នេះហើយ កិច្ចខិតខំប្រឹងប្រែងក្នុងការ

បិទសំណុំរឿង ត្រូវតែបង្ហាញតាមសេចក្តីសម្រេចដែលអនុម័ត តាមគោលការណ៍ច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ដើម្បីអាចអះអាងដូច្នេះបាន ត្រូវក្រឡេកមើលប្រវត្តិដ៏ចម្រូងចម្រាសក្នុងសំណុំរឿង០០៣ និង ០០៤ និងពន្យល់អំពីមូលហេតុដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពឹងផ្អែកលើយុត្តិសាស្ត្រនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីបកស្រាយពាក្យ

ត់ទោសមេដឹកនាំខ្មែរក្រហមទៅលោក អេនជ្រូ ប៊ូយល៍

«ទទួលខុសត្រូវខ្ពស់បំផុត» ត្រូវបានធានាដោយច្បាប់ និងភាពចាំបាច់ដែលមានលក្ខណៈសាមញ្ញ ។ បន្ទាប់មក ការពិនិត្យលើយុត្តាធិការនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទាក់ទងនឹងយុត្តាធិកាបុគ្គល និងការវាយតម្លៃលើភាពជាប់ពាក់ព័ន្ធដែលអាចដាក់បន្ទុកបានតាមរយៈតុលាការពិសេសរបស់ប្រទេសសេវ៉ាឡេអូន តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលត្រូវបានបង្ហាញ ។ បន្ទាប់មក យុត្តិសាស្ត្រនេះនឹងត្រូវយកទៅប្រៀបធៀបនឹងអង្គហេតុដែលទាក់ទងនឹងជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ ។ តាមរយៈការវិភាគនេះ យើងអាចនិយាយយោងលើកហេតុផល ដោយសារតែភាពធ្ងន់ធ្ងរនៃបទចោទប្រកាន់ពីអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងជនសង្ស័យនៅក្នុងសំណុំរឿងទាំងពីរ រួមបញ្ចូលជាមួយកម្រិតខ្ពស់នៃការទទួលខុសត្រូវរបស់ជនសង្ស័យនីមួយ ៗ ។ ជនសង្ស័យទាំង៤នាក់ដែលត្រូវបានសន្មតថា ជាប់ទាក់ទងនឹងសំណុំរឿងទាំងពីរ ហើយស្ថិតក្នុងលំដាប់នៃជនដែលត្រូវបានចាត់ទុកថាជា «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទន្ទឹមពេលដែលការសន្និដ្ឋាននេះអាចបង្កបញ្ហាដល់ផ្នែកពាក់ព័ន្ធទាំងផ្លូវនយោបាយ និងហិរញ្ញវត្ថុ តាមរយៈទស្សនៈផ្លូវច្បាប់ ដែលឯកសារនេះបានលើកឡើង ។ វាអាចជាលទ្ធភាពដែលសំណុំរឿងអាចត្រូវបានច្រានចោល ដោយសម្ហាងលើយុត្តាធិការបុគ្គល ។ ទង្វើបែបនេះនឹងជួយដល់សុចរិតភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរងការរិះគន់ក្នុងនាមជាស្ថាប័នច្បាប់មួយ ។ ដូច្នេះហើយ យើងអាចសន្និដ្ឋានថា ប្រសិនបើសំណុំរឿង ០០៣ ឬ ០០៤ ត្រូវបានបញ្ចប់មុនការជំនុំជម្រះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជា ម្ចាស់ជំនួយ និងផ្នែកពាក់ព័ន្ធ ត្រូវទទួលស្គាល់ថា ការខូះខាតធនធាន និងសមត្ថភាពដើម្បីដំណើរការសំណុំរឿង គឺជាមូលហេតុដើម្បីការពារសុចរិតភាពផ្លូវច្បាប់របស់តុលាការ ដូច្នេះហើយ សេចក្តីសម្រេចធ្វើបានតែសំណុំរឿង០០១ និង០០២ប៉ុណ្ណោះ ។

ភាពចម្រូងចម្រាសក្នុងសំណុំរឿង០០៣ និង ០០៤ ក្នុងប្រទេសកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រើប្រាស់ប្រព័ន្ធច្បាប់ «ស៊ីវិលឡ» ដែលមានការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា ប៉ុន្តែការស៊ើបអង្កេតនោះត្រូវធ្វើឡើងក្នុងទ្រង់ទ្រាយធំ ដោយសហចៅក្រមស៊ើបអង្កេតពីរនាក់ ។ សហព្រះរាជអាជ្ញាមានកាតព្វកិច្ចដាក់ជូន «ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ» ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយធ្វើការស៊ើបអង្កេតផ្លូវការលើជនសង្ស័យ នៅពេលដែលសហព្រះរាជអាជ្ញាមានហេតុផល

ក្នុងការជឿដែលថា ជនសង្ស័យមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដោយ ស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតទទួលបានដីកា បញ្ជូនសំណុំរឿងស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ច «ដោយបង្ខំ» ក្នុងការស៊ើបអង្កេតការចោទប្រកាន់នៅក្នុងដីកានោះ ដោយស្វែងរកភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុក មុននឹងចេញដីកា បញ្ជូនរឿងទៅជំនុំជម្រះ ទាំងការជំនុំជម្រះជនសង្ស័យ និងកំណត់ ថាតើការចោទប្រកាន់បែបណា នឹងត្រូវបានវិនិច្ឆយទោស ឬក៏ ច្រានចោលការចោទប្រកាន់ទាំងអស់ដើម្បីបញ្ចប់សំណុំរឿង ។ សំណុំរឿង០០៣ និង ០០៤ កំពុងស្ថិតក្នុងដំណាក់កាលនៃការ ស៊ើបអង្កេតដែលបានអូសបន្ទាយយ៉ាងយូរដោយសារភាពចម្រូង ចម្រាស ចាប់តាំងពីមានការផ្ទួចផ្ទើមនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ របស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក រូបឹត ប៊ឺទីត ។

មានការសន្និដ្ឋានថា រដ្ឋាភិបាលកម្ពុជាកំពុងតែព្យាយាម រារាំងសំណុំរឿងទាំងពីរមិនឲ្យដំណើរការ ។ សហព្រះរាជអាជ្ញា លោកស្រី ជា លាង ជំទាស់ទៅនឹងគំនិតផ្ទួចផ្ទើមឲ្យមានការចោទ ប្រកាន់សម្រាប់សំណុំរឿង០០៣ និង ០០៤ ដែលនេះធ្វើឲ្យ លោក ប៊ឺទីត ធ្វើការងារនោះតែម្នាក់ឯងលើការដាក់ដីកាបញ្ជូនសំណុំរឿង ឲ្យស៊ើបសួរសម្រាប់សំណុំរឿងទាំងពីរ ។ តួនាទីរបស់រដ្ឋាភិបាល ក្នុងសំណុំរឿង០០៣ និង ០០៤ នៅក្នុងឆ្នាំ២០១០ បង្ហាញយ៉ាង ច្បាស់ថានៅពេលដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន សំណុំរឿងទីពីរ មិនត្រូវបានអនុញ្ញាតឲ្យដំណើរការនោះទេ អំឡុងពេលកិច្ចប្រជុំជា មួយអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីម៉ូន ។ ទោះបីជាចាប់តាំងពីពេលនោះមក មន្ត្រីរដ្ឋាភិបាលកម្ពុជាមិនមាន ភាពប្រាកដប្រជា នៅពេលដែលធ្វើបទអត្ថាធិប្បាយអំពីសំណុំ រឿងទាំងពីរ ចំពោះទស្សនៈដែលរដ្ឋាភិបាលបានជំទាស់ថា សំណុំ រឿងទាំងពីរនៅតែដំណើរការ ហើយត្រូវបានលើកឡើងញឹកញយ ដោយបណ្តាញសារព័ត៌មានអន្តរជាតិ នៅពេលដែលមានការ ពិភាក្សាអំពីសំណុំរឿងទាំងពីរនេះ ។ ទស្សនៈបែបនោះ ពិតប្រាកដ ណាស់បានព្រមានប្រជាជនកម្ពុជា ហើយការបញ្ចេញទស្សនៈ ជាសាធារណស្តីពីបំណងប្រាថ្នា និងការចង់បានរបស់ឥស្សរជន នយោបាយជាន់ខ្ពស់នៅក្នុងប្រទេសកម្ពុជា បានជះឥទ្ធិពលដល់ ដំណើរនៃការធ្វើការសម្រេចចិត្ត ។ ទាក់ទងនឹងសំណុំរឿង ០០៣ ឬ ០០៤ ទស្សនៈដែលថា គណបក្សប្រជាជនកម្ពុជារបស់លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន បន្តជំទាស់នឹងការជំនុំជម្រះបានឆ្ទុះបញ្ចាំង និងបានពង្រឹងតាមរយៈអង្គហេតុដែលថា មេធាវី ចៅក្រម និង បុគ្គលិកជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បាន ជំទាស់ទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់សហសេវិកអន្តរជាតិរបស់ ខ្លួន ក្នុងការបន្តសំណុំរឿងឆ្ពោះទៅរកការជំនុំជម្រះ ។

នៅក្នុងឆ្នាំ២០១១ ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវរងការរិះគន់ពីក្រុមអ្នកការពារសិទ្ធិមនុស្ស និងអ្នកច្បាប់ដែល បានចោទប្រកាន់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្ស្រេក ប៊ុង អំពីបទយុបយិត រារាំងសំណុំរឿង០០៣ និង ០០៤ តាមការបញ្ជារបស់រដ្ឋាភិបាល កម្ពុជា ។ ការរិះគន់ទាំងនេះកាន់តែខ្លាំងជាងមុន នៅពេលដែលដីកា បញ្ជូនសំណុំរឿងឲ្យស៊ើបសួរដែលនៅជាអាថ៌កំបាំងនៅក្នុងសំណុំរឿង ទាំងពីរ ត្រូវបានបែកធ្លាយតាមបណ្តាញអ៊ីនធឺណិតរបស់អង្គភាព សារព័ត៌មានប្រទេសញូវហ្សេលែន ដោយសារឯកសារទាំងពីរបាន លម្អិតអំពីការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ នៅខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានបិទការស៊ើបអង្កេត លើសំណុំរឿង០០៣ ប៉ុន្តែមិនព្រមចេញនូវដីកាដំណោះស្រាយ ផ្ទូវការដើម្បីបញ្ចប់សំណុំរឿង ឬត្រូវធ្វើការជំនុំជម្រះ ដោយធ្វើឲ្យ សំណុំរឿងនោះស្ថិតនៅក្នុងសភាពមិនច្បាស់លាស់តាមផ្ទូវច្បាប់ ។ ក្រោយមក នៅខែសីហា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង ស៊ីកហ្ស្រេដ ប៊ុង បានបញ្ចេញនូវបញ្ជីរាយនាមទីតាំង ប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដែលជាប់ទាក់ទងនឹងសំណុំរឿង០០៤ នៅ ក្នុងឯកសារដែលចៅក្រមទាំងពីរបានបង្ហាញអំពីមន្ទិលសង្ស័យ ថាតើជនសង្ស័យក្នុងសំណុំរឿង០០៤ គឺជាអ្នកទទួលខុសត្រូវខ្ពស់ បំផុតឬទេ ។ ការបង្ហាញបញ្ជីរាយនាមនោះ បានបញ្ជាក់ថា ការស៊ើប អង្កេតសំណុំរឿង០០៤ ដែលផ្តោតលើទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ត្រូវបានជឿថា ជាទីតាំងដែលមានជនរងគ្រោះរាប់រយពាន់នាក់ ត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ចុងក្រោយ ចំពេលដែលមានការកើនឡើងការរិះគន់ និង ការចោទប្រកាន់អំពីការស៊ើបអង្កេតមិនមានលក្ខណៈត្រឹមត្រូវ

ចៅក្រម ស៊ីកហ្ស្រូដ ចុ៉ិង បានលាលែងតំណែងនៅខែតុលា ឆ្នាំ២០១១ ដោយលើកឡើងការជ្រៀតជ្រែកផ្ទៃកនយោបាយជាហេតុផលនៃការលាលែងរបស់គាត់ ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ឡូ រ៉ង់ កាសប៊ី អានសឺម៉េត ដែលជំនួសលោក ចុ៉ិង បានសន្យាជាសាធារណៈថា នឹងស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ ប៉ុន្តែផ្ទុយទៅវិញ គួនាទីជាចៅក្រមបម្រុងរបស់គាត់ពុំត្រូវបានទទួលស្គាល់ដោយខ្ពស់ពីក្រុមប្រឹក្សាអង្គចៅក្រម ។ ចៅក្រម យូ ប៊ុនឡេង ដែលជាសមាជិកខ្ពស់ក្រុមប្រឹក្សាអង្គចៅក្រម និងសហព្រះរាជអាជ្ញាជាតិ ជា លាង បានបដិសេធ មិនព្រមធ្វើការជាមួយចៅក្រម កាសប៊ី អានសឺម៉េត ដោយលើកឡើងក្នុងសេចក្ដីប្រកាសព័ត៌មាន ដែលចៅក្រម កាសប៊ី អានសឺម៉េត ចាប់ផ្ដើមស៊ើបអង្កេតសំណុំរឿងទាំងពីរ ហើយបានប៉ុនប៉ងបើកការស៊ើបអង្កេតលើសំណុំរឿង០០៣ ជាថ្មីម្ដងទៀត ។ ចុងក្រោយ បន្ទាប់ពីត្រូវបានរារាំងនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស៊ើបអង្កេត ជាច្រើនខែ ចៅក្រម កាសប៊ី អានសឺម៉េត ដែលបានខកចិត្តចំពោះការប៉ុនប៉ងរារាំងការស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ បានលើកឡើងថា គាត់មិនអាចបំពេញកាតព្វកិច្ច ដោយសារតែភាពមិនចុះសម្រុងក្នុងការធ្វើការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយសុខចិត្តលាលែងតំណែងទៅវិញ ។ ការលាលែងតំណែងរបស់ចៅក្រម កាសប៊ី អានសឺម៉េត បានធ្វើឡើងភ្លាមៗបន្ទាប់ពីគាត់បានបង្ហាញនូវការសម្រេចចិត្តលាតត្រដាងចំណាត់ការរបស់បុគ្គលិកជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការរារាំងការប៉ុនប៉ងស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ ។ ចៅក្រម កាសប៊ី អានសឺម៉េត បានបង្ហាញនូវសេចក្ដីសម្រេចពីរដែលថា ជនសង្ស័យទាំងពីរក្នុងសំណុំរឿង០០៣ មានលក្ខណៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្រោមច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូច្នេះហើយ ការស៊ើបអង្កេតសំណុំរឿង ០០៣ គួរតែបន្ត ។

